# អំពិលផ្អែម

# Sweet Tamarind




រៀបរៀងដោយៈ គ្រោងការសៀវភៅកសិកម្មប្រជុំជន

ការិយាល័យទូ.ប៉ណ 1074 ម៉ថ មហាវិទ្យាល័យកសិកម្មតំបន់បាងខេន ក្រុងទេព 10903

---

បកប្រែ និងរៀបរៀងដោយគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ

នៅខេត្តតំបន់ពាយ័ព្យ, ប្រទេសកម្ពុជា

# អំពិលផ្អែម

# Sweet Tamarind



រៀបរៀងដោយ : គម្រោងការសៀវភៅកសិកម្មប្រជុំជន

ការិយាល័យទូ.ប៉ណ 1074 ម៉ឺថ មហាវិទ្យាល័យកសិកម្មតំបន់បាងខេន ក្រុងទេព 10903

---

បកប្រែ និងរៀបរៀងដោយគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ

នៅខេត្តតំបន់ពាយ័ព្យ; ប្រទេសកម្ពុជា

---

# អំពិលផ្អែម

# Sweet Tamarind

UNDP / OPS
CARERE

## មាតិការឿង

ទំព័រ

1. លក្ខណៈខាងរុក្ខសាស្ត្រ ........ 2
2. ប្រភពកំណើតរបស់អំពិលផ្អែម ........ 7
3. ផលប្រយោជន៍នៃផ្នែកផ្សេងៗរបស់អំពិលផ្អែម ........ 8
4. ពូជអំពិលផ្អែម ........ 13
5. ការពង្រីកពូជអំពិលផ្អែម ........ 24
6. ការជ្រើសរើសទីកន្លែងដាំ ........ 33
7. ការត្រៀមដីដាំ ........ 35
8. រយៈចន្លោះដាំ ........ 36
9. ការត្រៀមរណ្តៅដាំ ........ 39
10. ការជ្រើសរើសពូជ និងការត្រៀមមែកពូជ ........ 40
11. វិធីដាំ ........ 44
12. ការមើលថែរក្សាអំពិលផ្អែមដើមតូច ........ 46
13. ការដាំដំណាំគួបផ្សំ ........ 47
14. ការកំចាត់កត្តាចង្រៃ ........ 51
15. ការធ្វើកន្លែងការពារភ្លើង ........ 54
16. ការផ្តល់ទឹក ........ 55

ទំព័រ


17. ការដាក់ជី ........ 59
18. ការកាត់តែងមែក ........ 66
19. ការចេញផ្កា បំប៉ែនអំពិល និងការចាស់នៃក្ទួរអំពិល ........ 69
20. ការជាប់ផ្លែ ........ 73
21. ការប្រើអ័រម៉ូនជួយក្នុងការជាប់ផ្កា ជាប់ផ្លែ ........ 74
22. ការដោះស្រាយបញ្ហាអំពិលផ្អែមជាប់ផ្លែច្រើនសារ ........ 80
23. ការទុំនៃអំពិលផ្អែម ........ 84
24. ការប្រមូលផល ........ 87
25. ការទុកដាក់ថែរក្សាក្ទួរអំពិល ........ 88
26. សត្រូវសព្វល្អិត និងជំងឺរបស់អំពិលផ្អែម ........ 92
27. រយៈពេលដុះលូតលាស់ធំ និងគំរោងអនុវត្តន៍ ........ 99
28. ឧបសម្ព័ន្ធទីមួយ ........ 99
29. ឧបសម្ព័ន្ធទីពីរ ........ 100
30. ឧបសម្ព័ន្ធទីបី ........ 115
31. ឧបសម្ព័ន្ធទីបួន ........ 121

# អំពិលផ្អែម

អំពិលផ្អែមជារុក្ខជាតិឈើហូបផ្លែដែលគេដាំនៅលើដីទួល ដែលអាចទទួលប្រាក់ចំណូលបានច្រើនផ្លែលក់បានថ្លៃ ។ ដើមអាយុ 8-10 ឆ្នាំ បើថែទាំបានល្អនិងផ្តល់ផលក្នុងមួយដើមបានប្រាក់ចំណូល 10,000 (មួយម៉ឺនបាត) ។

ពាណិជ្ជកម្មផ្សារលក់ដូរអំពិលផ្អែមនោះមានសភាពទូលំទូលាយឆ្ងាយ ទាំងនៅក្រៅប្រទេសនិងក្នុងប្រទេស ។ សព្វថ្ងៃនេះប្រទេសទាំងឡាយនៅមជ្ឈិមបូព៌ាដូចជាប្រទេសអារ៉ាប់សាវ-អ៊ុឌីត្រូវការអំពិលផ្អែម ប៉ុន្តែនៅក្នុងប្រទេសថៃមានផលិតផលអំពិលផ្អែមតិចតួចមិនគ្រប់គ្រាន់ក្នុងការលក់ដូរ ប្រសិនបើមានការផ្សព្វផ្សាយចំណេះដឹងខាងបច្ចេកទេសផលិតអំពិលផ្អែមអោយបានទូលំទូលាយឡើង នោះក៏មុខជាបំពេញនូវសេចក្តីត្រូវការរបស់ទីផ្សារកាន់តែច្រើនឡើង ហើយថ្ងៃណាមួយនឹងនាំអំពិលផ្អែមចេញទៅលក់បានគ្រប់គ្រាន់ជាមិនខាន ។

អំពិលផ្អែមជាឈើផ្លែដ៏ហាររអាយុយូរឆ្នាំមានភាពរឹងមាំមួន ធន់ទប់ទល់ចំពោះដីដែលជាំល្អណាស់ អាចដុះលូតលាស់ដំបានទៅលើដីស្ងួតគ្រប់ប្រភេទ ។ រោគរាលដាលនិងសត្វល្អិតផ្សេងៗក៏មិនសូវមានមកបំផ្លាញ ការថែទាំក៏មិនពិបាក ។ ផលផ្លែក្នុងមួយដើមៗក៏បានចំនួនច្រើនសមរម្យ ។ ដូចនេះនៅក្នុងពេលបច្ចុប្បន្ននេះទើបមានមនុស្សជាច្រើនមានការចាប់អារម្មណ៍បែមកនាំគ្នាដាំអំពិលផ្អែមថែមឡើងទៀត ព្រមទាំងនាំយកមកប្រើនូវបច្ចេកវិទ្យាខាងកសិកម្ម ធ្វើអោយផលិតផលក្នុងមួយឆ្នាំៗកើនឡើងយ៉ាងសម្បើម ក៏ប៉ុន្តែទោះបីជាមានផលិតផលអំពីអំពិលផ្អែមកើនឡើងចំនួនច្រើនយ៉ាងណាក៏ដោយ ក៏នៅមិនទាន់គ្រប់គ្រាន់ដល់សេចក្តីត្រូវការរបស់ទីផ្សារនៅឡើយ ។ ហេតុដូចនេះទើបអាចនិយាយបានថាអំពិលផ្អែមជាឈើផ្លែដែលគួរអោយចាប់អារម្មណ៍ចុះទុនដាំជាមុខរបរដ៏សំខាន់ក្រៃលែង ហើយក៏ជារុក្ខជាតិដែលមានអនាគតដ៏ភ្លឺថ្លាទៅទៅមុខជាយូរអង្វែង ។

លក្ខណៈខាងភូតគាមសាស្ត្រ

ឈ្មោះសាមញ្ញ : ស្វ៊ីតថាម៉ារិនឌី (Sweet Tamarind)
ឈ្មោះវិទ្យាសាស្ត្រ : ថាម៉ារិនឌីអ៊ិនឌិកាលិន្ន (Tamarind Lndica L.)
ស្ថិតនៅក្នុងពូជអំបូរ: លិគុម្មិណូសេអ៊ី (Leguminosae)

ជារុក្ខជាតិដែលស្ថិតនៅក្នុងវង្សពូជអំបូរជាមួយគ្នានិងត្រកូលសណ្តែក :
ត្រកូល : ថាម៉ារិនឌ័ស (Tamarindes)
ប្រភេទ : អ៊ិនឌិកា (Indica)

អំពិលផ្អែមជារុក្ខជាតិមួយប្រភេទក្នុងត្រកូលសណ្តែក ដើមឈរជីហរមានលក្ខណៈដើមជាគុម្ព រូបរាងមូលទំហំធំទ្រង់ទ្រាយដើមបែកមែកសាខាលាតសន្ធឹងចេញទៅដល់ 20 ម៉ែត្រ មានម្លប់ត្រដៃបក្រាស់ ដើមមានកំពស់ប្រហែល 18 ម៉ែត្រ ។ សំបកមានពណ៌ត្នោតខ្ចី បែកជាស្រកាចង្អូរតូចៗ ។ អំពិលជារុក្ខជាតិដែលស្លឹកផ្សំ ។ ស្លឹកមានលក្ខណៈដុះឡើងឆ្លាស់គ្នាមានប្រវែងប្រហែល 7-15 សង្ទីម៉ែត្រ ។ ស្លឹករាយស្ថិតនៅរៀងគ្នាជាគូរមានប្រហែល 10-20 គូ ។ កាលណាស្លឹកចាស់ហើយក៏ជ្រុះជម្រុះអស់ ហើយក៏ដុះបែកត្រួយឡើងមកថ្មីនៅក្នុងរដូវក្តៅប្រហែលនៅក្នុងខែមិនា និងចុងខែមេសា ។ តពីនោះភ្ញេកផ្កានិងដុះលូត-លាស់ធំជាមែកនិងចង្កោមចេញផ្កាបរិបូរណ៍ ។ ក្នុងរដូវភ្លៀងខែឧសភាផ្កាក៏រីក ។ ក្នុងចុងខែឧសភា ដល់ខែមិថុនា ផ្កាអំពិលកើតចេញជាចង្កោមតូចៗនៅចុងមែកមានប្រវែង 10-15 ផ្កា ជាចង្កោមមានភេទបរិបូរណ៍ គឺមានទាំងកេសរឈ្មោល និងកេសរញីជាមួយគ្នាក្នុងផ្កាតែមួយ ចង្កោមផ្កាមានប្រវែងប្រហែល 5-10 សង្ទីម៉ែត្រ ។ ត្របកផ្ការាងពណ៌លឿងស្រៀងៗរាងក្រាស់បន្តិចមានទាំងអស់ 4 ត្របក ។ ត្របកផ្កាមានពណ៌ព្រឹងទុំលាយស នៅខាងក្នុងមាន 3 ត្របក ។ ពួកកេសរឈ្មោលមានរូបរាងដូចអំពូល ចំណែកកេសរញីវិញមាន 3 កំប៉ុក មួយកំប៉ុកៗមានអ័បរេណូស្ថិតនៅក្នុងនោះស្រេច ។ អំពិលនិងជាប់ក្តិបក្ខរ

ល្អមើលហើយផ្ការបានប្រហែលនៅចុងខែធ្នូ ដល់ខែមិថុនា ។ បើជាអំពិលផ្អែមពូជស្រាល និងបេះប្រមូលផលបានប្រហែលនៅចុងខែវិច្ឆិកា ។ បើភ្លៀងក្រអស់ក៏ប្រមូលបេះប្រមូលផ្លែផលក្រអស់ដែរ ។ ក្ញរឬផ្លែអំពិលមានទំហំប្រវែងពី 7.5-20 សង្ទីម៉ែត្រ គន្លាក់មួយៗ ផតបន្តិចបន្តួចមានគ្រាប់ពណ៌ខ្មៅ ឬពណ៌ត្នោតចាស់ របរាងមូលបន្តិច មានសាច់ពណ៌ត្នោតហ៊ុំជុំវិញគ្រាប់ ។

ដើមអំពិលផ្អែមអាចប្រែតម្រូវតាមសភាពធាតុអាកាសនៅក្នុងតំបន់ត្រូពិចបានល្អ អាចដុះបាននៅតាមតំបន់មូសសុង (Mousoon) ដែលមានដីរបាយទឹកបានល្អ មិនចូលចិត្តដីដែលសើមជោគជាំ ធន់ទ្រាំនិងដីដែលមានជាតិអាហារតិច ។ នៅក្នុងប្រទេសអាហ្វ្រិកច្រើនជួបប្រទះអំពិលដុះតាមដីក្បែរដីបូក ។

នៅក្នុងប្រទេសថៃឡង់ដ៍អាចដាំអំពិលបានគ្រប់តំបន់គ្រប់ភូមិភាគអាចដុះបានតាមដី ស្ទើងតែគ្រប់ប្រភេទ ប៉ុន្តែនិងដុះល្អតលាស់ធំបំផុតនៅតាមដីទឹកហូររបាយខ្សាច់មមោត ឬដីផ្សំរបាយដីឥដ្ឋ ប៉ុន្តែដីគ្រួសក្រហមក៏អាចដាំអំពិលបានដែរ ។

កាលណាចូលដល់ខែមករា និងខែកុម្ភៈ អំពិលក៏និងចាប់ជំរុះស្លឹកចោលខ្លះតាមផ្នែក ហើយនិងបែកត្រួយប្រហែលនៅពាក់កណ្ដាលខែមេសា ។ លុះចាប់ផ្ដើមរដូវភ្លៀងក៏ចាប់ផ្ដើមចេញផ្កាចេញផ្លែ ។ ទាំងនេះស្រេចតែរយៈពេលភ្លៀង ។ បើឆ្នាំណាមានភ្លៀងធ្លាក់ពន្យាទៅទៀត ការចេញផ្កា ចេញផ្លែ (ផ្លែ) ក៏ពន្យាពេលទៅផងដែរ ។ សំរាប់គំរោងកសាងលូតលាស់របស់អំពិលមានដូចតទៅនេះ :

ឫស : អំពិលផ្អែមដែលបណ្ដុះពីគ្រាប់ មានប្រព័ន្ធឫសជាឫសកែវ ដែលចាក់គ្រាប់ទៅក្រោមយ៉ាងជ្រៅ ហើយឫសជាច្រើនបែកចេញល្អណាស់ ធ្វើអោយវាអាចស្រូបយកចំណីបានល្អផងជាងឈើហូបផ្លែផ្សេងៗទៀត ។

សង្ទីម៉ែត្រ ទាំងពីរជំហៀងផ្កាមានលក្ខណៈដូចគ្នា ។ មានត្របកផ្កាពណ៌ក្រហម រូបរាងវាស្រដៀងទៅនឹងទូកវែងប្រវែង ប្រហែល 8 មល្លីម៉ែត្រ ចំនួន 2 ត្របក មានត្របកស្លឹកមានលក្ខណៈកោងចុះជារូបពងមាន់ពណ៌ក្រាមវែងប្រហែល 1-1.5 សង្ទីម៉ែត្រ ចំនួន 4 ត្របក ។ ត្របកផ្កាកើតត្រង់ផ្នែកលើរបស់ផ្កាមានពណ៌លឿងព្រៀងៗ មានខ្សែតូចឆ្នារពណ៌ក្រហមប្រវែង 1-1.5 សង្ទីម៉ែត្រ ចំនួន 3 ត្របក ហើយនៅមានត្របកផ្កា 2 ត្របកទៀត ដែលមើលឃើញជាសសៃរោមល្អិតៗបង្គប់នៅត្រង់គល់របស់កេសរឈ្មោល ។

ផ្កាអំពិលជាផ្កាដែលមានប្រភេទគ្រប់បរិបូរណ៍ មានកេសរឈ្មោលដែលផ្សំពូជបាន 3 ស្ថិតនៅផាស់គ្នានិង កេសរឈ្មោលដែលផ្សំពូជមិនបាន (ខ្ទើយ) ។ ទង-កេសរឈ្មោលមានប្រវែង 1 សង្ទីម៉ែត្រ ទងកេសរនេះនិង ផ្សាភ្ជាប់គ្នាប្រវែង 1l សង្ទីម៉ែត្រ នៃប្រវែងរបស់ទងកេសរ ហើយទើបមូរទងឡើងទៅលើនៅខាងក្រោមត្របកផ្កា ។ មានអ័បរណ្ឌពណ៌ត្នោតលាយក្រហមនៅផ្នែកខាងទទឹងអ័បរណ្ឌនិងបែកតាមបណ្ដោយ ។ កេសរញីមានពណ៌ខ្សៀវមានរោមច្រើនសំបើមកោងឯឡើងទៅលើ ។ ទងកេសរញីវែងជាងកេសរឈ្មោល ។ ត្រង់ចុងកេសរញីញែកជាផែកៗ សំបុកពងតាមជាប់ជាមួយបំពង់របស់ត្របកចិញ្ចើមខាងក្នុងសំបុកពងរបស់កេសរញី ហើយមានពងចំនួនច្រើន ។ ការផ្សំកេសរនៃអំពិលអាស្រ័យទៅលើសត្វល្អិតជាភ្នាក់ងារជួយផ្សំ ។

ក្ឋរ(ផ្លែ) កាលណាក្ឋរអំពិលគ្លិបខ្ចី និងមានពណ៌ខៀវស្រស់ និងមានទ្ធន ឬលំអងពណ៌ត្នោតចាប់នៅទើបមើលទៅឃើញជាពណ៌ខៀវលាយត្នោត ។ សាច់ខាងក្នុងពណ៌សទ្ធនមានរស់ជាតិជូរខ្លាំង ។ តមកកាលណាមានអាយុច្រើនឡើងសាច់ក៏មានពណ៌លឿងទ្ធនហើយក៏ប្រែទៅជាពណ៌ត្នោតចាស់ស្រកស្ងួតរបួតចេញពីសំបកក្ឋរ ហើយតបកសំបកក្ឋរក៏ស្ងួតអាចប្រកាច់អោយបែកបានងាយជាទីបំផុត ។ ចំណែកសាច់

ហ៊ុំស្រោបគ្រាប់ស្អិតនៅជិតគ្នាវែងរហូតមានលក្ខណៈស្អិតរមួត ហើយមានសរសៃយឺត 3 សរសៃ តាមបណ្តោយក្ទួរដែលហៅថា " សរសៃស្បូន " សាច់ពណ៌-ត្នោត ចំណែកគ្រាប់មានពណ៌ត្នោតចាស់ ។

ផ្លែ ឬក្ទួរអំពិល មិនថាជាអំពិលផ្អែម មិនថាជាអំពិលជូរទេ ក្ទួរមានលក្ខណៈញែកចេញជាពីរប្រភេទ :

" អំពិលក្តា : មានក្ទួរសំប៉ែតធំ និងអំពិលអាចមន៍ឆ្មា : មានក្ទួរមូលតូច "

នៅក្នុងសៀវភៅកសិករឆ្នាំ 50 ក្បាលទី 4 ប្រចាំឆ្នាំ 2520 លោកស្មៀនហាមណាន បានបែងចែកលក្ខណៈនៃក្ទួរអំពិលផ្អែមចេញជា 4 ប្រភេទ :

1. ក្ទួរដាវ : មានលក្ខណៈកោងបន្តិចដូចជារូបដាវ
2. ក្ទួរគង : ចុងក្ទួរមានលក្ខណៈកោងងរហូតមកជួបគ្នា ឬក៏ពាក់លើគ្នាមានលក្ខណៈជារង្វង់មូលស្រដៀងវង់គង
3. ក្ទួរលាត : មានលក្ខណៈវែងមិនកោងដូចប្រភេទដទៃទៀត ក្ទួរចាស់មានសំបកជិតគ្នានិងទងភាគខាងលើ
4. ក្ទួរឆ្នើង : មានលក្ខណៈងជាថ្នាំងៗ ខុបមើលឃើញច្បាស់ស្រដៀងគ្នា និងសណ្តែកដី

ពណ៌សំបកអំពិលផ្អែមមានចាប់ពីពណ៌ត្នោតក្រម៉ៅ ជិតតែនិងខ្មៅពណ៌ត្នោតព្រៀងៗពណ៌លឿងជិតដូចទឹកឃ្មុំ ពណ៌ត្នោតក្រហមចាស់និងពណ៌លឿង ។

រសជាតិអំពិលផ្អែមទាំងប្រភេទជូរទាំងប្រភេទផ្អែម មានភាពផ្អែមតាំងតែ 30% ឡើងទៅ ហើយមានជាតិប្រូតេអ៊ីនមានទៅដល់ 30% ។ ប៉ុន្តែបើអំពិលពូជណាមានរសជាតិឆ្ងាញ់តិចច្រើន ស្រេចតែប្រភេទនីមួយៗនៃពូជអំពិលនោះឯងតែម្តង

គ្រាប់ : ភាគច្រើនអំពិលផ្អែម និងមានគ្រាប់ដែលមានរូបរាង និងលក្ខណៈខុសប្លែកពីគ្នាទៅតាមពូជ ។ ពូជខ្លះមានគ្រាប់ធំប៉ុន្តែពូជខ្លះមានគ្រាប់តូច ភាគច្រើនគ្រាប់អំពិលផ្អែមមានលក្ខណៈសំបកគគ្រើម ។

## ប្រភពកំណើតនៃអំពិលផ្អែម

អំពិលផ្អែមមានប្រភពកំណើតដើមនៅក្នុងព្រៃទំនាបក្នុងតំបន់ក្តៅ ក្នុងទ្វីបអាហ្វ្រិកខាងកើតរវាងអាប៊ិស៊ីនិចុះមកខាងត្បូង រហូតដល់ដូរទន្លេសែមប៊ីលមកភាគខាងត្បូងនៃប្រទេស-ឥណ្ឌាមានអំពិលដុះក្នុងព្រៃយ៉ាងសម្បើមដែលគេស្មានថា ប្រហែលជាមានមនុស្សធ្លាប់រស់នៅបានយកអំពិលចូលមកដាំនៅក្នុងប្រទេសឥណ្ឌា ក៏ប៉ុន្តែគ្មានភស្តុតាងប្រាប់អោយដឹងថាមានការដាំដុះតាំងតែពីកាលណាមក ។ អ្នកប្រាជ្ញជាតិក្រិកបានពោលទុកមានការដាំអំពិលផ្អែមយ៉ាងច្រើនសុះសាយ នៅក្នុងប្រទេសអ៊ីហ្សិបចាប់តាំងពីសម័យសតវត្សទី 4 មកម្លេះ ដោយមានគេប៉ាន់ស្មានថាមនុស្សយើងបានចាប់ផ្តើមដាំអពិលផ្អែមមុនពេលវេលាដូចបានពោលមកហើយនោះ ។ ប្រទេសដែលគេដាំអំពិលផ្អែមគឺមាន ឥណ្ឌា បង់ក្លាដេស សេរីលង្កា ឥណ្ឌូនេស៊ី ភូមា ថៃឡង់ដ ស្ងឹង្ហ័ តៃវ៉ាន់ ម៉ាឡេស៊ី និងប្រទេសដទៃទៀតនៅប៉ែកអាស៊ីនិរតី ។

ចំពោះប្រទេសថៃឡង់ដ៍ មានដាំអំពិលផ្អែមពាសពេញផ្នែកខាងជើងភាគឥណ្ឌូសាន្ត ជា-ពិសេសតាមមាត់ទន្លេមេគង្គ ដូចជាខេត្តព្រែ ណាន ឡាំប៉ាង ពេជ្របូរណ៍ ណងខាយ ហើយនិងឧបលរាជធានីជាដើម ។

ចំពោះកំណើតពាក្យថា Tamarind (អំពិល) ដែលជាឈ្មោះសាមញ្ញនៃអំពិល នេះមិនទាន់ដឹងច្បាស់អាចមកពីភាសាអារ៉ាប់ថា Tarmar- U'L Hind ប្រែថាផ្លែល្មើឥណ្ឌា (Date of India) ឬក៏មកពីភាសាពែក្ស (Persian) ថា Tamar L-Hindi ក៏បាន តែយើងដឹងថាពាក្យដំបូងឡើយប្រហែលជាមិនបានប្រើពាក្យថា Tamar ប្រែថាផ្លែល្មើ ទេ វាគួរតែមកពីពាក្យថា Thamar ប្រែថាផ្លែច្រើនជាង ។ ក្រៅពីប្រទេសឥណ្ឌានៅមានតាមបណ្តាប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដូចជាប្រទេសម៉ាឡេស៊ី លាវ និងប្រទេសថៃ ដែលនៅក្នុងប្រទេសកម្ពុជាយើងមានអំពិលជូរ និងអំពិលផ្អែមនៅតាមខេត្តផ្សេងៗ ជាពិសេសគេនាំប្រភេទនេះមកដាំនៅក្នុងភូមិភាគឧត្តរ និងភូមិភាគឦសាន្ត ។

ផលប្រយោជន៍នៃផ្នែកផ្សេងៗនៃអំពិល :

អំពិលជារុក្ខជាតិមានប្រយោជន៍សន្ធឹកសន្ធាប់ណាស់ ជាទូទៅគេច្រើនតែយល់ថាអំពិលជារុក្ខជាតិដែលមានប្រយោជន៍ចំពោះតែគួរ (ផ្លែ) ដើម្បីយកទៅបរិភោគ និងយកដើមធ្វើជ្រលងតែប៉ុណ្ណោះទេ ។ ប៉ុន្តែការពិតយើងអាចប្រើគ្រប់ផ្នែកនៃដើមអំពិលអោយកើតជាផលប្រយោជន៍បានយ៉ាងសន្ធឹកសន្ធាប់ណាស់ ពោលគឺ :

សាច់ សាច់អំពិលចាប់ផ្តើមប្រើជាប្រយោជន៍បាន ចាប់តាំងពីចេញគួរខ្ចីៗយកមកធ្វើជាអាហារ ដូចជាធ្វើទឹកគ្រឿងម្ជូរអំពិលខ្ចី ឬប្រើបរិភោគស្រស់ៗជាមួយអំបិល-ម្ទេស ឬកាពិផ្អែម ។ គួរស្រស់ដែលចាស់ណាស់ហើយគ្រាប់ក៏ប្រែពណ៌ ប៉ុន្តែសំបកក្ដូរនៅមិនទាន់សណ្ដកគេនិយមធ្វើអំពិលក្រាំស្ករ ។ ជួនកាលគេនិយមយកមកដុតភ្លើងអោយទាល់តែក្រៀម ឬកប់ក្នុងផេះភ្លើងរួចហើយយកសំបកចេញប្រើបរិភោគបាន ។ កាលណាគួរអំពិលចាស់មែនទែនហើយគ្រាប់ក៏ប្រែទៅជាពណ៌ខ្មៅ សាច់មានពណ៌ស ឬសំបកចាប់ផ្តើមប្រែពណ៌ទៅជាពណ៌

ផ្កាតម្រៀង១ខ្លះហើយ ។ សំបកញែកចេញពីសាច់គេហៅថា " អំពិលគួរ "
អំពិលគួរនៃអំពិលផ្អែមមានរសជាតិជូរអែមដែលចាត់ទុកថារសជាតិឆ្ងាញ់ណាស់

គួរអំពិលគួរដែលចាស់មែនទែន សំបកផ្លែ ស្រួយល្អហើយ កាលណាយកសំបកចេញហើយ សាច់ខាងក្នុងហៅថាអំពិលបក ។ អំពិលបកក្រៅពីបង់សម្លផ្សេងៗ ហើយនៅប្រើធ្វើទឹកជ្រលក់អំពិល ត្រណាប់អំពិល អំពិលប្រឡាក់ស្ករ ចំណែកប្រទេសឥណ្ឌា និងប្រទេសជិតខាងយកអំពិលទៅត្រាំត្រី ដើម្បីកុំអោយត្រីឆ្អាប ហើយប្រើដាក់សម្លការី ។ នៅប្រទេសអង់គ្លេស និងប្រទេសផ្សេងៗនៅអ៊ឺរ៉ុប គេប្រើធ្វើទឹកជ្រលក់ ។ ចំណែកនៅឯប្រទេសអាមេរិកវិញគេប្រើធ្វើភេសជ្ជៈប្រភេទជាអាកុល ក្រៅពីនេះសាច់អំពិលនៅមានប្រយោជន៍សំរាប់លាងសំអាតភាជនៈទង់ដែង និងស្ពាន់បានល្អទៀតផង ។

សាច់អំពិលមានគុណសម្បត្តិក្នុងការធ្វើជាថ្នាំការពាររោគឈាមចេញតាមអញ្ចាញធ្មេញ ។ នៅប្រទេសម៉ូរិសល្បែស ប្រើអំពិលផ្សំនិងអំបិលកែរោគពោះចុកចាប់តាមសន្លាក់ និងតាមសាច់ដុំ ។ ក្នុងប្រទេសហ្វីលីពីនស៍ប្រើជាថ្នាំរពាយ ថ្នាំបញ្ចុះព្រូនសត្វ ដោយដាក់លាយជាមួយទឹកក្តៅឧណ្ហៗ ចាក់បញ្ចូលតាមទ្វាររបស់សត្វ ចំណែកនៅក្នុងប្រទេសថៃឡង់ដ៏ច្រើនយកអំពិលទៅធ្វើជាថ្នាំបូរាណផ្សេងៗ ។

សំបកផ្លែ សំបបកផ្លែអំពិលចាស់ដែលបកយកសាច់ចេញហើយ អាចយកមកប្រើជាថ្នាំផ្សះ ។ នៅភូមិភាគឧត្តរនៃប្រទេសថៃឡង់ដ៏ប្រើសំបកផ្លែមកអំពិលអោយបែកជាកំទេចល្អិតៗ ផ្សំជាមួយនឹងសារសៃថ្នាំជក់ជួយធ្វើអោយមានរសជាតិសារសៃថ្នាំឆ្ងាញ់ ទន់ល្អឡើងទៀត ។

គ្រាប់ គ្រាប់អំពិលលីង ឬស្ងោរប្រើបរិភោគបាន ។ នៅប៉ែកល្វែងសមុទ្រប៉េរ៉ុកលគេប្រើធ្វើថ្នាំកែរោគមួល ទឹកស្ងោរគ្រាប់កែរោគបួស ។ គ្រាប់អំពិលលីងហើយ ហើយគោះយកសំបកចេញ ប្រើថ្នាំកែរាគអាចម៍រោគមួល ចង្អោរក្អួត និង ជាថ្នាំព្រូន ។ សាច់ក្នុងគ្រាប់អំពិលនេះជាប្រភពដែលអោយម្សៅមានគុណភាពល្អទៀតផង ។ នៅក្នុងប្រទេសឥណ្ឌូគេយកមកកិនអោយល្អិត ហើយហូត់យកមកធ្វើជាកាវដែលមានគុណភាពខ្ពស់ ជំនួសការប្រើម្សៅអង្ករ ធ្វើអោយអាចបន្ថយបរិមាណការប្រើម្សៅអង្ករ និងម្សៅសាគូដែលប្រើនៅក្នុងរោងចក្រឧស្សាហកម្មក្រដាស ។ ត្រៀងតំបាញ និងធ្វើកាវបានធ្វើអោយប្រទេសឥណ្ឌាសន្សំសំចៃអង្ករទុកសំរាប់បរិភោគបានទៅដល់មួយឆ្នាំ 40 លានបាត ។ ក្រៅពីនេះម្សៅដូចពោលមកហើយនោះ ទៅនាំយកមកធ្វើជាចំណីអាហារថ្នាក់ល្អ និងធ្វើរ៉ូទិ ដោយមកអំពីម្សៅក្នុងគ្រាប់អំពិល មានកាបូអ៊ីដ្រាតដែលគេហៅជាចេលឡូស (Jellose) ដែលមានគុណសម្បត្តិដូចគ្នានឹងសារាយដែរ ។ ដូចនេះកាលណាផ្សំចូលគ្នាជាមួយនឹងសារៈធាតុលាយពណ៌ក្ស ហើយនឹងធ្វើជាម្សៅកាវបានយ៉ាងល្អបំផុត ពីព្រោះមានភាពស្អិតខ្លាំងណាស់ ។ ម្សៅបែបនេះគេយកទៅប្រើនៅក្នុងរោងចក្រឧស្សាហកម្មធ្វើសំពត់ផ្កា ដើម្បីបោះពុម្ពក្បាច់ក្បូរទៅលើផែនជ័រកៅស៊ូទៀតផង ។ ក្រៅពីនេះប្រេងដែលចំរាញ់បានអំពីគ្រាប់អំពិល នៅនាំយកមកប្រើប្រកបអាហារ ប្រើជាប្រេងលាបអោយរលោង ឬលាយជាមួយថ្នាំលាបផ្ទះ ប្រើជាប្រេងអុជចង្កៀង ។ នៅក្នុងប្រទេសឥណ្ឌូនេស៊ីប្រើជាថ្នាំថែរក្សាសក់ ។

សំបកគ្រាប់ សំបកពណ៌ត្នោតដែលហ៊ុំស្រោបគ្រាប់នោះ កាលណាគោះអោយរបកយកសាច់ពណ៌សខាងក្នុងចេញហើយ អាចយកមកធ្វើជាចំណីសត្វ ឬយកមកផ្សំជាមួយសាច់ផ្លូវ និងប្រេងចំហុយប្រើជាថ្នាំលាបសក់ និងរោមជ្រៀមក៏បាន ។

ស្លឹក ត្រួយ ឬចុងត្រួយអំពិល និយមធ្វើជាម្ហូបអាហារ ដូចជាសម្លម្ជូរ ស្ងោរម្ជូរត្រី ប្រឡាក់ ស្ងោរត្រី ។

ស្លឹកចាស់ : នៅក្នុងប្រទេសឥណ្ឌា គេប្រើស្លឹកចាស់យកទៅចំរាញ់យកពណ៌ ដើម្បីធ្វើថ្នាំជ្រលក់សំពត់ ។ នៅក្នុងប្រទេសម៉ាកាស៊ី (ពីដើម ម៉ាដាកាស្ការ៍) ប្រើជាថ្នាំពុទ្ធ ហើយធ្វើអោយប្រព័ន្ធរំលាយអាហារធ្វើការបានប្រសើរឡើងៗ នៅអាហ្វ្រិកខាងលិចប្រើស្លឹកអំពិលស្ងួតមកបុកបិទមុខដំបៅ រោគពិសរឹងរៃ កាត់ស្លេស កែរោគម្លូល កែក្អក ។ ក្រៅពីនេះនៅមានគេធ្លាប់យកស្លឹកអំពិលមកទំពារ រួចយកទៅបិទលើស្នាមពោះចឹកដើម្បីបឺតយកពិសពោះ ។ នៅក្នុងប្រទេសថៃឡង់ដ៏ប្រើស្លឹកអំពិលចាស់ និងស្លឹកគ្រូចដាំទឹកកក់សក់ ឬងូតទឹកអោយក្មេង ដើម្បីធ្វើអោយក្បាល និងសាច់ស្អាត ។ ស្លឹកអំពិលស្ងោរនឹងខ្ទឹមបារាំងយកមកប្រើងូតអោយអ្នកមានជំងឺគ្រុនក្ដៅនៅក្នុងរយៈពេលស្បើយពីគ្រុន និងរោគផ្ដាសសាយបានទៀតផង ។

ដើម ឈើអំពិលជាឈើសាច់រឹង ស្វិត មានក្រយៅល្អិតស្អាតណាស់ យកមកប្រើធ្វើគ្រឿងប្រដាប់ប្រដារបានយ៉ាងច្រើនដូចជា តុ ទូ គ្រែ ដងចបកាប់ ដងចបជីក ធ្វើជ្រូញ ហើយដុតធ្វើជាធ្យូងមានគុណភាពល្អណាស់ ។

ឫស នៅក្នុងភាគខាងជើងនៃប្រទេសនីជេរី ប្រើឫសអំពិលកែរោគឃ្លង់ ។

សំបកនិងសរសៃ សំបកនឹងសរសៃអំពិលមានគុណសម្បត្តិធ្វើជាថ្នាំកែរោគក្នុងប្រទេស ទែនសានី (ដើមហៅទាន់ក៏នីកា) ប្រើសរសៃ និងសាច់ដុសខាត់សំអាតទង់ដែង និងស្ពាន់ ហើយនិងប្រើជាមេភ្លើងបានទៀតផង ។





ពូជអំពិលផ្អែម :

ពូជអំពិលផ្អែមនាបច្ចុប្បន្ននេះមានច្រើនសន្ធឹកសន្ធាប់ណាស់ ដោយមកពីតម្លៃខ្ពស់ជាងផ្លែឈើដទៃផ្សេងៗទៀត ធ្វើអោយមានការសិក្សា និងជ្រើសរើសពូជអំពិលផ្អែមសំបើមណាស់ ជាហេតុអោយកើតមានពូជថ្មីៗដែលគេប៉ាន់ស្មានថាល្អលើសជាងរបស់ដើមទៅទៀត ។ ពាក់ដែលគេបានប្រទះឃើញសព្វថ្ងៃនេះ គឺមានច្រើនជាង 20 ពូជ ។ ពូជខ្លះមានលក្ខណៈរូបរាងប្រហាក់ប្រហែលគ្នាដែលម្ចាស់ចំការអំពិលផ្អែម និងដាក់ឈ្មោះដោយខ្លួនឯងដោយយកប្រភពដាំ ឬឈ្មោះម្ចាស់នោះដាក់ឈ្មោះពូជ ឬដាក់ឈ្មោះតាមម្ចាស់ដើមកន្លែងកំណើតរបស់ដើមអំពិលនោះ ឬតាមលក្ខណៈពិសេសនៃដើមអំពិលតែម្តង ។ ពូជខ្លះអាចមានលក្ខណៈនិងរូបរាងប្រហាក់ប្រហែលគ្នា ដែលម្ចាស់អំពិលផ្អែមអាចដាក់ឈ្មោះដោយខ្លួនឯងដោយអាស្រ័យទៅលើប្រភពដាំ ឬឈ្មោះម្ចាស់នៃពូជនោះ ដាក់ជាឈ្មោះពូជដូចបានឃើញអំពីការប្រកួតអំពិលផ្អែមតាមខេត្តផ្សេងៗ បានឃើញមានពូជថ្មីៗកើតមានឡើងជានិច្ច ។ ប៉ុន្តែកាលណាចងក្រង និងសិក្សាលក្ខណៈនៃគុណសម្បត្តិប្រចាំពូជនេះហើយក៏បានប្រទះឃើញថាមានពូជអំពិលផ្អែមមិនប៉ុន្មានពូជទេ ។ ឈ្មោះពូជដែលល្បីហៅដោយអនុលោមទៅតាមឈ្មោះដែលមានដូចតទៅនេះ :

1. <u>ពូជទឹកឃ្មុំ</u> : ជាអំពិលផ្អែម ពូជស្រាល (ក្រផ្លែ កាលណាមានអាយុច្រើនឆ្នាំ ផ្លែច្រាស់) ។ ដើមមានសំបកចេញពណ៌ត្នោតរាងក្រមៅ ។ ទំរង់គុម្ពដើមធំល្មម ស្លឹកមិនក្រាស់ណាស់ណា ស្លឹកខៀវចាស់ខ្លាំង ផ្លែមានឯកលក្ខណៈចំពោះស្រដៀងនឹងជង្គង់ជ្រុងឬស្រដៀងវង់គង គឺខុបខ្លាំង ។ ប៉ុន្តែកាលណាប្រៀបធៀបនឹងពូជផ្សេងទៀតទំហំផ្លែតូចជាង ដើមអាយុ 2-3 ផ្លែតូច ហើយអាយុចាប់ពី 5 ឆ្នាំ ឡើងទៅផ្លែនិងមានទំហំធំ សំបករាបគ្មានចង្អូរជ្រៅទេ ផ្លែខ្ចីរសជាតិជូរចត់ ទុំ ចាស់សាច់មានពណ៌ត្នោតក្រមៅរសជាតិផ្អែម ។ សាច់ត្នោតពណ៌ចាស់រសជាតិផ្អែមឆ្ងាញ់ ក្រអូបខ្លិនដូចទឹកឃ្មុំសំបកផ្លែក្រាស់បើទុកយូរ ។ ជាទូទៅពូជទឹកឃ្មុំដាំនៅលើដីខ្ពស់ក៏បាន ប៉ុន្តែត្រូវបាន

ប្រព័ន្ធទឹកចេញចូលអោយបានល្អ ។ ចំការទំនាបមានប្រៀបជាងចំការដីខ្ពស់ ពីព្រោះទីទំនាបយូរៗទៅដើមនឹងធំធាត់មាំមួនល្អបរិបូរណ៍ជាង ប៉ុន្តែទីខ្ពស់ធំរហ័ស ។ លុះអាយុច្រើនឡើងៗនឹងស៊ូទីទំនាបមិនបានទេ ពីព្រោះខ្វះភាពឧបត្ថម្ភសំបូរ ។ អំពិលពូជទឹកឃ្មុំចេញផ្កាប្រហែលនៅខែមេសា ចេញក្ដួរប្រហែលចុងខែវិច្ឆិកាដើមខែធ្នូ ។ បេះប្រមូលផលនៅខែវិច្ឆិកា ឬខែធ្នូ ។ ជាប់ក្ដួរច្រើនប៉ុន្តែមិនមែនជាចង្កោមទេ ក្នុងមួយៗពោតពេញមួយដើម ។ ផ្លែក្នុងមួយដើមៗអំពិលដែលមានអាយុ ៦-៧ ឆ្នាំ អាចបេះផលបានប្រហែល 50-100 គីឡូក្រាម ប៉ុន្តែបើមានការថែទាំបានល្អអាចផ្ដល់ផល 150-200 គីឡូក្រាម ក្នុងមួយដើម ។

ការខាតបង់នៃពូជទឹកឃ្មុំគឺនៅត្រង់ផ្លែតូច ពីព្រោះការចេញផ្កា និងជាប់ផ្លែមានច្រើនហួសពេក ។ សាច់មិនសូវពេញ ពីព្រោះស្លឹកធំ ។ បរិមាណស្លឹកច្រើន ហើយក្រាស់ កាលណាផ្លែស្វែះស្ទូវអាហារដែលនាំយកទៅចិញ្ចឹមផ្លែតិច ភាគច្រើននាំយកទៅចិញ្ចឹមស្លឹកច្រើនជាងបានជាផ្លែទើបមិនសូវធំ ។ បើត្រូវការអោយផ្លែធំត្រូវកាត់តែងមែកដើម្បីកុំអោយផ្លែស្វែះស្ទូវពេក ។

2. <u>ពូជស៊ីជំពូ</u> : ជាអំពិលផ្អែម ពូជស្រាលដូចគ្នានិងពូជទឹកឃ្មុំដែរ ។ ដើម សំបកមានពណ៌ត្នោតប្រផេះ ឬពណ៌ត្នោតចាស់ ។ ស្នាមបែកស្រកាធំ ។ ពោះមែកជាចង្អូរ ។ ទំរង់គុម្ពដើមស្ថិតនៅត្រង់ឡើងទៅលើមិនរីកសាយចេញទេ ទំរង់គុម្ពដើមស្រដៀងឆ័ត្រ មែកខ្ចីក្រមប់ ស្លឹកពណ៌ខៀវចាស់ ចុងត្រួយមានពណ៌ក្រហមខ្លាំងរួចក្រហមព្រៀងៗបន្តិចម្តងៗរហូតទៅជាពណ៌ជំពូរ ។ ចេញផ្កាប្រហែលនៅចុងខែឧសភា ។ ផ្លែចាស់បេះប្រមូលផលបាននៅដើមខែធ្នូ ។ ផ្លែចាស់សង្កេតបានត្រង់ពោះចាប់ផ្ដើមផតចុះ ផ្លែដែលមិនចាស់ គ្រាប់មកខ្ចីហើយមូល លុះចាប់ផ្ដើមចាស់គ្រាប់ត្រូវជាពណ៌ត្នោត ឬខ្មៅ សំបកនិងប្រែពណ៌ពីពណ៌ត្នោតទៅជាពណ៌ប្រផេះ ។ ទងផ្លែចាប់ផ្ដើមក្រៀមអោយដឹងថាចាប់ផ្ដើមចាស់ហើយ លក្ខណៈផ្លែទូទៅជាអំពិល



ដែលមានលក្ខណៈផ្លែត្រង់ធំ វែងជាងអំពិលផ្អែមពូជដទៃៗទៀត ។ បរិវេណខាងក្រៅជាកញ្ចូរសីប៉ែតដែលគេហៅថា " កូរអ៊ិករង " សំបកកូរស្តើងទំងន់ប្រហែល ៤ ទៅ ៥ ផ្លែ ក្នុងមួយគីឡូក្រាម ។ ផ្លែជាប់ច្រើនមធ្យម ពីព្រោះវាជាអំពិលផ្អែមពូជត្រាណោ ។ ចំណែកឯរសជាតិផ្អែមដូចជាចេកហាលគឺស្អិតណាស់ ខ្ទិះក្រអូប សាច់-ក្រាស់ ពណ៌លឿងទុំ ព្រមទាំងខ្មោតលឿង គ្រាប់រលុង គ្មានកាក សរសៃដែលស្រោបគ្រាប់វិញមានតែ ២ ៣ សរសៃតែប៉ុណ្ណោះ ។

ការខូចខាតបង់នៃអំពិលពូជផ្អែមនេះ គឺដោយសារការប្រែប្រួលរសជាតិផ្អែមទៅច្រើន កាលណាមានការប្រែប្រួលផ្លាស់ប្តូរសភាពធាតុអាកាសបរិមាណទឹកភ្លៀង ។ លើសពីនេះទៅទៀតឆ្នាំណាមានភ្លៀងធ្លាក់ ជាពិសេសក្នុងខែវិច្ឆិកានិងធ្វើអោយមានការទុំយឺតជាងការកំណត់ ហើយកាលណាទុំនិងមានរសជាតិជូរអែម ព្រោះមានទឹកច្រើន ឫសនិងស្រូបយកធាតុអាហារចូលទៅចិញ្ចឹមផ្នែកផ្សេងៗបានច្រើនឡើង ជាពិសេសស្លឹកមិនផ្អាកការលូតលាស់នៅតែធ្វើការកសាងក្រូតស៊ុលហ្វួរិកក្នុងកូរផ្លែរហូត ធ្វើអោយសារៈធាតុដែលនិងធ្វើប្រតិកម្មផ្លាស់ប្តូរក្រូតនេះទៅជាស្ករ ត្រូវសាងឡើងមិនទាន់ទើបធ្វើអោយមានក្រូតស៊ុលហ្វួរិកជាប់នៅក្នុងកូរច្រើន ជាមូលហេតុធ្វើអោយសាច់ជូរ ក្រៅពីនោះការដែលមានសំបកស្តើងធ្វើអោយកូរបែកងាយ បើប៉ះដង្កិចឡាខ្លាំងៗ ។

3. <u>ពូជហ្មឹនចុង</u> : អំពិលពូជហ្មឹនចុងជាដើមត្រកូលអំពិលផ្អែម មានដើមកំណើតកើតមកបានយូរជាង 200 ឆ្នាំ ចាត់ជាអំពិលផ្អែម ពូជធ្ងន់ មានប្រភពកំណើតនៅស្រុកឡុមភោ ខេត្តពេជបូរណ៍ ។ លក្ខណៈស្លឹកធំ ពណ៌ខៀវស្រស់ ចំនួនស្លឹកមានតិចធ្វើអោយទំរង់គុម្ពដើមមិនក្រាស់ ។ សំបកដើមពណ៌ត្នោតចាស់ជិតខ្មៅ កូរខុបធំ ចាត់ជាបែបកូរគង ពីព្រោះកូរខុបខ្លាំងទាល់តែជិតគ្នាទៅជារូបរង់ គង់មានផ្លែស្វែះរៃរ ល្មមសមគួរ ប៉ុន្តែបើថែទាំមិនល្អគ្រប់គ្រាន់អាចមានផ្លែស្វែះច្រើនមួយឆ្នាំ ខានមួយឆ្នាំ ការសំខាន់នោះគឺជាអំពិលដែលឆ្ងាញ់បំផុត ។ កូរធំបំផុតរសជាតិផ្អែមមុតគ្មានជូរសោះ



ពូជអម្ពិលចុង

សាច់ក្រាស់គ្រាប់ល្អិតកាលណាចាស់មានពណ៌ខ្មៅចាស់ សាច់ល្វត មិនជាប់គ្រាប់ ហើយពីព្រោះគំរោងសាងនៃសំបកមិនល្អ ។ មុនផ្លែទុំបើអាកាសធាតុមិនល្អគឺគ្រជាក់ ហួតហែងភ្លាមៗនៅពេលភ្លៀងរាំងក្លួរនិងបែក 40%-60% ។

4. ពូជពណ៌មាស : អំពិលផ្អែមពូជពណ៌មាស (លោក យ៉ាត់) នេះក្លាយពូជមកពីពូជ ហ្វ៊ិនចុងដែលគេទទួលស្គាល់ថាជាអំពិលផ្អែមពូជដ៏ល្អពិសេស ។ ក្លួរធំហើយផ្លែបំផុត ជាប់គេក្នុងបណ្តាពូជអំពិលផ្អែមដែលមាននៅក្នុងប្រទេស ។

លក្ខណៈដើម សំបកមានពណ៌រាងសទ្ធន ស្នាមបែកនៃសំបកល្អិត ។ ស្លឹកធំ ទំរង់គុម្ព ដើមយកជាពិតប្រាកដមិនបាន ពីព្រោះការបែកមែកធាងចេញមកមិនសូវមានរបៀប លក្ខណៈក្លួរខុបធំ ហើយវែង ។ សំបកផ្លែពណ៌សទ្ធន សាច់ក្រាស់ពណ៌ផ្ទចមាស រសជាតិផ្អែមុតឆ្ងាញ់ណាស់ គ្រាប់តូច ផ្សារត្រូវការណាស់ ប៉ុន្តែផ្លែមិនសូវស្មេះទេ ។

ដោយហេតុមកពីអំពិលផ្អែមពូជពណ៌មាស ជាអំពិលផ្អែមជាពូជដែលមានទំរង់គុម្ពដើម មិនទៀងទាត់ ពីព្រោះមានបែកមែកធាងដែលបែកចេញមកមិនមានរបៀបទើបធ្វើ អោយចេញផ្កាយឺតជាងពូជដទៃទៀតដែលតាមធម្មតាចេញផ្កានៅដើមខែឧសភា ប៉ុន្តែ ចំពោះពូជពណ៌មាស និងចេញផ្កាយឺតជាងគ្រាប់ពូជប្រហែល 2-3 ថ្ងៃ ។ បើភ្លៀង ក្រធ្លាក់មកក៏នឹងធ្វើអោយការចេញផ្កាកាន់តែយឺតទៅ ហើយជាពូជអំពិលផ្អែមដែល មានចំណាស់ក្លួរកាន់តែយឺតណាស់ទៅទៀត ព្រោះជាអំពិលផ្អែមពូជធ្ងន់ ។ ផ្លែនឹង ចាស់បេះប្រមូលផលបានប្រហែលនៅចុងខែកុម្ភៈ រហូតដល់ដើមខែធ្នូ ។

5. ពូជខន្តី : ចាត់ជាអំពិលពូជស្រាលថ្នាក់កណ្តាល ។ ដើមស្រដៀងគ្នានិងពណ៌មាស គឺពណ៌សំបករាងវែងមានស្នាមបែកតាមបណ្តោយ ប៉ុន្តែល្អិតជាងពូជពណ៌មាស ទំរង់ គុម្ពដើមស្អុក ហើយមានមែកធាងច្រើនបន្តិចប្រហាក់ប្រហែលគ្នានិងអំពិលផ្អែមពូជ

ទឹកឃ្មុំ ស្លឹកតូចជាងពូជដទៃៗទៀត ហើយស្លឹកញឹក ក្រាស់ ពណ៌ខៀវចាស់ស្រដៀងទៅនឹងស្លឹកអំពិលជូរ ។

លក្ខណៈក្លូរត្រង់ ឬខុបខ្លះបន្តិចបន្តួច បើប្រៀបធៀបទៅនឹងពូជស្រីធុមភ្ន ។ ពូជខន្តីនេះក្លូរខ្លីជាង ប៉ុន្តែគន្លាក់ក្លូរឃើញច្បាស់ជាង ។ ក្លូរធំមធ្យម ទម្ងន់ស្រាល សាច់ពណ៌ត្នោតចាស់ ។ ភាពទន់នឹងភាពផ្អែមនៃសាច់ប្រហាក់ប្រហែលគ្នាទៅនឹងពូជស្រី-ធុមភ្ន ។ ផ្លែច្រើនស្ទែះសមគួរប្រហែលគ្នានិងពូជទឹកឃ្មុំដែរ ហើយមានផ្លែស្ទែះរាល់ៗឆ្នាំ ក្លូរចេញជាប់គ្នាជាចង្កោមៗ ការប្រែប្រួលរបស់ពូជមានតិចគឺអាចផ្លាស់ប្តូរជាតិក្រតស៊ុលហ្វួរិកអោយទៅជាស្ករបានរហ័ស ធ្វើអោយមានក្រួតធ្លាក់ជាប់នៅក្នុងក្លូរតិច ទើបធ្វើអោយមានរសជាតិជូរតិចបំផុតទោះបីក្រធ្លាក់ភ្លៀងមកក៏ដោយ ។ ការខូចខាតរបស់ពូជខន្តីគឺជាស្លឹកតូច ធ្វើអោយទទួលអាហារមិនល្អ ទំហំរបស់ក្លូរទើបខ្លីហើយតូច ហើយរហ័សទុំជាងពូជដទៃៗទៀត ព្រមទាំងជាពូជដែលដង្កូវ កណ្តៀរបំផ្លាញយ៉ាងច្រើនក្រៃលែង ប៉ុន្តែបើមានការចាក់ថ្នាំជានិច្ច បញ្ហានេះក៏ពុំកើតឡើងដែរ ។

6. ពូជឥន្ទផាណាំ : កាលពីដើមឈ្មោះពូជណាងលេ ពីព្រោះកាលពីដើមនោះដើមពូជដាំនៅក្នុងភូមិណាងលេ ស្រុកឡមសាក់ ហើយជាពូជដែលគេបានសន្និដ្ឋានថាអាចក្លាយមកអំពីពូជហ្វៀនចុង ឬពូជប៉ាឌុក ។ បើមានស្នាមបែកសំបកល្អិតៗប្រហែលគ្នា នឹងពូជហ្វៀនចុង ប៉ុន្តែគគ្រើមជាពូជខន្តី ។ ទំរង់គុម្ពដើមមូលរាងបំពង់ គំរោងសាងសង់នៃទំរង់គុម្ពដើមណែន ។ ស្លឹកពណ៌ខៀវចាស់ ធំ ស្តុក ហើយមានរយៈល្មមធ្យម ។ ចុងត្រួយដែលចាប់ផ្តើមចេញមកមានពណ៌ខៀវខ្ចី ខុសពីពូជអំពិលដទៃទៀត ។ លក្ខណៈផ្លែសំប៉ែតរាប រាងមូល ផ្លែត្រង់ ស្តុក ហើយមានមែកធាងច្រើនបន្តិចស្រដៀងនឹងអំពិលផ្អែមពូជទឹកឃ្មុំ ។ ស្លឹកតូចជាងពូជដទៃៗទៀត សាច់មានពណ៌ត្នោតក្រមៅស្អិតបន្តិច រសជាតិស្រដៀងនឹងពូជឥន្ទផាណាំ(រម៉ើ) សាច់ច្រើនជ្រាក មិនស្ងួត



ពូជឥទ្ធផាណាំ

សំខាន់បំផុតគឺចេញផ្កាស្វែះជារៀងរាល់ឆ្នាំ ព្រោះជាពូជស្រាល ដោយមកពីសាច់ផ្លែប ផ្ចិតផ្លែពេរីមកពីសមុទ្រខ្សាច់ បើមានឱកាសនាំចេញទៅលក់នៅឯប្រទេសមជ្ឈិមបូពា បាននោះ ។

7. ពូជចៅហ្វៀសេដ្ឋកិច្ច : កាលដើមឈ្មោះម៉ូតលីប លក្ខណៈជាពូជដែលមានចុង ពណ៌ខៀវខ្ចី សំបកដើម ។ សំបកដើមពណ៌ត្នោតលាយសខ្ចួន ការដុះលូតលាស់របស់ ដើមល្អ ក្បូរស្វែះជាចង្កោមជាប់ក្បូរល្អ សាច់ផ្អែម ស្បែកស្រោបសាច់ស្អិតធ្វើអោយ ពិបាកទំពារបរិភោគ ។ សាច់លាយម្សៅខ្ទិះ ទើបអ្នកខ្លះហៅថាអំពិលផ្អែមខ្ទិះអាច ទុកបេះផ្លែបាន ដោយអង្រួនដើមអោយផ្លែជ្រុះធ្លាក់មកដោយផ្លែពុំបែក ជួយសំចៃ កម្លាំងការងារបេះផ្លែផង ។

8. ពូជឡាំងតែក (ខ្នងបែក) : លក្ខណៈទូទៅនៃអំពិលផ្អែមពូជនេះ ដូចជាពូជមាស គ្រប់យ៉ាង ប៉ុន្តែក្បូរធ្វូចជាងហើយរសជាតិក៏អន់ជាង ពីព្រោះជាពូជដែលក្លាយពូជមក ពីការដាំគ្រាប់ពូជពណ៌មាស ។

លក្ខណៈក្បូរជាចង្កូរប្រហែល 6-7 សង្ទីម៉ែត្រ សំបកក្បូរមានពណ៌ត្នោតលាយឡាជា មួយនិងពណ៌លឿង សាច់ស្តើង មានក្លិនក្រអូប មានរសជាតិផ្អែម សាច់ជ្រាក លក្ខណៈលេចកាលណាកេះសំបកចេញឃើញសាច់អំពិលញែកចេញពីគ្រាប់ ស្រទៀប និងអំពិលទឹក ធ្វើអោយស្រួលបរិភោគ ហើយស្បែកស្រោបគ្រាប់ជុយទំពារបរិភោគ លេបទាំងអស់ក៏បាន ។

9. ពូជពេជ្រក្បូរ : ជាកូនកាត់ពីពូជអំពិលហ្វីនចុង និងពូជអំពិលពណ៌មាសដោយផ្សំ គ្នា ប្រើហ្វីនចុងជាដើមឪ ពណ៌មាសជាដើមម៉ែ ទំរង់គុម្ពដើមទូលាយមែកវែងជាង ដៃ ពណ៌ចុងត្រួយក្រហមស្រគាំ ស្លឹកមានលក្ខណៈស្រដៀងនិងពណ៌មាសពីស្លឹកធំ

មានពណ៌ខៀវខ្ចី ជាអំពិលដែលមានលក្ខណៈពិសេស គឺគួរជាប់ដេញពីគល់ទៅរកចុងដើម មិនដូចអំពិលផ្អែមពូជដទៃទៀតទេដែលភាគច្រើនជាប់ចំពោះជាយគុម្ពដើមខាងក្រៅ ចំណែកគល់ខាងក្នុងមិនជាប់ទេ ហើយការចេញផ្កានៃពូជពេជ្រក្សត្រចេញផ្កាដេញពីគល់មែក ធ្វើអោយការរីកសាយរបស់គួរល្អ មិនចាប់គ្នាជាពួកចង្កោមដែលលក្ខណៈបែបនេះធ្វើមិនអោយមានការដណ្តើមចំណីអាហារគ្នា និងធ្វើអោយទំហំគួរស្មើប៉ុនៗគ្នា ព្រោះអាហារដែលបញ្ចូលមកអោយគួរក៏ទទួលបានស្មើគ្នាៗគ្រប់គួរ ដែលជាលក្ខណៈដ៏ល្អប្រចាំពូជនេះ សាច់របស់ពេជ្រក្សត្រមានរសជាតិដូចជាហ្សិនចុងប៉ុន្តែសាច់ស្វិតជាង ហើយមានពណ៌ក្រហមជាង គួរដូចហ្សិនចុងប៉ុន្តែលាតជាងបន្តិចបន្តួច គំរោងសាងនៃសំបកក្រាស់ល្មមគ្នានឹងហ្សិនចុង ប៉ុន្តែសំបកចាប់ណែនជាងធ្វើអោយគួរបែកតិចជាង ការចេញគួរច្រើនស្ទេះស្មើគ្នារាល់ឆ្នាំ ផលិតផលល្អជាងពូជហ្សិនចុង និងពណ៌មាស ។

លក្ខណៈចំពោះពូជពេជ្រក្សេត្រគឺមានបរិមាណស្លឹកតិច ហើយទំរង់គុម្ពដើមទូលាយពពាក់ពពូនគ្នា ។ កាលដែលមានស្លឹកតិចធ្វើអោយផលិតផលអាហារចេញមកចិញ្ចឹមគួរមិនបានពេញលេញ ដូចនេះកាលណាគួរច្រើនស្ទេះពេកគួរក៏ល្អិត ក្រៅពីនេះពូជពេជ្រក្សត្រកាលណាយកទៅដាំកន្លែងដែលមានទឹកច្រើនមិនសូវល្អ ជាពិសេសនៅក្នុងតំបន់ភូមិភាគកណ្តាល ត្រូវដាំលើករងកុំអោយទឹកដក់រលួយឫស ពីព្រោះបើទឹកដក់ត្រាំឫស ឫសនឹងងាប់ ។ រដូវភ្លៀងត្រូវពូនដីគល់ ពីព្រោះបណ្តាលកើតមានរោគផ្សិតបំផ្លាញ និងរោគរលួយឫស ។ ដូចនេះជាការសមស្របក្នុងការដាំនៅលើដីខ្ពស់នៅភាគឧត្តរ និងភាគឦសាន្តយ៉ាងច្រើន ។

10. <u>ពូជប៉ាកខុក</u> : ពូជប៉ាខុកជាឈ្មោះឃុំមួយនៃស្រុកឡមសាក់ ខេត្តពេជបូរណ៍ ជាពូជដែលក្លាយមកអំពីគ្រាប់ដាំ ។ លក្ខណៈស្លឹកតាមធម្មតាមិនធំដូចជាពូជហ្សិនចុងទេ គួរមានទំហំធំត្រង់ច្រើនជាងពូជដទៃៗទៀតស្រដៀងនឹងពូជឥន្ទផាណំ(រម៉ុ) ប៉ុន្តែខ្ចីជាង

ខាងក្នុងជាទ្រនង់មើលឃើញច្បាស់ សំបកមានពណ៌ឆ្នោតក្រហម ឬមានពណ៌ឆ្នោតប្រផេះ រសជាតិផ្អែមស្រដៀងនិងពូជឥន្ទណាំ ប៉ុន្តែសាច់មិនស្អិតដូចជាពូជឥន្ទណាំទេ គឺមានរាងល្ហុះជាង គ្រាប់ធំ ផ្លែវែងច្រើនប្រហែលគ្នានឹងពូជស្រីឆុមភូ ប៉ុន្តែចាញ់ពូជខន្តី និងពូជឥន្ទផាណាំមនុស្សមិនសូវជាស្គាល់ច្រើន តែមានលក់ក្លែងក្លាយថាជាពូជឥន្ទណាំ ។

11. <u>ពូជពានព្រះរាជទ័</u> : អំពិលផ្អែមពូជពានព្រះរាជទ័ ជាអំពិលផ្អែមពូជមួយដែលផ្លែអោយមានផ្លែអោយចាប់អារម្មណ៍ខ្លាំង លក្ខណៈទ្រង់ទ្រាយគុម្ពដើមមាំមួន ឆាប់ធំប្រហែលគ្នានឹងពូជឥន្ទណាំ ចុងពណ៌ខៀវខ្ចីបែបឥន្ទណាំគ្រាន់តែស្លឹកតិចជាង គឺស្លឹកស្រឡះ ថ្នាំងឃ្លាតពីគ្នា សំបកដើមគគ្រើម មានពណ៌ក្រមៅជាង ។ កាលដែលមានលក្ខណៈស្លឹកច្រើនធ្វើអោយចិញ្ចឹមផ្លែបានច្រើនជាផ្លែវែងរាល់ឆ្នាំរហ័សទុំ ផ្លែធំក្រអប់ប្រហាក់ប្រហែលគ្នានឹងពូជឥន្ទផាណាំ ផ្លែត្រង់ ភាគច្រើនខុបខ្លះជាប់ផ្លែជាចង្កោមបើដើមមាំមួនល្អបរិបូរណ៍ក៏មានផ្លែវែងៗចេញលក់បានព្រមជាមួយគ្នានឹងពូជទឹកឃ្មុំ ។ គំរោងសាងសំបកគួរល្អ ។

ក្រៅពីពូជអំពិលផ្អែមដូចបានពោលមកខាងលើនេះ នៅមានពូជផ្សេងៗទៀតនៅក្នុងប្រទេសជាច្រើនដែលពូជអំពិលផ្អែមនីមួយៗនៅមានប្រវត្តិកំណើត កើតមកមិនទាន់ដឹងច្បាស់ពិតប្រាកដ ហើយនៅគ្មានលក្ខណៈលេចច្បាស់នៃពូជច្រើនណាស់ណោះទេ ទើបសុំនិយាយតែត្រឹមពូជតទៅនេះ :

ពូជថៃមហុម មហាចរុណា គ្រឥន្ទ ផៃយ៉ៃ ហុនប៉ៀក ណាស៊ិន្ទន ទួនណាយ តានធិប ខ្ទិបាំង ហ្វាកលើយ ឃុនសាប់ គ្រូឬផាន់ គ្រូសេន ណាយសាយ ណាងប៉ៀង ណាយប៉ៀក ណាយស្វាត់ ពានណាកែ ណាណុកខោ ពានសុំប៉យ ណាសូក រារិ ។

ការពង្រីកពូជអំពិលផ្អែម

អំពិលផ្អែម ឬអំពិលជូរត្តិចាប់តាំងពីបុរាណកាលមក គេនិយមពង្រីកពូជដោយការដាំគ្រាប់ ដែលស្ថិតនៅពូជដើមខ្លះបានល្អខ្លះ ឬអន់ជាងឪម៉ែខ្លះ ។ មានក្លាយពូជបណ្តាលបានមកពីពូជថ្មីៗខ្លះ គឺបើសិននៅល្អក៏នាំគ្នាយកគ្រាប់ទៅដាំទៀត ឬដំណាមកក៏មានការនាំគ្នាសាកខ្លះ នាបច្ចុប្បន្នកាលនេះគេនិយមពង្រីកពូជដោយវិធីបំបៅមែកកាន់តែច្រើនជាងវិធីដទៃទៀត ។

ការពង្រីកពូជដោយដាំគ្រាប់ : យកគ្រាប់មកដាំក្នុងរណ្តៅដែលប្រើស្បែង ឬឈើស្រួចបុកទៅក្នុងដីអោយកើតជារន្ធដាក់តែមួយគ្រាប់ល្មម ។ កាលណាភ្លៀងធ្លាក់ក៏បានទទួលសំណើមគ្រប់គ្រាន់ គ្រាប់ក៏ចាប់ផ្តើមដុះចេញជាដើមចំរើនលូតលាស់តទៅ ឬម្យ៉ាងទៀតប្រើចបជីករណ្តៅរាក់ៗទម្លាក់គ្រាប់ទៅក្នុងរណ្តៅ រួចលុបដីក៏បាន ។ សម័យសព្វថ្ងៃនេះគេនិយមដាំគ្រាប់ក្នុងថង់ប្លាស្ទិក ។ កាលណាដើមដុះបានកំពស់ 30 សង្ទីម៉ែត្រ ក៏យកទៅដាំក្នុងចំការក៏ប៉ុន្តែដោយមកពីការក្លាយពូជបានងាយទើបគេនិយមបណ្តុះកូនហើយ ក៏យកទៅបំបៅនឹងពូជដុងល្អ វិធីនេះបានត្រឹមត្រូវតាមពូជដើមមិនក្លាយ ។

ការពង្រីកពូជដោយការសាក : សម័យដើមសាកមែកដែលមានពណ៌ត្នោតហើយ សម័យឥឡូវនេះសាកមែកខៀវដែលមានទំហំធំល្មម មិនងាយបាក់ទោះបីជាមានស្លឹកជាប់នៅ ក៏អាចបេះស្លឹកខៀវត្រង់នោះចេញ ។ ឈ្វៀលយកសំបកអំពិលជុំវិញកន្លែងបកសំបកអោយអស់ យកទឹកថ្នាំដូនណូហ្សិកតាមអត្រាក្នុងសៀវភៅក្បួន ឬលាបសេរ៉ាឌិកលេខ 2 រួចហើយយកស្រកីដូង និងជីរុំថង់ប្លាស្ទិកចងផ្តោបរិតអោយណែនជាកំប៉ុក ចោះរន្ធអោយទឹកភ្លៀងចូល ឬស្រោចទឹកងាយសើម។ មិនយូរក៏ដុះឫសដូចគ្នានិងស្វាយ ហើយនិងខ្នុរ ។ សព្វថ្ងៃនេះមានគេនិយមតិចណាស់ ។ សម័យថ្មី 100% ធ្វើមែកចេញលក់ដោយបំបៅមែក ។





របៀបតមែកអំពិល

ការពង្រីកពូជដោយបំពៅមែក : គោលការណ៍គឺមែកពូជល្អមកដាំក្នុងថ្នាលពង្រីកពូជ ធ្វើការថែទាំរក្សាអោយមានកំពស់កុំអោយខ្ពស់ពេក អោយល្មមសមរម្យដែលអាចងាយធ្វើការបានស្រួល ពីព្រោះយកកូនក្នុងថង់ឡើងទៅបំពៅ ចងរឹបមែកនិងថង់ទៅនឹងឈើការពារកុំអោយខ្យល់យោគរង្គើ ។ ប្រហែលមួយខែក៏កាត់យកមកផ្សាំបាន ។

អំពិលផ្អែមជារុក្ខជាតិប្រើប្រព័ន្ធដកកូនដាក់ថង់ ហើយនាំឡើងទៅបំពៅតាមបែបស្វាយពុំបានទេវានឹងងាប់អស់ជីវិតតែម្តង ពីព្រោះសាច់ក្រជុះជាប់គ្នា ។ ចុងបញ្ជូនទឹកនិងអាហារពេចិញ្ចឹមដើមគល់របស់កូនមិនស្រួលបណ្តាលអោយដើមគល់ងាប់ ។ ទើបត្រូវបណ្តុះដាំ ឬចិញ្ចឹមក្នុងថង់រហូតអោយបានទំហំប៉ុនខ្មៅដៃក៏យកទៅបំពៅបាន ។ រយៈពេលដែលសាច់នៅពុំទាន់ជុះជាប់គ្នានោះ ដើមគល់កូនក៏ត្រូវអាស្រ័យទឹក និងអាហាររបស់ឫសខ្លួនឯងទើបរស់នៅបាន ហើយនៅតែមករហូតពេលសាច់ជុះជាប់គ្នា ។ កូនផ្លុសល្អបរិបូរណ៍បំពៅជាប់ជុះសាច់ជាប់គ្នាបានងាយជាងដើមដែលចាស់រឹង ហើយអាយុច្រើន ។



ដើមកូនអំពិលផ្អែមដាក់ក្នុងថង់ផ្សាំ

វត្ថុដែលប្រើផ្សាំកូនគឺដី 1 ភាគ ជីផ្តាប់ 1 ភាគ ឬផេះអង្កាម 1 ភាគ ឬប្រើតែដី និងជីផ្តាប់ក៏បាន យកមកច្របល់លាយគ្នាហើយយកមកច្រកក្នុងថង់ប្លាស្ទិកខ្មៅ ចោះរន្ធអោយទឹកហូរចេញ ។ យកគ្រាប់អំពិលផ្អែមត្រាំទឹកក្តៅហើយមួយយប់ កប់ទៅក្នុងថង់ជំរៅប្រហែល 2-3 សង្ទីម៉ែត្រ ឬជំរៅ 4 ដងនៃកំពស់គ្រាប់ ។ ស្រោចទឹកអោយសើមជោគ ដាក់ជីគីមី 15-5-20 + 2 ស្រោចទឹកអោយសើមជានិច្ច ហើយបាញ់ស្លឹកដោយប្រើរូបមន្តជីបម្រែបម្រួលមិនចំនួន 1 តំរបដប 50 មិល្លីក្រាម លាយអ៊ុយរេ (UREA) 10 ក្រាម អ៊ុយនិលេត 5 ក្រាម នៃគ្រាន់ស៊ុអេសប្រាំពីរ 3 សេសេ និងលាយទឹក 20 លីត្រ ។ ការដាក់ជីបង្ហំបែបនេះនឹងធ្វើអោយកូនអំពិលថ្លុសធំ មាំមួនឆាប់ធំ អាចយកទៅបំពៅបានឆាប់រហ័ស ។ ចំការខ្លះបណ្តុះកូនដាំ 3 ដើមក្នុងមួយរ៉ៃ ហើយដកចោលទុកូនអន់ 2 ដើម នៅពេលក្រោយ ប៉ុន្តែឥឡូវនេះភាគច្រើនគេបណ្តុះមួយថង់ក្នុងមួយដើមប៉ុណ្ណោះ ដែលល្អមជុំវុញអោយជីទាំងតាមដី និងតាមស្លឹកក៏ល្អមប្រើបាន ។

មើលថែទាំកូនអោយបានល្អ មាំមួន បរិបូរណ៍ ។ ក្នុងរយៈពេលនេះបើបង្ហំអោយកូនធំធាត់ក៏អាចក្តិចត្រួយចោលខ្លះម្តងម្កាល ។ លុះអាយុបាន 5-6 ខែ និងបានទំហំប៉ុនបំពង់បិតកាហ្វេ ឬប្រហែល 5 មិល្លីម៉ែត្រក៏អាចបំពៅបាន ។

រយៈពេលដ៏សមស្របក្នុងការបំពៅមែកអំពិលផ្អែម ដើម្បីអោយបានផលល្អគួរជ្រើសរើសយកការបំពៅក្នុងរដូវភ្លៀង ។ ការជ្រើសរើសមែកពូជល្អដែលនឹងយកមកជាមេពូជ គប្បីជ្រើសរើសមែកដែលមានលក្ខណៈល្អ គ្មានបែកខ្នែងស្តេសស្តាសហួសពេក ជាមែកដែលធាត់ថ្លុស គ្មានរោគ ឬគ្មានសត្វបៀតបៀន ជ្រើសរើសបំពៅចំពោះមែកដែលនៅជាយៗទំរង់គុម្ពដើមប៉ុណ្ណោះ ទើបធ្វើអោយការបំពៅបានផលល្អពីព្រោះមែកដែលបំពៅនៅតូចមានពណ៌ខៀវចាស់ ពណ៌ត្នោត ស្ថិតនៅក្នុងចន្លោះពេលចំរើនលូតលាស់ធំធាត់នៃសាច់ឈើ ប៉ុន្តែបើជ្រើសរើសបំពៅមែកដែលមានទំហំធំហួសពេកចូលមកក្នុងចន្លោះខាងក្នុងនៃ

ដើបឱកាសក្នុងការបំពៅមែកអោយបានផល ក៏ថយចុះជាដីរាបតាមទំហំមែក ពីព្រោះអត្រាការចំរើនលូតលាស់នៃសាច់ឈើនិងថយចុះទៅតាមដែរ ។

មុននឹងបំពៅត្រូវកាត់ចុងដើមគល់ចេញអោយសល់គល់ដើមប្រវែង4-5ធិវ(1-1 សង្ទីម៉ែត្រ) ប្រើកាំបិតពង្រីកពូជ ឬកាំបិតមុតៗវាសដើមទាំងពីរដាច់ចេញជាត្រណាប់ស៊ក ចំណែកមែកពូជល្អក៏វះបញ្ជៀតឡើងចូលទៅក្នុងសាច់ឈើបន្តិចប្រវែងប្រហែល 1 និវកន្លះ (3.9 សង្ទិ-ម៉ែត្រ) អោយមានលក្ខណៈត្រូវគ្នានិងស្នាមវះដើមគល់ដែលត្រៀបទុក រួចហើយយកដើមគល់ស៊កបញ្ចូលទៅ ដោយចាក់អោយសំបកមែកទាំងពីរគ្រប់ជិតជល់គ្នាបានល្អ ។ ក្នុងករណីដែលមិនអាចចាត់អោយជិតជាប់គ្នាបានគ្រប់ជាននោះ ត្រូវចាត់ជ្រើសរើសយកជានខាងណាមួយអោយជិតគ្នា ដើម្បីអោយសាច់ឈើដុះផ្សារភ្ជាប់គ្នាបាន ។ យកផ្លាស្ទិករុំអោយជុំពិតស្នាមដំពៅដោយរុំពីជានក្រោមឡើងលើ ហើយរិតអោយតឹងណែន រួចពោះបង្គោលឈើចងខ្សែថង់ដើមគល់ទុកអោយជាប់នឹងល្អ កុំអោយខ្យល់យោគរង្គើបាន ។

ទោះជាយ៉ាងណាក៏ដោយ ក្នុងការបំពៅមែកអំពិលក្នុងលក្ខណៈបែបនេះវាអាចមានបញ្ហាដោយប្រការណាមួយ ដោយមកពីអំពិលជាឈើសាច់រឹង មានទំហំខ្ពស់ពិបាកធ្វើក្នុងការពង្រីកពូជ បើនាំយកកូនឡើងទៅបំពៅលើដើមមេដែលខ្ពស់ ទោះបីធ្វើបានក៏មិនស្រួលក្នុងការស្ទូរឡើង ការរកទិការពារខ្យល់យោគ ការផលិតមែកបំពៅចេញមកលក់ក៏អាចធ្វើបានតិច ។ កសិករចំការអំពិលផ្អែមទើបនាំយកមែកពូជល្អមកដាំជិតៗគ្នា អាចឃ្លាតពីគ្នាត្រឹមកន្លះម៉ែត្រក្នុងមួយដើម ហើយមួយជួរឃ្លាតគ្នា 2 ម៉ែត្រ រង់ចាំបំពៅចុងមែកដែលមានកំរិតកំពស់ 1.50 ម៉ែត្រ រួចហើយបែកមែកថ្មី បំពៅថ្មី ដូចនេះរហូតទើបដើមមេពូជស្ថិតនៅទាបបែកចុងថ្មីរហូត ។







លក្ខណៈស្នាមវះលើមែកពូជល្អ



លក្ខណៈស្នាមវះដើមគល់





លក្ខណៈនៃការស៊កដើមគល់ចូលទៅជាមួយមែកពូជល្អ និងការរុំស្នាមបំពៅ

វិធីនេះទើបជាវិធីស្រួលក្នុងការផលិតមែកបំពៅចំនួនច្រើន ។ ការដោតឈើជុំវិញដើមសំរាប់ចងរឹតប្រពោងមែកបំពៅក៏ធ្វើបានងាយស្រួលផងដែរ ។ ការជុំវិញដើមមេពូជអោយបែកមែកថ្មីដែលថ្លុសអោយទាល់តែជាប់ងាយនោះ ក៏ត្រូវដាក់ជីដី និងស្លឹកដូចគ្នានិងការជំរុញដើមកូនអញ្ចឹងដែរ ។

បន្ទាប់ពីបំពៅហើយត្រូវស្រោចទឹកដើមគល់អំពិល ប្រហែលមួយអាទិត្យម្តងប្រហែល 4-5 អាទិត្យ ស្នាមដំពៅវះក៏និងជាប់គ្នាល្អ ។ មុនកាត់ត្រូវប្រើកាំបិតលោក់មែកពូជត្រង់គល់មែកក្រោមស្នាមវះដើម្បីដាស់ ដើម្បីត្រៀមកាត់មែកចេញពីដើមមេ ។ ក្រោយពីការលោក់ដាក់មែកទុកហើយ 7-10 ថ្ងៃ ទើបកាត់ចុះមកផ្សាំត្រៀមទុកលក់ ឬដាំតទៅ ។



បញ្ហាទូទៅនៅក្នុងការផ្សាំអំពិលផ្អែមនេះ ភាគច្រើនកើតអំពីមេរោគផ្សិតនៅក្នុងថ្នាលផ្សាំ ដោយមកអំពីថ្នាលផ្សាំបណ្ដុះ មានពួកពិណាជាតិគីដើមពិណាជាតិដុះក្រាស់ណែនងាយកើតរាលដាលនៃមេរោគផ្សេងៗ ជាពិសេសគឺមេរោគផ្សិតនៅក្នុងដីអាចស៊ីត្រង់កគ្គិលនៃដើមកូន (ស្នាមពរវាំងក្នុងដី និងអាកាសបរិវេណសើរដី) ក្នុងករណីនេះត្រូវបាញ់ថ្នាំថីរ៉ាក់គួស្វប៉េរ លាយត្រីពាន់ស៊ីអេស 7 តាមអត្រាចែងនៅក្នុងស្លាក ។ រោគផ្សិតដែលជួបប្រទះញឹកញាប់នៅក្នុងអំពិលនោះ គឺផ្សិតម្សៅស៊ីស្លឹកកើតអំពីអំពិលទន់ខ្សោយ ពីព្រោះខ្វះធាតុកំបោរ ឬខ្វះធាតុកាល់ស្យូម ។ ការផ្សំដីដាំថ្លូឡូមិត និងដីកំបោរហ្វូសហ្វាតផ្សំរួមផង ។ បើចាំបាច់ត្រូវចាក់កាល់ស្យូមអ៊ុយនិលេត 2 ស្លាបព្រាកាហ្វេ ទ្រីពាន់ស៊ីអេស 7; 3 សេសេ លាយទឹក 20 លីត្រ អោយដើមមាំមួនឡើង ហើយបាញ់សារៈធាតុបំបាត់មេផ្សិតម្សៅដូចជាកាលិស៊ិនសាទ្រល់ បេនលេទអូឌី បេនថក្ស អាហ្វ៊ីកាន ជាដើម ។ ប៉ុន្តែបើដាក់ដើមកូនចូលទៅក្នុងបួយថង់ៗ ឃ្លាតពីគ្នាបន្តិចក៏អាចបន្ថយសំណើមចុះ ការរាលដាលនៃមេផ្សិតក៏ថយចុះដែរ ។

ចំពោះសត្វល្អិតនៅក្នុងថ្នាលពន្លកពូជនោះអាចមានស្រមោច មេស៊ីឈើ ដង្កូវ ខ្មូង បំផ្លាញម្លូងម្ដាល ។ ប្រើសារៈធាតុគីមីដែលមានក្លិនខ្លាំងដូចជា សូឡូន ធីអីដាន ដើម្បីបណ្ដេញក៏មានប្រសិទ្ធិភាព ឬក្លិនអន់ថយរហើយន្តិចៗបានច្រើនថ្ងៃដេញសត្វល្អិតក្នុងដី និងតាមស្លឹកបានល្អដូចជា ឡូសបែន 20 EC. និងអែកថេលិកមានប្រសិទ្ធិភាព ។ តាមធម្មតាសត្រូវទាំងនេះមានចំនួនតិច ប្រើកាលណាចាំបាច់តែប៉ុណ្ណោះ ។

## ការជ្រើសរើសកន្លែងដីដាំ

ការធ្វើចំការអំពិលផ្អែមជាការដាក់ទុនដែលយូរអង្វែង ។ ការជ្រើសរើសកន្លែងដីដែលត្រូវយកមកធ្វើចំការ ទើបមានសារៈសំខាន់ក្រៃលែងពីព្រោះកន្លែងដាំជាបច្ច័យសំខាន់ដល់ផលិតផល ។ ផលដែលនឹងបានទទួល ទោះបីកន្លែងដីដាំមានដីមិនល្អក៏ល្មមអាចកែច្នៃដីអោយល្អបាន ប៉ុន្តែការបង្កើនសាហ៊ុយចាយវាយក្នុងការចុះទុនទៀត ។ ដូចនេះក្នុងរឿងជ្រើសរើសទីកន្លែងដីដាំគប្បីជ្រើសរើសកន្លែងដីអោយបានសមស្រប ទើបបានស្មើនិងផលចំណេញចាប់តាំងពីពេលផ្តើមធ្វើចំការមក ។

ការជ្រើសរើសទីកន្លែងធ្វើចំការក្នុងកន្លែងមូលដ្ឋាន ដែលមានធ្វើចំការឈើហូបផ្លែនៅស្រេចទៅហើយ ក៏រមែងអោយដឹងអំពីការអនុវត្តន៍ ការរក្សាថែទាំដើមពេលអំពីអ្នកចំការក្នុងមូល-ដ្ឋាននោះ នោះរហូតទៅដល់ការស្រួលដីទៃៗទៀត ។

កន្លែងដីដែលដាំអំពិលផ្អែមនោះត្រូវមានដីទួលខ្ពស់ ទឹកជំនន់មិនដល់ ផ្ទៃដីរាប ឬក៏ជំរាលទេរបន្តិចបន្តួច ជាដីធូរ មានឥន្ទ្រិយវត្ថុខ្ពស់ (Organic matter) មានមុខដីជ្រៅកើតទឹកក្នុងដីមធ្យម ។ ទោះជាយ៉ាងណាក្តីអំពិលផ្អែមជារុក្ខជាតិជំហរ ដែលមានភាពរឹងប៉ឹងធន់រាំងស្ងួត ធន់និងទឹកជំនន់បានល្អ លើកលែងតែឆ្នាំដំបូងកុំអោយទឹកជន់ បើអាចដាំអំពិលផ្អែមបានគ្រប់ភូមិភាគនៅក្នុងប្រទេសថៃឡង់ដ៏ (ភូមភាគខាងត្បូង អាចមិនសមស្រប ពីព្រោះភ្លៀងធ្លាក់ជោគជាំខ្លាំងពេក ប៉ុន្តែដាំបានដូចគ្នា) ដាំបានគ្រប់កន្លែងទោះបីជាដីទំនាប ដីទួលលើភ្នំ ។ បើជាដីទំនាបត្រូវធ្វើការបញ្ចៀញទឹកក្នុងរយះពេលដែលអំពិលផ្អែមកំពុងទុំ ពីព្រោះបើដើមអំពិលផ្អែមទទួលទឹកច្រើនក្នុងរយះពេលដូចបានពោលមកហើយនោះ អាចធ្វើអោយរសជាតិផ្អែមខ្សោយ អន់ផ្អែម ដោយមកអំពីជាតិស្ករត្រូវបំផ្លាញដោយអេនសៃម៏អ៊ុជ្រូលេសដែលធ្វើការកាលណាមានទឹកជុំវិញច្រើន ។

ក្រៅពីរៀងទឹកខ្លែងដាំហើយ មូលដ្ឋានជាបច្ច័យធ្វើអោយមានភាពងាយស្រួលផ្សេងៗក្នុងការដែលនឹងទៅប្រកបកិច្ចការជំនួញ ដូចជាផ្លូវថ្នល់ អគ្គិសនី រយៈផ្លូវជិត ឬឆ្ងាយអំពីក្រុង និងផ្សារច្រើនប៉ុណ្ណា ។ បើចំការនៅជិតមជ្ឈដ្ឋាននៃប្រជាករច្រើន (ជិតផ្សារ) រមែងធ្វើអោយមានប្រៀបជាងចំការដែលស្ថិតនៅទីកន្លែងឃ្លាតឆ្ងាយ ដែលត្រូវធ្វើការដឹកជញ្ជូនផលិតផលតាមរយៈផ្លូវឆ្ងាយ ហើយក្រៅពីនេះនៅមានប្រៀបក្នុងរឿងផ្លូវគមនាគមន៍ស្រួលជាង មានការដឹកជញ្ជូនងាយស្រួលព្រោះនៅជិតផ្សារ ។

<u>សភាពធាតុអាកាស</u> : អំពិលផ្អែមចូលចិត្តភាពហួតហែងក្នុងរដូវក្តៅ ហាក់បីដូចជាមានការសំរាកការដុះលូតលាស់គឺអោយហួតហែងច្រើនបន្តិច ។ លុះចាប់ផ្តើមចូលរដូវភ្លៀងក៏អោយបានចទួលទឹកពេញលេញ អំពិលផ្អែមក៏បែកត្រួយចេញផ្កាសំបើម ។ កាលណាជាប់ក្ងរហើយត្រូវនិងរដូវភ្លៀងក៏នឹងចិញ្ចឹមក្ងរបានយ៉ាងស្រួលរហូតរដូវភ្លៀង ។ ចុងឆ្នាំកាលណាចាប់ផ្តើមចូលរដូវរងារក្ងរអំពិលចាប់ផ្តើមមានជាតិផ្អែម ។ បើធាតុអាកាសមានសំណើមខ្លាំង ឬមានភ្លៀងធ្លាក់និងកើតមេរោគផ្សិតចូលស៊ីសាច់អំពិលផ្អែមទាល់តែរស់រលីង ដូចដែលមានកើតនៅក្នុងភូមិភាគខាងត្បូងដែលមានភ្លៀងធ្លាក់ក្នុងរដូវរងារ ពីព្រោះខ្យល់ត្រជាក់បក់ឆ្លងកាត់ពព្រងសមុទ្រថៃឡង់ដ៏ ក៏នាំចំហាយទឹកទៅផង ហើយក៏បណ្តាលអោយភ្លៀងធ្លាក់កាលណាប៉ះដង្កិចប្រាំងបណ្តាលអោយក្ងរអំពិលកើតមេផ្សិតស៊ីទាំងអស់ កាលណាចូលរដូវរងារគួរតែធាតុអាកាសហួតហែងរហូតដល់រដូវរងារ និងរដូវហួតហែង ។ ដូចនោះនៅភូមិភាគឧត្តរនិងភូមិភាគព្យសាន្ត និងភូមិភាគកណ្តាលទើបអាចកែប្រែកៃផ្ទៃនៅលើផ្ទៃដីស្រែអោយដាំអំពិលផ្អែមបាន ។

## ការត្រៀមរៀបចំដី

ក្នុងការត្រៀមរៀបចំដីក្នុងដីណាក់ការដំបូង គឺគួរត្រឡប់ដីដើម្បីបំបាត់ពិណាជាតិស្មៅ និងកំចាត់ពងសត្វល្អិតផង ។ ហាលដីទុកប្រហែលមួយអាទិត្យ ហើយភ្ជួរលើកទីពីរដើម្បីធ្វើអោយដីរាបស្មើល្អ ។

ចំពោះការដាំអំពិលថ្លែមលើដីទំនាប ដែលមានបរិមាណទឹកក្នុងដីខ្ពស់ និងក្នុងចន្លោះពេលរដូវភ្លៀង និងទឹកជន់ ។ ដូចនេះត្រូវលើករងលើភ្លឺព័ទ្ធជុំវិញអោយជំមាំ អាចការពារទឹកជំនន់ជំពាន ។ សម័យនេះត្រូវការអោយជំអោយរថយន្តមួយបាំង (Pick-up truck) បើកបរដើរលើពានដើម្បីប្រើដឹកជញ្ជូនដីតាមទូក ។ ក្នុងចំការត្រូវចាក់អោយជាភ្លឺរងទទឹង 7 ម៉ែត្រ ប្រឡាយទឹក ទទឹង 3 ម៉ែត្រ ជំរៅ 1 ម៉ែត្រ ដើម្បីប្រើទូកក្នុងទឹកបានស្រួល ទាំងការដឹកជញ្ជូនដី បន្លែ ទាំងគ្រឿងប្រដាប់ប្រដារបាញ់ថ្នាំ ។ តាមការពិតក៏វាដូចជាការលើករងធ្វើចំការបន្លែអញ្ចឹងដែរ ។

កាលណាចាក់ដីលើករងហើយក៏ហាលថ្ងៃ ។ តពីនោះក៏បាចកំបោរដើម្បីបំបាត់ធាតុក្រូចហើយបន្ថយដីឥដ្ឋ ។ កំបោរអ្វីក៏ប្រើបានទាំងអស់ មិនថាកំបោរស កំបោរសំបកខ្យងថ្មកំបោរកិនហ្មត់ ផងថ្មកែវ កំបោរម៉ារ៏ល ថ្មរលួយក្នុងរអាងភ្នំ កំបោរហ្វូសហ្វាត និងដូឡូម៉ៃផង់ ។ បើតម្លៃមិនថ្លៃហួសពេកទេក៏ប្រើពីរប្រភេទខាងក្រោយ មួយប្រភេទកណ្តាលក៏និងមានប្រសិទ្ធិផលខ្លាំងណាស់ ។ មុនពេលបាចកំបោរត្រូវយកគំរូដីត្រួតពិនិត្យវាស់ធាតុក្រូចក្សង មើលតារាងធៀបតម្លៃ pH ប្តូរទៅជាការប្រើកំបោរម៉ារ៏លថាមួយរ៉ៃប្រើអស់ប៉ុន្មានគីឡូក្រាម យកតម្លៃនេះមកប្រើជាប្រភេទកំបោរហ្វូសហ្វាត និងដូឡូម៉ៃធ៍មួយយ៉ាងកន្លះបាន ដែលនៅក្នុងការដាក់ដំបូងអាចនឹងដល់ក្នុងមួយរ៉ៃ ច្រើនរយរហូតដល់ពាន់គីឡូក្រាមក៏បាន ស្រេចតែទៅលើដីថារប៉ុន្មានៗ ។





ចំពោះដីផ្ទៃរាបស្មើ ដែលទឹកស្ងួតយ៉ាងលឿន គេត្រូវដាំនៅលើជួររងខ្ពស់ បើដីភាគច្រើនជាប្រភេទដីល្បាយ ។

ចម្ងាយដាំ

ចម្ងាយដាំអំពិលផ្អែមអាចខុសៗគ្នា ទៅតាមគោលបំណងនៃការដាំ ធម្មតាអំពិលផ្អែមអាចដាំបានក្នុងចម្ងាយ ៦ x ៦ ម៉ែត្រ ។ គោលការណ៍ដែលគួរចាំទុក គឺដាំចម្ងាយឲ្យល្មមដល់ពេលដែលដើមធំពេញលក្ខណៈហើយ មែកមិនជាន់គ្នា ។

ចិន្តនាបដីផ្លូវខ្លាំង បើដីករណ្តៅហើយដាំក្នុងរណ្តៅ និងកើតមានបញ្ហាប្រសរឡើរ ធរ់រ
រលួយតាមមកផ្ងចរុក្ខជាតិដីទៃទៀតអីចឹងដែរ ។ យកល្បពូនដីត្រង់ចំណុចដែលដាំ រហ៊ើពេដាំ
ចុះលើគោកនោះ មួយបែបទៀតដែលគេនិយមច្រើនគឺធ្វើអោយខ្នងរងខ្ពង់បែបខ្នងអណ្តើក
ពេលភ្លៀងធ្លាក់ ឬស្រោចទឹកហើយ ទឹកមិនដក់ និងអោយអំពិលរឹងមាំមូនល្អ ។

<u>រយៈចន្លោះដាំ</u>

រយៈចន្លោះដាំអំពិលផ្អែមអាចខុសផ្សេងៗគ្នា ទៅតាមវត្ថុបំណងក្នុងការដាំ និងដីក្នុងថ្នាលដាំ អំពិលផ្អែមដែលជាមែកបំបៅ ភាគច្រើនដើមទាប ទំរង់គុម្ពដើមទូលាយ ។ រយៈពំងាយដាំ គប្បីអោយឃ្លាតពីគ្នារវាង 6 x 6 ម៉ែត្រ 12 x 12 ម៉ែត្រ ។ ការដែលប្រើរយៈចម្ងាយ ប៉ុន្មាននោះស្រេចតែទៅលើលក្ខណៈរបស់ដី ទំរង់គុម្ពអំពិលផ្អែមនៃពូជនិមួយៗ ។ ភាគច្រើនកសិករចំការខេត្តពេជ្របូរណ៍ប្រើរយៈឆ្ងាយពីគ្នា 10 x 10 ម៉ែត្រ រីឯកន្លែងដទៃៗទៀតអាចពិចារណាបានដូចតទៅនេះ :

① រយៈចម្ងាយដាំតាមគុណភាពដី (ក) លក្ខណៈផ្ទៃដីឧត្តមសម្បូរណ៍ដីល្អ គប្បីប្រើរយៈដាំឃ្លាតពីគ្នា 10 x 10 ម៉ែត្រ ឬ 10 x 12 ម៉ែត្រ (ខ) លក្ខណៈផ្ទៃដីមានគុណភាពមិនល្អជាដីសោះកក្រោះ ដីខ្សាច់ គប្បីប្រើរយៈចម្ងាយ 6 x 6 ម៉ែត្រ ឬ 6 x 8 ម៉ែត្រ ។

② រយៈចម្ងាយដាំតាមលក្ខណៈទំរង់គុម្ពដើម (ក) លក្ខណៈអំពិលផ្អែមមានទំរង់គុម្ពដើមតូចដូចជាពូជ ឥន្ទថាណាំ គប្បីប្រើរយៈចម្ងាយដាំ 10 x 10 ម៉ែត្រ (ខ) លក្ខណៈពូជអំពិលផ្អែមដែលមានទំរង់គុម្ពដើមធំទូលាយ ដូចជាពូជហ្សិនចុង និងពូជពណ៌មាស គួរប្រើរយៈ 10 x 10 ម៉ែត្រ ឬ 12 x 12 ម៉ែត្រ (គ) ពូជអំពិលផ្អែមដែលមានទំរង់គុម្ពដើមជាមធ្យម គឺពូជទឹកឃ្មុំ និងពូជខន្តី គួរជ្រើសរើសរយៈដាំតាមគុណភាពរបស់ដី ។

ចំពោះការដាំវិធីប្រើតាមរបៀបលើករង រយៈចំងាយដែលដាំដែលយើងបានផលល្អ ភាគច្រើនគេប្រើរយៈប្លាតពីរណ្ដៅ 6 ម៉ែត្រ ដែលនឹងធ្វើអោយអំពិលពុះល្អតលាស់បានយ៉ាងឆាប់រហ័ស ប្រសិនបើប្រើរយៈដាំស្មើគ្នានិងទទឹងដីលើករង ប៉ុន្តែបើសង្ឃឹមអោយអំពិលផ្ដល់ផលរហូតពេញវ័យហើយ ដោយកាត់តែងមែកតែបន្តិចបន្តួចនោះច្រើនដាំប្លាតពីគ្នា 7 ម៉ែត្រ ប្រើរយៈពេលប្រហែល 5 ឆ្នាំ គុម្ពដើមនឹងប៉ះជង្គិចគ្នាហើយក៏ល្អត្រូវកំចាត់តែងមែកកុំអោយពុះរំលោះ ជំទូលាយពេក បើយកគុម្ពជំទូលាយអាចដាំប្លាតពីគ្នាទៅដល់ 10 ម៉ែត្រ ហើយគួរធ្វើនិងភ្លឺដីដែលទូលាយជាពិសេសដែលអាចជាការងារពិបាក ពីព្រោះបើភ្លឺដីទូលាយក៏ត្រូវប្រើដីច្រើនក្នុងការធ្វើអោយទាប អាចត្រូវជីកដីក្នុងប្រឡាយទឹកទូលាយហួសពេកទៅ ឬជ្រៅពេកទៅ ដែលធ្វើអោយអស់ផ្ទៃដីដែលត្រូវដាំ មាត់ភ្លឺដីបាក់ធ្លាក់ទឹកបានងាយ ។ បើដាំប្លាយឆ្ងាយពីគ្នាក៏បាន លុះគុម្ពដើមចាប់ផ្ដើមបៀតគ្នា ក៏ប្រែជាដើមមេសំរាប់ពន្លឺកព្វជមួយដើមខានមួយដើមទាល់តែបៀតគ្នាខ្លាំង ទើបកាត់មួយដើមខានមួយដើមក៏ទៅជាប្លាតគ្នា 8 ម៉ែត្រ ក្នុងមួយដើម ។

នាពេលសព្វថ្ងៃនេះមានគេសាកល្បងពិសោធន៍ដាំអំពិលផ្អែមក្នុងប្រព័ន្ធដាំជិតគ្នាដោយប្រើរយៈដាំ 6 x 6 ម៉ែត្រ ដោយសង្ឃឹមផលិតផលចំពោះផ្ទៃដីដែលដាំក្នុងរយៈពេលដំបូងខ្ពស់ និងដើម្បីស្រួលក្នុងការមើលរក្សាថែទាំបេះគួរ ។ ការពិសោធន៍នៅមិនទាន់ដឹងលទ្ធផលច្បាស់លាស់នៅឡើយ ។ បើប្រសិនជាបានផលល្អ និងជួយធ្វើការរក្សាថែទាំ បេះផ្លែអំពិលផ្អែមកាន់តែស្រួលឡើង ប៉ុន្តែមានចំណុចដែលត្រូវពិចារណាគឺការដាំក្នុងប្រព័ន្ធជិតគ្នា ត្រូវការកាត់តែងមែកច្រើនជាធម្មតាដែលអាចធ្វើអោយអំពិលផ្អែមមានមែកចាស់តិច មានមែកខ្ចីច្រើន ប៉ះជង្គិចដល់ការចេញផ្កាពីព្រោះអំពិលផ្អែមចេញផ្កានៅឯមែកចាស់ ។

តារាងរយៈចម្ងាយដាំ

| ថ្នាលផលិតកូរ | | |
|---|---|---|
| រយៈរវាងដើម (ម៉ែត្រ) | រយៈរវាងកូរ (ម៉ែត្រ) | ចំនួនដើមក្នុងមួយរ៉ៃ (ដើម) |
| 10 | 10 | 16 |
| 10 | 10 | 13.33 |
| 10 | 10 | 11.11 |

| ថ្នាលពង្រីកពូជ | | |
|---|---|---|
| រយៈរវាងដើម (ម៉ែត្រ) | រយៈរវាងកូរ (ម៉ែត្រ) | ចំនួនដើមក្នុងមួយរ៉ៃ (ដើម) |
| 0.50 | 2 | 1.600 |
| 1 | 2 | 800 |
| 2 | 2 | 400 |
| 3 | 3 | 177 |
| 4 | 4 | 100 |

## ការត្រៀមរណ្តៅដាំ

ការដាំអំពិលផ្អែមលើដីទួលខ្ពស់ ដំណាក់ការដាំមានសារៈសំខាន់ដល់ការដុះលូតលាស់របស់អំពិលផ្អែមច្រើនល្អមសមគួរ ពីព្រោះការដាំលើដីខ្ពស់ជាទូទៅ និងគ្មានការរៀបចំដីត្រៀមទុកមុនទេ បើមិនធ្វើនោះគឺគ្រាន់តែធ្វើការកំចាត់តិណជាតិស្មៅ និងកែប្រែផ្ទៃដីរួចហើយក៏ជីករណ្តៅមួយរំពេច ។ ដូចនេះរណ្តៅគួរត្រៀមដាំអោយបានល្អ ជាពិសេសបើសភាពដីមិនសូវល្អ ទំហំរណ្តៅដាំក៏គួរត្រៀមអោយមានទំហំធំជាងរណ្តៅក្នុងដីមិនល្អគួរមានទំហំ 75 x 75-50 សង្ទីម៉ែត្រ ឬ 1 x 1 x 1 ម៉ែត្រ ។

ការត្រៀមដីក្នុងរណ្តៅដាំ គួរកែប្រែអោយដីធូរ ដោយលាយដីក្រោល ឬជីផ្ទាប់និងឥន្ទ្រីយវត្ថុ (Organic matter) ដូចជាសំណល់តិណជាតិ អាចម៍សត្វផ្សេងៗដាក់ចុះទៅផង ដើម្បីជួយអោយដីដុំបទឹកបានល្អសមស្របដល់ការលូតលាស់ដំនៃឫស ក្នុងរយៈពេលដំបូងតាមកន្លែងមូលដ្ឋានខ្លះត្រូវប្រើធាងដូងចាត់ដាក់ត្រួតលើគ្នាលើបរិវេណបាតរណ្តៅ ដោយដាក់ផ្ទារខាងដែលមានសរសៃឡើងជាន់គ្នាប្រហែល 2-3 ជាន់ ដើម្បីអោយធាងដូងស្រូបយកសំណើមពេលស្រោចទឹក ឬភ្លៀងធ្លាក់ក្នុងបរិវេណច្រើនល្អមអោយដល់ដើមក្នុងរដូវហួតហែងជួយកុំអោយដើមស្ទះការលូតលាស់ធំៗ មុនភ្លៀងធ្លាក់ថ្មី ឬទឹកថ្មីមក ។

ដាក់ធាងដូងរួចជាស្រេច ហើយយកដីជាន់លើដែលជីកដាក់ដោយឡែកទុកដែលបានហាលស្រេច ហើយនៅពេលជីករណ្តៅលុបសង្កត់ធាងដូងអោយជិត ហើយប្រើថ្មហ្វូសហ្វាត ឬជីគីមីលេខ 15-15-15 ដាក់រងបាតរណ្តៅ ក្នុងមួយរណ្តៅៗចំនួន 3-4 ខាំ (មួយកំប៉ុងទឹកដោះគោ) ។

ចំពោះជីឥន្ទ្រីយវត្ថុដែលដាក់ចុះនៅទីនោះ គឺដាក់ពួកជីអាចម៍គោចាស់ៗ ជីផ្ទាប់សំណល់តិណជាតិ ។


ដីស្រទាប់លើ
ដីស្រទាប់ក្រោម
100 សម.
រណ្ដៅ
100 សម.


20-30 សម.
25 សម.
10 សម.
25 សម.
10 សម.
រណ្ដៅ

[illegible] ៣០ សង់ទីម៉ែត្រ ។ ការលើកដីអោយបានខ្ពស់នេះ ក៏ព្រោះត្រូវការអោយឫសរំពិល [illegible]ឡោះពេលដុះលូតលាស់ធំក្នុងរយៈពេលដំបូង ។ ដី [illegible] ត្រូវដាក់ដោយឡែកចំណែកដីស្រទាប់ [illegible] ។ [illegible]ចំនួន 15 ថ្ងៃ រួចហើយលាយដី [illegible] ។ ការចុះដាក់ក្នុងបាតរណ្ដៅអោយខ្ពស់ជាងកំរិតដីប្រហែល 30 សង់ទីម៉ែត្រ មុកសំរាប់ស្រុតតាមគល់ដើម ខុសអំពីការដាំអំពិលលើដីទួលខ្ពស់មិនចាំបាច់ត្រូវលើកប៉ុណ្ណោះ ដើម្បីការពារបញ្ចៀញបញ្ចូលទឹកលៀនហួសពេកក្នុងពេលស្រោចទឹក ។ ប៉ុន្តែបើដាំនៅលើដីទំនាប ឬសភាពដីបញ្ចៀញទឹកមិនសូវល្អ ចាំបាច់ត្រូវតួនដីអោយខ្ពស់ឡើង 30 សង់ទីម៉ែត្រ ដើម្បីជួយអោយទឹកហូរចេញ ពីព្រោះកាលណាមានភ្លៀងធ្លាក់ជោគជាំខ្លាំង ដីអាចបញ្ចៀញទឹកមិនបាន ឫសដែលទើបតែនិងចេញថ្មីៗ និងរលួយងាប់បាន ។

សំរាប់ការត្រៀមដីដែលធ្វើគោកនោះ គួធ្វើអោយបរិវេណដីនៅជុំវិញរណ្ដៅមកគរជាឬយគ្នា រួចបំបែកដីអោយល្អិត ហើយដាក់ជីអាចម៍គោ ឬជីផ្ទាប់លាយគ្នាក្នុងអត្រាដីមួយភាគ និងជីមួយភាគ ។

## ការជ្រើសរើសពូជដាំ និងការត្រៀមមែកពូជ

ការដាំអំពិលផ្អែមពូជណានៅកន្លែងដីនោះ អ្នកដាំជំនាន់ថ្មីហើយសូម្បីតែអ្នកដាំដើងចាស់ក៏ដោយ ក៏គួរតែស្ដាប់ពត៌មានដែលបានទទួលថ្មីជានិច្ច ព្រោះសព្វថ្ងៃនេះចាប់ផ្ដើមយល់ដឹង និងប្រើជាប្រយោជន៍អំពីបរិស្ថានក្នុងចំណុចរាយរង ឬមីក្រូមេតច្រើនគ្នាហើយ ហើយមុននឹងជ្រើសរើសពូជដាំគួរជ្រាបថា ពូជអំពិលផ្អែមបែបចេញបានប្រហែល 3 ប្រភេទគឺ :

① ពូជធ្ងន់ : បានដល់ពូជហ្វ៊ីនចុង ពណ៌មាស (លោកយ៉ាត់) ពេជ្រក្បែត្រជាពូជដែលក្រថ្លៃ ពីព្រោះមានអាយុវង់ចរជីវិតយូរ ការចាស់នៃផ្ការក៏ស៊ីពេលយូរយារណាស់ដែរ ។

② ពូជកណ្តាល : បានដល់ពូជខន្តី ពូជឥន្ទលាំ ជាពូជមិនសូវយឺតយូរដូចពូជធ្ងន់ទេ ។

③ ពូជស្រាល : បានដល់ពូជស្រីឆុមភូ ពូជទឹកឃ្មុំ ជាពូជរហ័សចេញផ្លែ ព្រោះអាយុវង់ចរជីវិតតាំងតែពីពេលចេញផ្ការហូតដល់ផ្លែចាស់ ស៊ីពេលវេលាតិច ។

ការដាំអំពិលផ្អែមលើដីទំនាប គួរជ្រើសរើសពូជធ្ងន់ ព្រោះដីទំនាបស្រែលើករងតែងតែក្រសួត ចំការផ្លែឈើជុំវិញមានសំណើមអាកាសច្រើន ។ បើសិនជាពូជស្រាលក៏ចាប់ផ្តើមផ្អែមទៅហើយ ក៏ប៉ុន្តែអាកាសនៅមានសំណើមនៅឡើយ ក៏នឹងកើតមេផ្សិតផ្ការបានងាយ ប៉ុន្តែបើពូជធ្ងន់អស់ភ្លៀងហើយ ប៉ុន្តែនៅមិនទាន់ចាស់នៅផ្ការនៅឡើយ មេរោគផ្សិតមិនចូលផ្ការហូតទៅដល់អាកាសហួតហែង មេរោគផ្សិតក៏ចាប់ផ្តើមតិច ហើយទើបចាប់ផ្តើមផ្អែម ។ ការដែលមានទឹកស្រោចបានរហូតដល់ពេលវេលាត្រូវការ ក៏ជាការមានប្រៀបក្នុងការបំប៉នអំពិលផ្អែមក្លាធំ អោយបានធំពេញទីបានរហូតទាល់តែមានលក្ខណៈពេញបរិបូរណ៍ បើសិនកន្លែងដែលមានដីខ្ពស់ ដីខ្សាច់ ដីជីវាលទេរ លុះអស់ភ្លៀងហើយទឹកក្នុងដីក៏ឆាប់អស់ ដូនកាលផ្ការក៏ល្អលាស់ធំពេញទី សភាពដីបែបនោះទើបមិនសមស្របក្នុងការដាំពូជធ្ងន់ ក៏បែរទៅដាំពូជស្រាលជំនួសវិញ ។ ដាទូទៅដីស្រែលើករងគួរដាំអំពិលពូជពណ៌មាស (លោកយ៉ាត់) និងពូជពេជ្រក្បែត្រ ។ ចំណែកពូជហ្វ៊ីនចុងនោះមានបញ្ហារៀងក្ការបែកច្រើន ទើបគេមិនសូវនិយមដាំ ។

រីឯភូមិភាគខាងត្បូងនិងភូមិភាគបូព៌ាដែលមានទឹកភ្លៀងធ្លាក់ជោគជាំ ភាគបូព៌ា ឧទាហរណ៍ដូចជាខេត្តច័ន្ទបុរី ចាត់ទុកជាខេត្តដែលមានភ្លៀងធ្លាក់ជោគជាំពិតមែន ប៉ុន្តែប្រៀបធៀបនិងភាគខាងត្បូងហើយសមស្របចំពោះការដាំអំពិលផ្អែមច្រើនជាង ។ និស្ស័យរបស់អំពិល

ផ្អែមត្រូវការប៉ះហួតហែង រដូវហួតហែងហើយភ្លៀងធ្លាក់រហូតរដូវភ្លៀង ។ លុះភ្លៀងធ្លាក់ក៏បែកត្រួយ ចេញផ្កា ជាប់ក្លួរ ចិញ្ចឹមក្លួររហូតដល់រដូវភ្លៀង លុះចូលរដូវរងារក៏គួរអស់ភ្លៀង សំណើមចុះថយព្រោះចាប់ផ្ដើមផ្អែម មានទឹកស្ករច្រើន ។ ដើនៅសើមនៅឡើយនិងកើតរោគមេផ្សិតបានងាយ ។ ខេត្តច័ន្ទបុរីក៏ចុះតាមកំណត់នេះបាន ។ លុះអស់ភ្លៀងហើយព្រោះរដូវត្រជាក់ក៏ចូលដែលអាកាសស្ងួតធ្វើអោយក្លួរអំពិលផ្អែមចាស់ បេះប្រមូលផលលក់បានដោយគ្មានមេរោគផ្សិត ។

នៅភាគខាងត្បូងមានភ្លៀងពីររដូវ គឺរដូវភ្លៀងធម្មតា ចាប់តាំងពីខែឧសភា ដល់ខែតុលា ដែលអំពិលផ្អែមក៏បែកត្រួយ ចេញផ្កា ជាប់ក្លួរ ។ លុះខែវិច្ឆិកាជាដើមទៅក៏ចាប់ផ្ដើមចាស់ លុះទុំហើយក៏ផ្អែម ។ ខ្យល់ត្រជាក់បក់ឆ្លងមកពីភូមិភាគដីទៃៗ និងចុះមកខាងត្បូងត្រូវឆ្លងកាត់ឈូងសមុទ្រថៃឡង់ដ៏ ក៏នាំចំហាយទឹកអំពីសមុទ្រមក ។ លុះមកប៉ះជង្ហុកលើដីគោកក៏កើតភ្លៀងធ្លាក់រាកាតេរខ្លាំង ។ នៅពេលនេះអំពិលដែលមានផ្អែមក៏កើតជុះផ្សិតខូចអស់រលីង ។ ដូច្នេះភាគខាងត្បូងកន្លែងណាដែលភ្លៀងធ្លាក់ជោគជាំនៅរដូវរងារ ក៏មិនអាចផលិតអំពិលផ្អែមអោយបានល្អឡើយ ព្រោះកើតជុះផ្សិតខូចអស់ ។ ប៉ុន្តែខេត្តច័ន្ទបុរីនោះខ្យល់ត្រជាក់ឆ្លងកាត់ចេញទៅទើបមិនសូវភ្លៀងធ្លាក់ដូចជាភាគខាងត្បូង ។

សរុបសេចក្ដីទៅថាការជ្រើសរើសពូជដាំក្នុងតំបន់នេះ គួរជ្រើសរើសពូជក្នុងពីរពួក គឺពូជធ្ងន់ និងពូជស្រាល ប្រើគោលការណ៍ទូលំទូលាយ គឺភ្លៀងនិងសំណើមក្នុងអាកាសកន្លែងនោះជាតួតំបន់កំណត់ ។ ពូជធ្ងន់នោះក្រចាស់ បានចាស់ទាល់តែបេះលក់អស់ហើយ ឬនៅ (ខែកុម្ភៈ) មុនចាប់ផ្ដើមត្រឡប់មកមានភ្លៀងថ្មី ។

ផ្ទុយទៅវិញបើជ្រើសរើសពូជស្រាល (បានព្រះរាជន៍ ទឹកឃ្មុំ ស្រីឆុមភូ) លុះដល់ចុងខែតុលាតភ្ជាប់មកដល់ខែវិច្ឆិកានោះអំពិលផ្អែមចាប់ផ្ដើមផ្អែមហើយ ។ ភ្លៀងនៅមិនទាន់ធ្លាក់ខ្លាំង ឬសំណើមក្នុងអាកាសមិនទាន់មានច្រើនទេ ។ បើដល់ដើមខែធ្នូទៅហើយ នៅមាន

សំណើមច្រើនអំពិលផ្អែមពូជស្រាល ក្ដួរនិងដុះផ្សិតជាពិតប្រាកដ ។ បែបនេះអាចប្រើពូជកណ្ដាល (ពូជឥន្ទួណាំ និងពូជខន្តិ) ឬអាចប្រើពូជធ្ងន់ (ហ្មិនចុង ពេជ្រក្សេត្រ) ដូចនោះ អ្នកកសិករចំការត្រូវមើលភូមិសាស្ត្រទីកន្លែងដាំ ហើយទើបជ្រើសរើសពូជអោយសមស្រប

ក្រៅពីរឿងពូជធ្ងន់ស្រាលនេះហើយ ការសំរេចចិត្តនិងថាជ្រើសរើសពូជណាស្រេចតែទៅលើអ្នកដាំអំពិលផ្អែម និងគ្មាដាំយ៉ាងណា ដាំដើម្បីអ្វី ពីព្រោះនៅក្នុងគោលបំណងនីមួយៗ សេចក្ដីត្រូវការនីមួយៗខុសពីគ្នាគឺ :

① <u>ដាំដើម្បីលក់ដូរ</u> : ត្រូវការប្រេះប្រមូលផលលក់ ឬប្រកាន់យកជាមុខរបរជាបង្គោល នោះ មិនគួរជ្រើសរើសដាំត្រឹមតែពូជមួយមុខទេ គួរដាំយ៉ាងតិចណាស់ 3 ពូជ ទាំងនេះព្រោះថានៅក្នុងពូជនីមួយៗការចាស់ ទុំរបស់ក្ដួរយឺត ឬឆាប់ខុសគ្នា ហើយនៅក្នុងពូជនីមួយៗត្រូវគិតដល់គុណភាព ព្រមទាំងផ្លែច្រើនស្មេះផង ។

② <u>ដាំដើម្បីបរិភោគខ្លួនឯង</u> : បើមិនសង្កត់ធ្ងន់ទៅលើការលក់ដូរទេ ករណីនេះក៏ស្រេចតែថាអ្នកដាំពេញចិត្តពូជអ្វី ក៏ជ្រើសរើសពូជនោះយកទៅដាំ ។ អ្នកខ្លះចូលចិត្តអំពិលផ្អែមដែលមានរសជាតិជូរអែមតិចៗក៏គួរជ្រើសរើសពូជឥន្ទួណាំ ។ ប៉ុន្តែមានចំណុចសង្កេតថាពួកជនជាតិអឺរ៉ុបចូលចិត្តផ្លែឈើ ដែលមានរសជាតិជូរអែម ។ ដូចនេះពូជអំពិលផ្អែមដែលមានរស់ជាតិដូចបានពោលមកនោះ គួរយកពូជឥន្ទលាំ ។ បើចូលចិត្តប្រភេទក្ដួរធំរសជាតិផ្អែមសុទ្ធនោះ គួរជ្រើសរើសយកពូជពណ៌មាស ។

③ <u>ដាំដើម្បីនាំចេញទៅលក់</u> : បច្ចុប្បន្ននេះអាចទៅមិនទាន់ហេតុផលគាំទ្របានថាជនបរទេសចូលចិត្តអំពិលពូជណាដែលច្រើនជាងគេបង្អស់ ។ ប៉ុន្តែមានចំណុចសង្កេតថាពួកជនជាតិអឺរ៉ុបចូលចិត្តផ្លែឈើណាដែមានជាតិជូរអែម ។ ដូចនេះពូជអំពិលផ្អែមដែលមានរសជាតិដូចបានពោលមកខាងលើនោះ គួរយកពូជឥន្ទួណាំ ។

១ <u>ដាំអោយសមស្របទៅតាមពេលវេលា និងធម្មជាតិ</u> : រដូវពេលណាចាស់ពេញទិ ហើយត្រូវបេះលក់ជាភួរៗ មិនបានយកសំបកស្ងួនជាដុំលក់ទេ ។ ដូចនេះបញ្ចូលកម្លាំងការងារបេះប្រមូលផលនិងកើតឡើងបាន ។ គួរផ្លាស់ប្តូរជៀសវាងកុំអោយត្រូវចំពេលគ្នាក្នុងការប្រមូលផលស្រែចំការ ឬផ្លែឈើដ៏ទៃទៀត ។

ក្រៅពីរឿងពូជដាំហើយរឿងសំខាន់តទៅគឺរឿងមែកពូជ ។ ដើមអំពិលផ្អែមដែលនិងយកទៅដាំនោះគួរត្រៀមទុកជាមុន អោយដើមមានសភាពរឹងប៉ឹងមាំមួនល្អដែលអាចនាំជញ្ជូនទៅដាំបាន ។ ជ្រើសរើសដើមដែលគ្មានមរោគ គ្មានសត្វល្អិតបៀតបៀនបំផ្លាញ ។ ប្រភពផលិតមែកពូជអំពិលផ្អែមដែលល្អ និងមានគុណភាពនោះ មានច្រើននៅខេត្តពេជ្របូរណ៍ ឬនៅចំការអំពិលផ្អែមទូទៅ ។ ទីកន្លែងខ្លះដែលពង្រីកពូជលក់ ដើមអំពិលផ្អែមយកមកដាំគួរតែបានមកពីការជ្រើសរើសពីចំការដែលទុកចិត្តបានពីពោះមិនអាចសង្កេតបានអំពិលមែកពូជបានទាល់តែសោះថា លក្ខណៈដើមនិងស្លឹកជាពូជអ្វី ។ មែកពូជដែលយកមកដាំគប្បីជាមែកដែលបានមកពីការបំបៅទើបសមស្របជាទីបំផុត ។

<u>វិធីដាំ</u> :

នាំយកមែកអំពិលផ្អែមដែលបំបៅរួចហើយ ហើយបានផ្សាំក្រោយពីការកាត់ពីដើមមេ យ៉ាងតិចមួយអាទិត្យ ហែកយកថ្លាស្ទិកចេញ ប្រយ័ត្នកុំអោយដីក្នុងថង់បែក អាចប្រូបាច់អោយដីក្នុងថង់ណែនមុនហែក ។ ដាក់ថង់ដើមពូជចុះត្រង់កណ្តាលមាត់រណ្តៅ យកដីលាយគ្នាលុបទិចទំនាបអោយខ្ពស់ជាងគិរិតផ្ទៃដីប្រហែល 30 សង្ទីម៉ែត្រ ។ កន្លែងទួលខ្ពស់ជាងគិរិតដីប្រហែល 30 សង្ទីម៉ែត្រ ។ កន្លែងដីខ្ពស់មិនបាច់ពូនគល់ ។ លប់អោយស្នាមលើមាត់រណ្តៅបន្តិចជាន់ដីអោយណែនដាំហើយយើងត្រូវប្រើឈើដោតបោះតៀកនិងដើម យកខ្សែ

ចងអោយជាប់ទៅនិងបង្គោលនេះ 2-3 ចំណង ការពារកុំអោយខ្យល់យោគ ព្រលិតដើម អោយពរេត្រង់ ស្រោចទឹកអោយជោគបើត្រូវដាំ ។

ដាំស្រេចហើយស្រោចទឹកអោយសើមជោគ យកស្មៅឬចំបើងគ្របបរិវេណគល់ ដើម្បីជួយអោយសើមបានយូរ ប៉ុន្តែត្រូវចាំមើលបើមានភ្លៀងធ្លាក់ខ្លាំងពេកនៅរដូវភ្លៀង ។ ក្រោយពីភ្លៀងធ្លាក់ត្រូវយកស្មៅ ឬចំបើងចេញដើម្បីកុំអោយដើមបៀមទឹកច្រើនឫសពេកអាចធ្វើអោយរលួយឫសបាន ប៉ុន្តែកុំយកស្មៅ ឬចំបើងចេញពីព្រោះគ្រាប់ភ្លៀងនិងច្រោះដីរណ្តៅដាំចេញទៅ ។ ក្រោយពីភ្លៀងធ្លាក់ខ្លាំងរួចហើយបើឃើញថាដីណែនហួសពេកទើបយកចេញ ។

បើដាំអំពិលផ្អែមច្រើនដើម ហើយស្រោចទឹកមិនស្រួលគួរង់ចាំចង្វាក់ភ្លៀងអោយបានល្អដាំកាលណាដីសើមល្មមសមគួរ ។ គួរដាំនៅដើមរដូវភ្លៀងដើម្បីអោយមានចន្លោះពេលដែលអំពិលផ្អែមនិងបានទទួលទឹកភ្លៀងបានយូរ និងធ្វើអោយអំពិលដើមតូចតាំងជីបរធាប់របស់បានរឹងប៉ឹង ដុះឫសបានវែងជ្រៅសាយទូលាយ ជួយអោយអំពិលផ្អែមធន់នឹងភាពហួតហែងបានល្អ ។

ចំការខ្លះនៅក្នុងខេត្តពេជ្របុរណ៍ ប្រើវិធីដាំដុះផ្លែកជាងវិធីទូទៅ គឺដោយការបន្ថែមឫសដោយអំពិលផ្អែម លុះដាំនៅពេលតូចៗនៅឡើយ គេនិងដាំអំពិលជូរតូចៗ 2-3 ដើម ជុំវិញ ។ តមកក៏បំពៅអោយជាប់គ្នាដោយបំពៅបញ្ជៀងមុំគ្នា ក្លាយជាអំពិលមួយដើមានឫសបួនឈុត ឬឫសធំ 4 គេជឿថាធ្វើអោយដើមអំពិលធាប់ធំប្រហែល 3 ដង នៃដើមអំពិលមិនបន្ថែមឫស ។ កាលណាមានឫសក្នុងដីច្រើនពេលដាក់ជីក៏ស្រូបជីឡើងទៅរស់ ហើយធាប់របស់ ហៅថាតបស្នងដល់ដីល្អជាងដើមដែលមិនបានបន្ថែមឫសអោយ ។

ការជ្រើសរើសដើមពូជអោយចំនួនស្មើគ្នា ការដាក់រណ្តៅដាំតាមមាត្រដ្ឋានមានដីផ្ទាប់ ជីអាចម៍គោច្រើនល្មមសមគួរក្នុងរណ្តៅនិមួយៗ ធ្វើអោយដើមអំពិលផ្អែមដុះលូតលាស់ធំបានល្អជាពិសេសគ្មានបញ្ហាក្នុងការដាំដុះសព្វថ្ងៃ ។

## ការមើលថែរក្សាថែទាំអំពិលដើមតូច :

កាលណាចាប់ផ្តើមដាំថ្មីៗត្រូវមើលថែរក្សាថែទាំអោយបានជិតដល់ជានិច្ចគ្រប់ពេលវេលា ពោលគឺក្រោយពីដាំអំពិលហើយត្រូវស្រោចទឹក 3 ថ្ងៃម្តងៗ កាលណាគ្មានភ្លៀងធ្លាក់ច្រើនរហូតដល់អំពិលផ្អែមអាយុបានមួយឆ្នាំ ការអោយទឹកក៏នឹងមិនមានតឹងរ៉ឹងណាស់ណាទេ ពីព្រោះដើមអំពិលផ្អែមមានជំហរបានហើយ ឬអាចអោយទឹកម្តងម្កាលក្នុងរដូវប្រាំងហែង ។

ក្រោយពីពេលដាំបានប្រហែល 2-4 ខែ ពិនិត្យមើលការដុះលូតលាស់ចំរើននៃអំពិលផ្អែមកាលណាឃើញថាដើមគល់ និងមែកពូជល្អដុះសាច់ជាប់ជិតគ្នាបានល្អហើយ ក៏បកសំពត់ប្លាស្ទិកដែលរុំស្នាមបំពៅចេញចោល កាលណាទុកវាដើមអំពិលធំឡើង នឹងធ្វើអោយកើតបានស្នាមរីកដុះដោយសារចងប្លាស្ទិករឹត ។

ត្រូវត្រួតពិនិត្យមើលកុំបណ្តោយអោយស្មៅដុះស្តុកតាមគល់ដើម ។ សង្កេតមើលដីបើឃើញណែនហួសពេកក៏ជ្រោយខ្លះ ជាពិសេសនៅពេលចុងរដូវភ្លៀងឈានចូលដល់រដូវរងារ ការជ្រោយដីអោយដើមអំពិលផ្អែម និងវត្ថុគ្របដីក្រោមទំរង់គុម្ពដើម លើកលែងចំពោះដើមគល់បន្តិចបន្តួច ដើម្បីអោយពន្លឺថ្ងៃចាំងដល់ និងការពារសត្វល្អិតផ្សេងៗដែលនឹងបំផ្លាញគល់ដើម ។ វត្ថុគ្របដីនិងជួយរក្សាសំណើមគល់បានក្នុងរយៈពេលរដូវរងារ ដែលអាកាសធាតុស្ងួតបានយ៉ាងល្អ ។ ពួកវត្ថុគ្របដីគឺចំបើង អង្កាម សំបកសណ្តែក ស្មៅស្ងួត ជីអាចម៍រណារ ជីអាចម៍គោ ដីផ្ទាប់ជាដើម ។

ការមើលរក្សាថែទាំអំពិលផ្អែមដើមតូច ក្រៅពីនេះក្នុងឆ្នាំដំបូងជាពិសេសចំពោះការដាំមែក បំពៅត្រូវចាំត្រួតពិនិត្យមើល តើមានមែកបំពង់បែកចេញពីដើមឬទេ បើមានឬប្រទះឃើញ ត្រូវក្តិចចោល ព្រោះជាមែកអំពិលជូរ ។ ក្រៅពីនេះកាលណាអំពិលផ្អែមចាប់ផ្តើមបែកស្លឹក ខ្ចី គួរបាញ់ថ្នាំសម្លាប់សត្វល្អិតដើម្បីការពារសត្វល្អិតមកស៊ីខ្ចី ។

<u>ការដាំរុក្ខជាតិគួបផ្សំ</u> :

ទោះបីជាអំពិលផ្អែមជារុក្ខជាតិចេញផ្កា ជាប់ផ្លែរហ័សក្នុងរយៈពេល 2-3 ឆ្នាំក៏ដោយ ក៏នៅ មិនទាន់ផ្លែបានច្រើនណាស់ណាទេ មិនតែប៉ុណ្ណោះ តែបើសិនជាទៀតថែរក្សាអោយដើម អំពិលអោយមានទំរង់គុម្ពដើមធំ 10 ម៉ែត្រ អាចត្រូវរង់ចាំពេលរាប់សិបឆ្នាំ ។ ហេតុ ដូច្នោះដីដែលនៅចំនេរ រវាងជួរ និងរវាងដើមនឹងល្អប្រសើរប្រយោជន៍ បើគេមិនដាំ រុក្ខជាតិដុះទេក៏ត្រូវប្រេះដីរឿយៗ ប៉ុន្តែបើបណ្តោយអោយស្មៅដុះក៏ត្រូវកំចាត់ស្មៅដោយការ ចិញ្ចឹមសត្វ ។ ចំការខ្លះទើបមានផែនការដាំរុក្ខជាតិផ្សេងតែម្តង ដើម្បីអោយមានប្រាក់ចំណូល ជាបណ្តើរៗសិន ។ លុះអំពិលមានទំរង់គុម្ពដើមធំបៀតគ្នាខ្លាំងហើយ ទើបបន្ថយរុក្ខជាតិ ដាំផ្សេង ។

ចំការខ្លះដាំអំពិលផ្អែមតាមបែបថ្មី មិនត្រូវការចំលួតលាស់ទេអោយមានមុខនាទីចេញផ្កា ចេញផ្លែច្រើនស្មើរៀងរាល់ឆ្នាំក៏គ្រប់គ្រាន់ហើយ ។ នៅតាមកន្លែងខ្លះក៏មានគេប្រើសារៈ- ធាតុខាល់ថារបាញ់ហើយបានផលល្អ ។ បើធ្វើបានដូចនេះមិនបាច់ទុកដីអោយទំនេររវាង ដើមច្រើនណាស់ណាទេ ។ បើពេញចិត្តរយៈត្រឹម 8 ម៉ែត្រ ក៏ដាំរយៈ 8 x 12 ម៉ែត្រទៅ ប៉ុន្តែអ្នកខ្លះដាំ 4 x 12 ម៉ែត្រ ។ លុះដល់ពេលដើមចាប់បៀតគ្នាក៏កាត់ចេញមួយដើមខាន មួយដែលក្លាយទៅជារយៈ 8 x 12 ម៉ែត្រ ។ អ្នកខ្លះបានប៉ាន់ប្រមាណមើលអោយឃើញ ថាមែកពូជអំពិលផ្អែមនោះតម្លៃមិនលើសពី 15 បាត ។ ដាំចោលអោយផ្លែមុននិងកាត់លក់ ក៏ច្រើនឆ្នាំដែលលក់បានប្រាក់ក្នុងមួយដើមបានលើសពី 15បាតទៅទៀត ជាហេតុធ្វើអោយ





អ្នកដាក់ទុនជំនាន់ថ្មីខ្លះហ៊ានដាំក្នុងដីមួយរ៉ៃទៅដល់ 100 ដើម គឺ 4 x 4 ម៉ែត្រ ។ ពសៅ អ្នកខ្លះនិយមចាត់ជួរអោយស្រេចតាំងពីចាប់ផ្ដើមដាំ ។ បើមិនទាស់និងភូមិសាស្ត្រស្ថាបត្យ ឬយកលំអរនៃការកាត់តែងចំការ ក៏អាចចាត់ជួរតាមថ្ងៃដែលជាវិធីប្រើពន្លឺថ្ងៃក្នុងការដាំជួស បានផលល្អបំផុត ។ ជួរទទឹងថ្ងៃនោះ លុះរុក្ខជាតិមានជំហរធំបន្តិចត្រូវបាំងពន្លឺថ្ងៃនៅពេល ព្រឹក និងពេលរសៀលនៅឡើយ ។ បានពន្លឺថ្ងៃល្អនៅពេលដែលថ្ងៃត្រង់តែប៉ុណ្ណោះ ។ បើកាត់ ជួរថ្ងៃកើតមានម្លប់បាំងគ្នាឯង នៅក្នុងជួររហូតព្រឹកដល់ល្ងាច ។ រីឯចន្លោះទំនេររវាងជួរ និងបានទទួលនូវពន្លឺថ្ងៃពេញលេញរហូតមួយថ្ងៃដូចគ្នា ដែលស្រដៀងនិងការដាំរុក្ខជាតិជួស ក្នុងទីស្រឡះ ធ្វើអោយរុក្ខជាតិជួសផ្ដល់អោយផលបរិបូរណ៍ផង ។ សេចក្ដីលំអិតក្នុងការដាំ រុក្ខជាតិជួសនោះបែងចែកបានតាមលក្ខណៈដូចតទៅនេះ :

① <u>ដាំដំណាំរើរុះ ជួសអំពិលផ្អែមលើដីទួល</u> : អ្នកកសិករបានដឹងជាក់លាក់ក្នុងការដាំដំណាំ ពោត ស្រូវមីយេ (Millet) សណ្ដែក ដីឡូង ។ល។ ស្រេចហើយ ។ ការដាក់ក្នុងឆ្នាំ ដំបូងអាចដាំបែបអំពិលផ្អែមជួសដំណាំរើរុះ គឺដាំរុក្ខជាតិជាដំណាំរើរុះមក ហើយ វាយរណ្ដៅដាំអំពិលជាចំណុចកន្លែងត្រូវការ ។ ការធ្វើដូចនេះសឹងតែធ្វើមិនប៉ះពាល់ ទង្គិចដល់ការផលិតនៃដំណាំរើរុះឡើយ ហាក់បីដូចជាការផ្ញើរអំពិលផ្អែមទុកផង ។ កាលណាប្រមូលផលហើយយើងក៏បានអំពិលធំល្មមសមគួរគឺអាយុប្រហែល 5-6 ខែ បើដំណាំរើរុះជំនាន់ទីពីរ អំណើះតទៅគ្រាន់តែភ្ជួរដែលមិនស្រួលបន្តិចបន្តួចក្នុងការ ជៀសវាងដើមអំពិល ។ ក្នុងឆ្នាំតទៅក៏ភ្ជួរទីដាំដំណាំរើរុះបានដូចដើម ហើយក៏នឹង នៅតែធ្វើបានទៅទៀតច្រើនឆ្នាំ ។ បើរយៈចន្លោះរាងទូលាយដូចជា 10 x 12 ម៉ែត្រ ជាដើម ។

② <u>ដាំបន្លែជួសក្នុងចំការអំពិលផ្អែម</u> : នៅលើដីទួលមិនសូវជួបប្រទះ ។ យ៉ាងច្រើនក៏ដាំ ពោតដំណើបដែលអាចប្រើជាបន្លែបាន ប៉ុន្តែការដាំអំពិលលើដីទំនាបភាគកណ្ដាលប ដូចជាសាមផ្រានបានដែរក្រាកធុមបែន និយមដាំពាសពេញរង លើកលែងតែចំពោះ

ដើមអំពិលតែប៉ុណ្ណោះ ។ បន្លែនេះមានរយៈការបាញ់សារជាតិកំចាត់សត្រូវរុក្ខជាតិអរម៉ូន និងជីបាញ់ស្លឹកសឹងតែ 5-7 ថ្ងៃម្តង ដែលបណ្តាលអោយអំពិលបានទទួលផលល្អផងដែរ គឺឆាប់ដុះលូតលាស់ធំជាពិសេស ។ តាមធម្មតានិងមានប្រាក់ចំណូលអំពីបន្លែប្រហែល 3 ឆ្នាំ ។ បន្ទាប់ពីនោះប្រាក់ចំណូលអំពីអំពិលផ្អែមក៏ជាបង្គោលការដែលគួរសង្កេតគឺមែកថ្មីនៃអំពិលរាងវែង ពីព្រោះប្រើជីតាមស្លឹកជុំវិញជាប្រចាំនោះឯង ។

③ <u>ដាំពេញហូបផ្លែជូរក្នុងចំការអំពិល</u> : ក្នុងតំបន់ព្រៃបន្លោះ និងច្រើនខេត្តនៅក្នុងភូមិភាគឥណ្ឌូសាន្តបានដាំទៀបជារុក្ខជាតិជូរ ។ ទៀបនោះជាដើមមិនខ្ពស់ជាងអំពិលហើយបើចាំបាច់ក៏កាត់តែងមែកអោយដើមទាបបាន ។ អំពិលផ្អាកដុះលូតលាស់នៅក្នុងរដូវហួតហែង ។ ដូចនេះរុក្ខជាតិជូរក៏គួរផ្អាកដុះលូតលាស់នៅក្នុងរដូវហួតហែងផងដែរ ដោយទាបសមស្របល្អណាស់ មិនបៀតបៀនអំពិល រឿងទឹក និងសំណើមសោះឡើយ ។ ទៀបចេញផ្កាក្នុងរដូវភ្លៀង ហើយផ្លែក៏បេះលក់បានរហ័សលុះអស់ភ្លៀងក៏ផ្អាកការដុះលូតលាស់ដូចអំពិល ប្រើរុក្ខជាតិដែលត្រូវអោយទឹកដាំចិញ្ចឹមផ្លែនៅរដូវហួតហែងដូចជាស្វាយ ត្រលេន សំណើមទាំងនេះនិងទៅបៀតបៀនការដុះលូតលាស់នៃអំពិលពេលហែងនោះបាន ។

④ <u>ការចិញ្ចឹមត្រីក្នុងរងអំពិលទីទំនាប</u> : នៅទីទំនាប ឬស្រែលើករងគួរចិញ្ចឹមត្រីប្រាក្នុងប្រឡាយទឹកដើម្បីអោយជួយស៊ីស្មៅ ។ ក្នុងទឹកគួរដាក់កំពឹងពួយ ចក កំព្ញ៉ែក ទៅលើផ្ទៃទឹកដើម្បីចាប់ជីក្នុងទឹកអោយមកនៅជាមួយរុក្ខជាតិពួកនេះ ។ ចាំជងរុក្ខជាតិមកដាក់ក្រោមគុម្ពដើមអោយពុករលួយ ។ ត្រូវប្រើជីដែលខ្វះនីត្រូសែនដូចជា 0-0-30; 0-3-0 និងឌិនដូឡូមិត ដែលនិងជួយអោយកើតសំបូរភាពល្អ ស្លឹកមិនស្កុក ចេញផ្កាចេញផ្លែងាយ ។ កាលណាជាប់គួរហើយសឹមបន្ថែមអ៊ុយរ៉េ (UREA) ខ្លះបន្តិច

បន្តូចដើម្បីជួយអោយក្តួរធំបន្តិចម្តងៗទំរាំជិតចាស់ ឬក្តួរធំពេញទីហើយក៏ពររប់ ។ បើនិជ្រួសែននៅជាប់សល់ច្រើន ក៏ក្រទុំ ឬមិនស្រួវទុំ ហើយមានរសជាតិជូរ ។

<u>ការកំចាត់ស្មៅចង្រៃ</u> :

ការងារធ្វើចំការ ស្រែ តែងតែមានស្មៅក្នុងទីធ្លាមួយច្រើនប្រភេទ ។ ប្រភេទដែលមិនត្រូវការហៅថា ស្មៅចង្រៃ ។ ក្នុងយុគ្គបច្ចុប្បន្នមិនចាំបាច់គិតពីពេញ្រាកកាត់ចោល ជំរះចោល ឬជីកចោល ឬបាញ់សារៈជាតិសម្លាប់ស្មៅដូចសម័យមុនទេ ក៏ប៉ុន្តែរកវិធីធ្វើទៅលើស្មៅអោយថយនូវភាពមិនត្រូវការអោយនៅតិចបំផុត អោយកើតប្រយោជន៍ខ្ពស់បំផុត ។

រយៈពេលប្រហែល 30 ថ្ងៃ ក្រោយដាំអំពិលហើយក៏ចាប់ផ្តើមមានស្មៅឡើង ។ ពាក្យថាស្មៅរបស់កសិករស្រែចំការ អាចមិនសំដៅដល់រុក្ខជាតិស្លឹកល្អិតដូចអ្នកបច្ចេកទេសព្រោះកំណត់ទុកនោះទេ ប៉ុន្តែគ្រប់ដំណាំទាំងស្លឹកល្អិត ស្លឹកធំទាំងឡាយដែលនៅក្នុងចំការ បង្កអោយមានផលអាក្រក់យ៉ាងច្រើន គឺដណ្តើមទឹក និងជីរបស់រុក្ខជាតិដំណាំជាបង្គោល នាំទិបង្កើតពង្រីកពូជសត្វរុក្ខជាតិផ្សេងៗ ដែលនិងអាចចេញទៅបំផ្លាញរុក្ខជាតិក្រៅចំការទៀតផង ឬរុក្ខជាតិជាបង្គោលខ្លួនឯងតែម្តង ធ្វើអោយចំការស្តុកអ៊្វិញ ធ្វើការមិនស្រួល ចោរច្រើនព្រោះគេគេចពួនបានងាយ ហើយលុះដល់រដូវហួតហែង ស្មៅក៏ស្ងួតហែងជាមេភ្លើងឆេះចំការបំផ្លាញអំពិលបាន ទើបចាំបាច់ត្រូវរកវិធីធ្វើការកំចាត់ស្មៅ ។ គោលការណ៍គឺធ្វើអោយបរិវេណជុំវិញគល់ 2-3 ម៉ែត្រ ឬស្មៅនិងភាពទូលាយនៃកម្ពស់ស្មើរង្វង់គុម្ពដើម ។ ចំណែកខាងក្រៅគុម្ពដើមមិនបាច់កំចាត់ទេ ទុកអោយវានៅ ដើម្បីប្រើអោយគ្របបុះការពារការច្រោះដី ព្រមទាំងការពាររក្សាសំណើមទុកនៅក្នុងដី ។ ចំពោះសំណល់ស្មៅដែលជំរះចេញអោយយកទៅគ្របគល់ដើម រួចយកដីលុប ឬទុកអោយរលួយទៅជាជីអោយដើមអំពិលតទៅ ។

វិធីកាត់ស្មៅ : ប្រើកាំបិត ប្រើគ្រឿងម៉ាស៊ីនកាត់ប្រភេទរុញក៏បាន ប្រភេទទាញក៏បានប្រើគ្រឿងកាត់ស្មៅជាមួយត្រាក់ទ័រក៏បាន ។ គួប្រើវិធីកាត់ស្មៅលើផ្ទៃដីកុំជីរះស្មៅ ។ ការជីរះស្មៅជាការបើកមុខដីអោយត្រូវភ្លៀងព្រោះបែកក្រហែងបានងាយ ។ កាលណាស្មៅដុះឡើងខ្ពស់ហួសប្រមាណ 30 សង្ទីម៉ែត្រ ឬចេញផ្កាគួរកាត់ស្មៅមុនគ្រាប់ចាស់ បើមិនដូចនោះទេគ្រាប់ស្មៅអាចដុះរាលដាលចេញទៅបំផ្លាញរុក្ខជាតិដែលនៅជិតហ្នឹងបាន ។ បើនៅលើទីនេះមានព្រោះសណ្តែកពាយ ឬសណ្តែកដទៃៗដែលជារុក្ខជាតិបំរុងដីដួសគ្នាជាមួយស្មៅ ។ ការកាត់ញឹកញយធ្វើអោយបែកដើមដុះឡើងមកទៀត ហើយកាត់ទៀតក៏ជាការបំរុងដីទៀតជាវិធីមួយ ។ លុះជិតចុងភ្លៀងក៏ត្រូវប្រញាប់កាត់ស្មៅអោយរាងទាប ដើម្បីអោយសំណាកស្មៅរលួយឆាប់មុនពេលចូលរដូវរងារ និងរដូវហួតហែង បើកាត់ស្មៅយឺតពេកទៅដល់ហួតហែង កាត់ហើយស្មៅវែងពេក ។ កាលណាស្ងួតក៏ទៅជាមេភ្លើងក្នុងរដូវហួតហែងនោះឯងមើលគួរកាត់ស្មៅញឹកញយមកតាំងពីដើមរហូតភ្លៀង ។

បំពោះពួកស្មៅស្បូវ និងពិណជាតិពិបាកកំចាត់ដទៃទៀត បណ្តោយអោយដុះឡើងធំពេញទំហឹង មុននិងចេញផ្កា និងចាប់ផ្តើមចេញផ្កា បាញ់ថ្នាំស្ប៉ាក (Spark) ប្រើថ្នាំពួកថ្លៃហួសេពពាមអត្រាក្នុងស្លាក ហើយលាយជាមួយសារជាតិជួយបន្ថែមប្រសិទ្ធិភាពថ្នាំដូចជា ត្រៃពាន់ស៊ុអេស 7, ភិតស៊ុលិន 77, ឬបេនដល ។ល។ ពេលបាញ់សារៈជាតិក៏និងបានសើមសព្វ ។ ការរង់ចាំរុក្ខជាតិធំពេញធឹង ធ្វើអោយផ្ទៃលើស្លឹករុក្ខជាតិដែលប៉ះពាល់ថ្នាំបានច្រើនបណ្តាលអោយជ្រាបយកជ្រួតជ្រាបយ៉ាងពេញលេញ ហើយចលនាដើរចុះទៅតាមឫសផ្សេងៗ ដែលតមកនិងបំផ្លាញរុក្ខជាតិអោយស្លាប់អស់រលីង ។ កុំប្រើស្ប៉ាក រួមជាមួយនិងថ្នាំសម្លាប់ស្មៅប្រភេទសម្ពស្ស (គឺប៉ះស្អិតជាប់) ដូចជាផារាខ្យត ពីព្រោះកាលណាត្រូវថ្នាំរុក្ខជាតិនិងស្លាប់មួយរំពេច ក៏បន្ថយការស្រូបជ្រាបចុះទៅ ។ រុក្ខជាតិនិងស្លាប់តែខាងលើហើយក៏ងើបរស់ឡើងវិញម្តងទៀត ។

បាញ់ស្បៀក ហើយទុកចោលអោយស្មៅងាប់បន្តិចម្តងៗបន្ទាប់ទាល់តែអស់ ។ បាញ់ថ្នាំកុំអោយទៅកាត់ចេញ ព្រោះត្រូវបណ្តោយអោយសារៈជាតិធ្វើចលនាដើរកាត់ឫសគល់ហើយរុះផង ។ សារៈជាតិនេះចូលទៅកាន់រុក្ខជាតិតាមផ្នែកពណ៌ខៀវ ទើបបាញ់អោយត្រូវល្អ ។ បាញ់អោយចំទឹកតែចំពោះស្មៅកុំអោយត្រូវរុក្ខជាតិបង្គោល គឺស្លឹកអំពិលដែលខៀវ ពីព្រោះថ្នាំជ្រាបចូលទៅបានត្រូវអោយបាញ់តែចំពោះពណ៌ត្នោតនៃអំពិល ។ ដូចនេះអំពិលនឹងមិនបានទទួលគ្រោះថ្នាក់ខូចខាតដោយប្រការណាមួយ ។

ការកំចាត់ស្មៅដោយវិធីមួយទៀត គឺចិញ្ចឹមសត្វអោយស៊ីស្មៅ ។ បើអំពិលដើមនៅតូចទាបកុំបណ្តោយអោយបសុសត្វ (សត្វចិញ្ចឹម) ចូលទៅករកេរប្រទាញស៊ីមិនបានទេ ពីព្រោះមានគ្រោះថ្នាក់ដល់អំពិល ។ អាចប្រើវិធីច្រូតស្មៅអោយសត្វស៊ី ប៉ុន្តែក៏អាចលែងគោក្របីអោយទៅរកស៊ីបាន ។ កាលណាដើមធំហើយផុតពីការបំផ្លាញរបស់ពពែ ចៀម ហើយអាចលែងអោយចូលទៅរកស៊ីបាន ឯចៀមនោះគេលែងបាច់ខ្លាចជាងពពែ ព្រោះវាចូលចិត្តស៊ីស្មៅជាងស្លឹកឈើ ។ មានក្មេងគង្វាលចៀមម៉ោងដេញហ្វូងចៀមទៅអោយស៊ីស្មៅ ពាសពាលពេញទី បណ្តាលអោយស្មៅទាបរាបស្មើ ។ បើដើមខ្ពស់ធំច្រើនអាចលែងគោក្របីអោយស៊ីបានផង ។ ការចិញ្ចឹមសត្វក្នុងចំការនឹងជួយអោយស្មៅរាប ហើយលាមកសត្វជាជីបំប៉នដីទៀតផង ។

ទោះជាយ៉ាងណាក្តី ស្មៅក្រៅពីមានគុណវិបត្តិហើយ នៅមានគុណប្រយោជន៍ផងដែរ ។ ប្រយោជន៍របស់ស្មៅឃើញច្បាស់ក្រៃលែង ក្នុងកន្លែងដាំអំពិលលើដីលាតស្ទើរ ។ ដីភាគ នៅភាគឦសានពេលណាមានភ្លៀងខ្លាំង ក៏កើតមានទឹកហូរច្រោះដែលបណ្តាលអោយ អោយបាក់ដីសើរលើ ។ បើមានស្មៅគ្របលើដីសើរលើនិងជួយទប់ទុះដីទុក ហើយ អោយទឹកជ្រាបចុះទៅក្នុងដីខាងក្រោមយូរឡើង ។ ស្មៅក្នុងចំការអំពិល ដីសើមរៀងរហូត ហើយទៅជាជីរហោរ ដូចការក្រាលការពារសំណើមនៃអាកាសក្នុង

ឃើញស្ថិតនៅក្នុងកំរិតដីសមស្របល្អល្មម ។ ស្មៅនៅជួយជាគ្រឿងចង្អុរប្រាប់ក្នុងការដាក់ជី និងភាពល្អបរិបូរណ៍នៃដីនោះឯងផង ពីព្រោះស្មៅទទួលជីបានល្អណាស់ ។ បើដីច្រើនស្មៅ

ក៏ស្រស់ខ្លាំងរហ័សដែរ ។ យើងប្រើស្មៅបន្ថែមឥន្ទ្រិយវត្ថុ (Orgamic Matter) អោយដល់ដី ហើយនៅប្រើចំណីសត្វបានផង ។ នៅចំការកន្លែងស្រឡះបើត្រូវការអោយដុះស្មៅឡើងពេញទីក៏ជួយដោយយកអាចម៍គោ ក្របី ដែលតាមធម្មតាមានគ្រាប់ស្មៅលាយឡំមកផង យកមកពាចខ្ចាយពាសពេញដីតាំងតែរដូវភ្លៀង ។ ជីអាចម៍គោមានភាពឧត្តមសម្បូរណ៍របស់សាច់ដីនៅខ្លះ ក៏និងជួយការដុះលូតលាស់របស់ស្មៅ ប៉ុន្តែបើស្មៅក្រដុះជំក៏ដាក់ជី 15-5-20 + 2 និងថ្មហ្វូសហ្វាត 0-3-0 អោយខ្លះ ស្មៅនិងឆាប់ដុះឡើងយ៉ាងឆាប់រហ័ស ។ ត្រូវចាំមើលអោយស្មៅដុះរាលពាសពេញស្មើគ្នាក្នុងចំការទាំងអស់ ។

<u>ធ្វើកន្លែងការពារភ្លើងឆេះ</u> :

ចំការរំពិលគ្រប់ចំការត្រូវធ្វើកន្លែងជួរការពារភ្លើងឆេះទុកផង ពីព្រោះអំពិលផ្អែមមានភាពពន់ខ្សោយឆាប់ឆាបឆេះភ្លើង ភ្លើងរាលដាល បើអំពិលត្រូវភ្លើងរាលដាលនិងបណ្តាលអោយឈប់ចេញផ្កា និងផ្អាកទៅច្រើនឆ្នាំ ។ ជួនកាលរសជាតិក៏ផ្លូវតែម្តង ។ ដូចនេះគ្រប់ចំការត្រូវធ្វើកន្លែងជួរការពារភ្លើងទុកផង ជាពិសេសនៅក្នុងរដូវហួតហែង ស្មៅស្ងួតធ្វើជាពន្លកភ្លើងបានងាយ ទើបចំការខ្លះអាចមើលការពារស្មៅបាន ប៉ុន្តែចំការក្នុងភូមិផងរបងជិតខាងគ្នា អាចព្រងើយកន្តើយ ។ លុះដល់រដូវក្តៅហួតហែងងាយកើតភ្លើងឆេះរាលដាលចូលមកបាន ។ ធ្វើកន្លែងជួរការពារភ្លើងឆេះដោយភ្ជួរជ្រោយដី ឬចាក់ថ្នាំសម្លាប់ស្មៅក្នុងបរិវេណចំការ អោយស្រឡះ 3-4 ម៉ែត្រ យ៉ាងតិច ។ អាចដាំដើមដំបងយក្សកាត់ដើមជាជួររបងដោយដាំជិតៗគ្នា ហើយចាំកាត់តែងជានិច្ច ក៏ប្រើជាកន្លែងជួរការពារភ្លើងឆេះ ឬបន្ថយកម្លាំងខ្លាំងរបស់ភ្លើងអោយចុះបានល្អ ។



ចំការអំពិលផ្អែមនៅដីទីទំនាប

---

<u>ការអោយទឹក</u> :

ទោះបីជាអំពិលជារុក្ខជាតិធន់និងភាពហួតហែងបានក៏ដោយពិតមែន ប៉ុន្តែគួរត្រៀមរៀងទឹកផង ។ ក្នុងរយៈពេលដាំថ្មីៗបើភ្លៀងមិនធ្លាក់ ចាំបាច់ត្រូវស្រោចទឹកជារៀងរាល់ថ្ងៃប្រហែលមួយសប្តាហ៍រហូតទៅដល់ដើមតាំងជីហារបាន ។ តពីនោះអាចខានពេលវេលាស្រោចទឹកអោយឃ្លាតជាងមុនអាច 3 ថ្ងៃ ឬ 7 ថ្ងៃម្តង ។ តាមធម្មតាលុះអាយុបានមួយឆ្នាំក៏ឈប់ការអោយទឹកបាន ។



ចំពោះអំពិលផ្អែមដែលធំហើយ ប្រហែលនឹងជាប់គួរធម្មជាតិ ឬនិស្ស័យរបស់អំពិលផ្អែមត្រូវការផ្កាកការផុះលូតលាស់ធំច្រើន ឬអោយប៉ះដង្កិចហួតហែងខ្លាំងៗរហូតមួយរដូវក្តៅ ហើយបានទទួលទឹកពេញលេញនៅក្នុងរដូវភ្លៀង ។ ប្រមូលផលរដូវវស្សារដល់ដើមរដូវប្រាំងរួចទៅផ្កាកសំរាកការផុះលូតលាស់វិលវល់រហូតទៅយ៉ាងនេះ ។ ដូចនេះការអោយទឹកអំពិលទើបត្រូវធ្វើអោយអនុលោមទៅតាមវដ្តចក្រ (ការវិលត្រឡប់) ដូចពោលមកហើយនោះគឺ :

កាលណាអំពិលផ្អែមឃែកត្រួយ ឬមុនបែកត្រួយ (ក្រោយពេលជំរុះស្លឹកចោលអស់ហើយ) រយៈពេលនេះជារយៈពេលនៃការចំរើនលូតលាស់តាមមែក និងស្លឹក គឺពម្រូវការអោយទឹកច្រើន រវាងចន្លោះពេលចុងខែមេសា ដល់ខែឧសភា ។ បើចន្លោះពេលនេះភ្លៀងមិនធ្លាក់ត្រូវតែអោយទឹកបានពេញលេញ (បើសិនជាចំការចាស់ ធ្លាប់មានការបេះប្រមូលផលហើយ ក៏លែងអោយអំពិលផ្កាកសំរាកការផុះលូតលាស់មិនត្រូវស្រោចទឹកទេ ទាល់តែអំពិលផ្លាស់ស្លឹកអស់ទាំងដើម ហើយបុិចត្រួយ) ចន្លោះពេលនេះកុំអោយខាតទឹកជាដាច់ខាត ។

ក្រោយពីពេលនោះស្លឹកអំពិលនិងចាប់ផ្តើមចាស់ ហើយចាប់ចេញផ្កា ។ នៅពេលដែលចេញផ្កាអោយទឹកទៅរហូត ។ លុះផ្កាចាប់ផ្តើមរីកគួរបន្ថយទឹក ។ អាចឆ្លោះរយៈថ្ងៃទៅមួយថ្ងៃ ឬលះបង់អោយទឹកប្រហែល 2-3 ខែ ទាល់តែផ្សំកេសរជាប់ទើបសឹមអោយទឹកម្តងទៀត ការអោយទឹកក្នុងចន្លោះពេលនេះត្រូវអោយសន្សឹមៗបន្តិចម្តងៗទៅសិន កុំបណ្តោយអោយស្ងួតហួសពេក ហើយតាំងអោយទឹកភ្លាមមួយរំពេចនោះពីព្រោះនឹងធ្វើអោយផ្លាស់ប្រែខ្លួនមិនទាន់ធ្វើអោយផ្កាជ្រុះបាន បានសេចក្តីថាចន្លោះពេលចេញផ្កានេះ បើគេអោយខាតច្រើនហួសពេកទាន់ហន់ភ្លាមនោះ ក៏ជាហេតុបណ្តាលអោយផ្កាជ្រុះបានទាំងអស់ ។ ទោះយ៉ាងណាក៏ដោយចន្លោះពេលនោះអំពិលផ្អែមកំពង់ដាំ តែងតែបានទទួលទឹកភ្លៀងធម្មជាតិទៅហើយ (ចុងខែឧសភា) ។ លុះចូលចុងខែមិថុនា ដល់ខែកក្កដា ភ្លៀងច្រើនពេកផ្កាកចាំបាច់ត្រូវស្រោចទឹកអោយទៀត ។ កាលណាឃើញថាខាតទឹកក្នុងពេលដូចបានពោល

នោះ បើកើតហួតហែងក្នុងរយៈពេលជាប់ផ្កា អំពិលនឹងមិនជាប់ក្លរទេ ព្រោះផ្កានឹងជ្រុះ ។ ចាំបាច់ត្រូវអោយទឹកក្នុងរយៈពេលដែលចេញផ្កាផ្សំកេសរហើយក៏ត្រូវអោយទឹកជួយផង ។

តាមការអង្កេតបានឃើញថា បើឆ្នាំដំបូងណាដែលភ្លៀងក្រធ្លាក់មក ការផ្អាកនៃការដុះលូត-លាស់នៃអំពិលនឹងយូរ ។ ការបែកត្រួយ និងចេញផ្កាយូរជាងធម្មតា ឬបើភ្លៀងធ្លាក់ជារយៈៗមករហូតធ្វើអោយកើតផ្កាឡើងមកច្រើនសារ ជាបញ្ហាក្នុងការរក្សាថែទាំផ្កា និងក្លរ ។ ក្នុងមួយសារៗនឹងទុំមិនស្មើ ។ ដូចនេះក្នុងចន្លោះចុងខែមេសា រហូតដល់ដើមខែឧសភា បើភ្លៀងពុំធ្លាក់ ឬធ្លាក់ពុំគ្រប់គ្រាន់ចាំបាច់ត្រូវអោយទឹកអោយបរិបូរណ៍ក្នុងចន្លោះពេលនេះ អាចជំរុញអោយអំពិលផ្អែមពូជស្រាល ដូចជាពូជស្រីឆុមភូ ពូជទឹកឃ្មុំ ចេញក្លរនិងចាស់មុនរដូវធម្មតាបាន ។

ចន្លោះពេលពទៅ ជាចន្លោះពេលដែលស្ថិតនៅរវាងចន្លោះពេលជាប់ក្លរខ្ចី ហើយរហូតចន្លោះនៃរដូវ ការចំរើនលូតលាស់ធំនៃក្លរ ក្នុងពេលដែលជាប់ក្លរក្តិបថ្មីៗនិងជ្រុះច្រើន ។ ដូចនេះត្រូវអោយទឹកអោយច្រើន ដើម្បីអោយផលផ្លែពេញលក្ខណៈបរិបូរណ៍ បានន័យថាក្រោយពីពេលដែលផ្កាអំពិលផ្អែមផ្សំជាប់ហើយ ហើយចាប់ផ្តើមចិញ្ចឹមក្លរចាំបាច់ត្រូវអោយទឹករហូតគ្រប់ពេលវេលា បើភ្លៀងពុំធ្លាក់ទាំងនេះដើម្បីការពារក្លរជ្រុះ ឬក្លរបែក ពីព្រោះបើបណ្តោយអោយខាតទឹក ឬអោយទឹកមិនបានស្មើ លុះចូលចន្លោះខែកញ្ញា ដល់ខែតុលាជាចន្លោះពេលភ្លៀងធំមក ធ្វើអោយអំពិលបានទទួលទឹកច្រើនហួសពេកទាន់ហាន់ ក្លរកើតពង្រីកខ្លួនមិនទាន់ បណ្តោយអោយក្លរបែកច្រើនជាពិសេសគឺពូជហ្វិនចុង ។

ប៉ុន្តែលុះក្រោយពីការជាប់ក្លរ គ្រាប់ចាប់ផ្តើមប្រែពណ៌ត្នោតទៅជាពណ៌ខ្មៅ ត្រូវលះបង់អោយទឹកជាដាច់ខាត បណ្តោយអោយក្លរចាស់មែនទែនរហូតដល់ពេលប្រមូលផល ។ លើសពីនេះទៅទៀតក្នុងរយៈពេលក្លរទុំ ពុំគួរអោយត្រូវទឹកសោះឡើយ ព្រោះទឹកនឹងចូលទៅជុំវិញ

អោនសែម ដែលបំផ្លាញជាតិស្ករ ធ្វើអោយសាច់អំពិលមានរសជាតិជូរជើមអំពិលធំ ហើយមិនត្រូវការសំណើមច្រើនទេ ។

ក្រោយពីប្រមូលផលហើយក៏លែងអោយអំពិលផ្អែមផ្អាកការដុះលូតលាស់ មិនត្រូវស្រោចទឹករហូតដល់អំពិលផ្អែមជំរុះស្លឹកពេញអស់ទាំងដើម មានការបែកត្រួយថ្មីទើបចាប់អោយទឹកតទៅអោយបានពេញបរិបូរណ៍ជាវង់ចរដើមដូចនិងរយះពេលដំបូង ។

<u>ការដាក់ជី</u> :

ជាបច្ច័យសំខាន់យ៉ាងក្រៃលែង ដែលមានផលទាក់ទងទៅនិងការដុះលូតលាស់នៃរុក្ខជាតិទូទៅ ការដាក់ជីជួយអោយអំពិលផ្អែមដុះលូតលាស់លំរបរែល រឹងប៉ឹងហើយអោយផលិតផលខ្ពស់ ផលិតផលមានគុណភាពខ្ពស់ ផ្លែធំ សាច់ក្រាស់ រសជាតិផ្អែម ។ ជីដែលប្រើចែកចេញជាពីរប្រភេទគឺ :

① <u>ជីសរីរាង្គ</u> (ជីធម្មជាតិ) : គឺជាជីដែលបានមកពីវត្ថុមានជីវិតទាំងរុក្ខជាតិ និងសត្វដែលបានប្រែប្រួលរូប ឬត្រូវផ្អាប់អោយទាល់តែរលួយពុកអស់ហើយ ទាល់តែស្ថិតនៅក្នុងសភាពដែលរុក្ខជាតិយកទៅប្រើជាប្រយោជន៍ ដូចជាស្លឹកឈើពុក ជីផ្អាប់ និងអាចម៍សត្វផ្សេងៗ ។

② <u>ជីអសរីរាង្គ</u> (ជីគីមី) : ភាគច្រើនជីប្រភេទនេះបានមកពីរោងចក្រឧស្សាហកម្ម មានធាតុអាកាសខ្ពស់ជាងជីសរីរាង្គ និងមានជាតិអាហារដែលក្នុងរូបដែលអាចធាប់រលាយទឹក ទើបរុក្ខជាតិនាំអោយទៅប្រើបានមួយរំពេច ។

ដើមអំពិលផ្អែមដែលដាំថ្មីៗអាយុបាន 1-2 ឆ្នាំ គួរដាក់ជីអាចម៍គោ ជីផ្កាប់ អាចដាក់លាយជាមួយជីគីមីដែលមានជាតិនីត្រូហ្សែនខ្ពស់ៗ ឬជី 12-24-12 ក្នុងមួយដើមអត្រា 450 ក្រាម (ប្រហែលមួយកំប៉ុងទឹកដោះគោ) ក្នុងឆ្នាំដំបូងបែងដាក់បីដង (មួយដងបួនខែ) ចំនួន 100, 150-200 ក្រាម តាមលំដាប់ ។ ក្នុងឆ្នាំតទៅត្រូវបន្ថែមជីច្រើនឡើងតាមចំនួនអាយុដែលច្រើនឡើង ។

កាលណាអំពិលពេលចូលឆ្នាំទី 3-4 ឬជាប់ផ្លែហើយ គួរដាក់ជីលាយដែលមានផូស្វ័រ និងប៉ូតាស្យូមខ្ពស់ដូចជា 12-12-17, 13-13-21 ឬ 14-14-14 ដោយបែងដាក់គឺរយៈពេលដើមភ្លៀង និងចុងភ្លៀងដែលនឹងជួយអោយជាប់ផ្លែបានច្រើន និងជួយអោយផ្អែមផង ។ អត្រាដាក់គឺក្នុងមួយឆ្នាំដាក់ពាក់កណ្តាលនៃអាយុដើមអំពិល ដូចជាដើមអំពិលអាយុបាន 2 ឆ្នាំ ដាក់ជីមួយគីឡូក្រាម ដើមអំពិមអាយុបាន 6 ឆ្នាំ ដាក់ 3 គីឡូក្រាម ។ សំរាប់អំពិលអាយុហួសពី 6 ឆ្នាំ ហើយមិនប្រកាន់យកគិតដូចពោលនោះទេ ។ បរិមាណជីដែលដាក់ស្រេចតែប្រភេទដី និងលក្ខណៈរបស់ដី ។ ចំណែកឯការដាក់ជីឥន្ទ្រីយវត្ថុនោះ អ្នកខាងខេត្តពេជ្របុរណ៍ប្រើអាចម៍មាន់ពង ដាក់ក្នុងមួយដើមប្រហែល 4 ធាវទីដីទៃអាចដាក់អាចម៍គោក៏បាន ប៉ុន្តែអាចម៍មាន់ត្រូវដាក់តិចជាងអាចម៍គោទៅដល់ 4 ធាវ បើដាក់អាចម៍គោគឺត្រូវដាក់ទៅដល់ 8 ធាវ ពីព្រោះអាចម៍គោគឺជាជាតិដែលមានធាតុជីច្រើន ។ ដើមអំពិលអាយុប្រហែល 8 ឆ្នាំ ដាក់ប្លាតពីគល់ដើមប្រហែលប្រវែង 6 ម៉ែត្រ ។ ដាក់អោយជុំវិញទំរង់គុម្ពដើម ។ គួរដាក់ប្រហែលនៅក្នុងខែមេសា ពីព្រោះជីឥន្ទ្រីយវត្ថុអ្នកនេះនាំដើមពេលស៊ីត្រូវទទួលទឹកភ្លៀងមករំលាយជី ។ ការដាក់មុនភ្លៀងធ្លាក់នឹងងាយស្រួលធ្វើការងារច្រើនជាង បើរង់ចាំអោយភ្លៀងធ្លាក់ហើយនោះនឹងត្រៀមកិច្ចការមិនទាន់ ពីព្រោះការងារនឹងច្រើនដែលហៅថាត្រៀមទុកជាមុន លុះដល់ភ្លៀងធ្លាក់ក៏បានស៊ីជីតែម្តង ។



ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តន៍ចំពោះអំពិលផ្អែមនាពេលបច្ចុប្បន្ននេះ ជាពិសេសជាអំពិលផ្អែមរដូវប្រាំង ។ ក្រោយពីប្រមូលផលហើយត្រូវធ្វើការកាត់តែងមែកតាមការចាំបាច់ ហើយមិនដាក់ជីអ្វីដែលមានជាតិនីត្រូហ្សែនសោះឡើយរហូតដល់រដូវប្រាំង ។ បើជាជីផ្កាប់ជីអាចម៍គោត្រូវហាមដាច់ខាត ពីព្រោះបណ្តាលអោយខូចខាតបាត់បង់សំនើមសំរាប់ការជាប់ផ្កា ។ អោយដាក់បានតែថ្មហ្វូសហ្វាតប៉ុណ្ណោះដែលមានហ្វូសហ្វ័រតែម្យ៉ាង ។ ការដាក់ជីអាចម៍គោរដូវប្រាំង លុះភ្លៀងធ្លាក់ជីនេះទៅចិញ្ចឹមត្រួយ កើតលេងស្លឹក ផ្កាតិចមិនសូវជាជាប់ផ្លែតាមការគួរ ការធ្វើអោយដីមានឥន្ទ្រីយវត្ថុច្រើនហួសពេក ជាការមិនល្អសំរាប់ការផលិតអំពិលតាមធម្មជាតិ ។ ការដោះស្រាយគឺពន្យាពេលវេលាដាក់ជីទៅធ្វើបានកាលណាអំពិលជាប់ផ្ការហើយ ហើយកុំដាក់ជីតាមដីច្រើនហួស ។

ក្រៅពីការប្រើជីឥន្ទ្រីយវត្ថុ និងជីគីមីដល់ដើមអំពិលផ្អែមហើយ អាចដាក់ជីតាមស្លឹកផងក៏បាន ពីព្រោះអំពិលផ្អែមចាត់ទុកជារុក្ខជាតិប្រភេទដែលឆាប់ទទួលជីបានល្អ ទាំងការប្រើតាមដីនិងការប្រើតាមស្លឹក ។ ម្យ៉ាងទៀតអំពិលមានតម្លៃថ្លៃទើបប៉ុនិងតម្លៃចុះទុន ។ សុំអោយត្រឹមតែផលិតផលល្អប៉ុណ្ណោះ ក៏សមស្របទៅនិងការដាក់ជីណាស់ទៅហើយ ។ ការដាក់ជីតាមដីនោះអាចមានបញ្ហាដីក្រួត ដីល្បប់ ដីគ្រួសក្រហម ចាប់យកធាតុរ៉ែជីម្យ៉ាងដូចជាហ្វូស-ហ្វ័រសទុក ។ ប៉ុន្តែបើនីត្រូសែន និងប៉ូតាស្យូមដីនិងមិនចាប់ប៉ុន្មានទេ លែងចេញមកអោយរុក្ខជាតិប្រើបានមួយរំពេច ការដាក់ជីតាមស្លឹកនិងគ្មានកើតបញ្ហានេះឡើងទេ ពីព្រោះរុក្ខជាតិឆាប់ទទួលជីដែលអោយតាមស្លឹកបានលទ្ធផលតាមរូបមន្តដែលប្រើ កាលណាកសិករយល់ប្រព័ន្ធអោយជីតាមស្លឹកច្បាស់ល្អ ក៏អាចនាំយកមកជួយផលិតអំពិលផ្អែមបានល្អប្រសើរឡើង ។ រូបមន្តជីដែលលើកជាគំរូមកក៏គ្រាន់តែជាឧទាហរណ៍មួយប៉ុណ្ណោះ ។

រយៈនៃការជុះល្អិតលាស់ធំនៃអំពិលដែលនឹងដាក់ជីបាន ស្ថិតនៅក្នុងដំណាក់ការដែលគួរលែងផ្អាកការជុះល្អិតលាស់ក្នុងរដូវប្រាំង ។ លុះភ្លៀងធ្លាក់បែកត្រួយចាប់ចេញផ្កា ចាប់ជាប់ផ្ការ ផ្ការតូច ផ្ការមធ្យម ផ្ការធំ ក៏គួរអោយជីដែលមានរូបមន្តខុសពីគ្នាគឺ :

① រយៈពេលផ្កាកការដុះលូតលាស់ : តាមធម្មតាមិនបាច់ប្រើជីទេ ។ តាមដីក៏កាន់តែមិនបាច់ដាក់ជីទៅទៀត បណ្តាលអោយដីស្ងួតបែបហ្នឹងទៅចុះ ។ បើដាក់ជីតាមស្លឹកក៏ប្រើរបមន្តតួលេខកណ្តាលខ្ពស់ដូចជា 11-45-11 ឬ 10-52-17 ដាក់ 2-3 សប្តាហ៍ម្តងដើម្បីត្រៀមអោយអំពិលប្រុងចេញផ្កា ។

② រយៈពេលបែកត្រួយ : ចូលក្នុងរដូវភ្លៀងកាលណាភ្លៀងធ្លាក់ អំពិលក៏បែកត្រួយហើយតមកក៏ចេញផ្កា រយៈពេលនេះត្រូវប្រើជីហ្វូសហ្វរុសខ្ពស់ ដូចជាជីតាមស្លឹក 11 45-11 ឬ 10-52-17 ជួយជំរុញអោយចេញផ្កា និងជាប់ក្ខរបានច្រើន ប្រើរៀងរាល់ 7 ថ្ងៃម្តងៗ ។

③ រយៈពេលចាប់ចេញផ្កា : នៅតែប្រើប្រាស់រូបមន្តលេខដដែល 11-45-11 ដូចដើម ឬអាចប្រើ 10-52-17 ឬ 15-30-11 ក៏បាន ។

④ រយៈពេលចាប់ជាប់ក្ខរ : ផ្កាអំពិលចេញជាចង្កោម ក្នុងមួយចង្កោមមានច្រើនជាង 10 ផ្កា ។ ចាប់ផ្តើមរីកពីផ្កាតាមគល់ចង្កោមចេញចុះទៅដល់ចង្កោមជាលំដាប់ ។ មួយចង្កោមសុំអោយជាប់តែមួយក្ខរបានហើយ កាលណាជាប់គ្រប់ចង្កោមពេញទាំងដើមទៅ ក៏មានក្ខរច្រើនសន្ធឹកសន្ធាប់ ។ កាលណាអំពិលចាប់រីកបានពាក់កណ្តាលដើម ឬហៅថាកំពុងរីកពេញពីក៏លាញ់សារៈជាតិជីបប៊ីរ៉េលលិន 1 អំពូល (50 មិល្លីលីត្រ) លាយទឹក 100 លីត្រ (5 ប៉ោត) បាញ់ 1-2 ដង រយៈពេលគ្នា 7-10 ថ្ងៃ ។ អំពិលក៏និងជាប់ក្ខរស្មើៗល្អ ហើយក៏បំរុងរីកធំបានយ៉ាងឆាប់រហ័ស ។

⑤ រយៈជាប់ក្ខរតូច : ប្រើជីដែលជួយជំរុញអោយឆាប់ធំដូចជា 30-20-10 ចំនួន 2-3 ស្លាបព្រា លាយទឹក 20 លីត្រ ឬប្រើជី 46-0-0 ចំនួនមួយស្លាបព្រាបាយ រួមជា

មួយជីពាមស្លឹក 20-20-20 ឬ 15-15-15 ចំនួនមួយស្លាបព្រា លាយទឹក 20 លីត្រ ក៏បាន ។ ប្រើបែបនេះរយៈពេល 7-10 ថ្ងៃ ម្តងរហូតដល់ក្ងួរធំមធ្យម ។

៦ រយៈពេលក្ងួរធំមធ្យម : ពាមធម្មតាជីលេខរូបមន្តប៉ុនគ្នាទាំងបីដូចជា 20-20-20 ឬ 15-15-15 ក៏បានតាមអត្រាដែលកំណត់ក្នុងស្លាក រហូតដល់ក្ងួរធំ ។

៧ រយៈពេលក្ងួរធំ : កាលណាក្ងួរធំហើយ ដាក់ជីជួយជំរុញបំប៉នបង្កើតជាតិស្ករ ដោយដាក់ជីលេខចុងខ្ពស់ ដូចជាជីពាមស្លឹក 12-22-32 ឬ 6-30-30 ត្រូវប្រយ័ត្នកុំអោយមានទិន្នរហៀនអោយជាប់នៅច្រើនហួសពេក រយៈពេលជិតចាស់ ពីព្រោះនិងធ្វើអោយអំពិលជូរពេក ។

សំរាប់ការលំអិតនៃការដាក់ជីគីមីនោះ ជីគីមីលក់នៅផ្សារតាមច្រើនរូបមន្ត ការជ្រើសរើសប្រើអោយសមស្រប និងជួយបន្ថែមក្នុងការដុះលូតលាស់ដំនៃដើមអំពិលផ្អែម ការចេញផ្កា ការជាប់ក្ងួរ ការអោយផលិតផលមានគុណភាពខ្ពស់បានយ៉ាងល្អប្រសើរ ។ រូបមន្តជីដែលណែនាំអោយជ្រើសរើសប្រើសំរាប់អំពិលផ្អែមសរុបមានដូចតទៅនេះ :



① អំពិលដើមតូច : រាប់ចាប់ពីដាំរហូតដល់អាយុបាន 2 ឆ្នាំ ប្រើជី 15-15-15 ឬ 16-16-16 ដាក់ជី 25-7-7 ឆ្លាស់ប្តូរមួយយាម ។ បើភ្លៀងអាចបំប៉ន 15-0-0 ខ្លះ ។

② អំពិលរដូវព្រាំងមុនធ្លាក់ភ្លៀង : ក្នុងដីមានជីវជាតិល្អបរិបូរណ៍ស្រេចហើយនោះប្រើជី 0-10-30 រួមជាមួយហ្វូសហ្វាត ។ កុំដាក់ជីដែលមាននីត្រូសែន ពរប់ដាក់ជីផ្កាប់ជីអាចម៍គោ ប៉ុន្តែបើមិនល្អ ដើមអំពិលមិនផ្លស់ត្រូវប្រើជី 12-24-12 ហើយដាក់ជីផ្កាប់ និងជីអាចម៍គោខ្លះបន្តិចបន្តួច ។

③ អំពិលជាប់ក្ទួរក្តិប : ប្រើជី 25-7-7 រួមជាមួយ 14-9-20 ឬ 16-11-14 ក៏បាន វិធីម្យ៉ាងប្រើ 0-10-30 ជារូបមន្តជីហារ ហើយបន្ថែមអ៊ុយរេ (UREA) ឬ 46-0-0 ជាជីជំរុញអោយក្ទួរចំរើនធំ ។ បើក្ទួរក្រធំក៏បន្ថែមអុយរេ (UREA) ថែមទៀត ធ្វើអោយឆាប់ធំ ។

④ អំពិលក្ទួរធំមធ្យម : ប្រើជីដូចគ្នាក្ទួរខ្ចី ប៉ុន្តែអាចប្តូរមកជាជីរូបមន្តស្មើគ្នាដូច 15-15-15 ឬ 16-16-16 ក៏បាន ។ បើស្លឹកអំពិលស្លេកមិនខៀវចាស់ អោយត្រឡប់មកប្រើ 16-11-14 ឬអ៊ុយរេ (UREA) រួមជាមួយ 0-10-30 ជំនួសវិញ ពីព្រោះមានម៉ានិស្យូមផង និងធ្វើអោយពណ៌ខៀវចាស់ប្រកបអាហារបានល្អ ក្ទួរនិងឆាប់ធំ ។

ចាប់តាំងពីពេលអំពិលចាប់ផ្តើមជាប់ក្ទួរក្តិបល្អហើយ គួរដាក់ជីនីត្រូហ្សែនអោយច្រើនបន្តិចទាល់តែហួសពីការត្រូវការនៃក្ទួរក្តិបរហូតពេលវេលា អោយមានអាការៈបែកត្រួយបន្តិចបន្តួចជានិច្ច ។

ប្រើរបៀបអោយជីបន្តិចម្តងៗច្រើនដង 2-3 សប្តាហ៍ រឹតតែល្អ រហូតដល់ក្នុរធំពេញ ទើងបានទំហំហើយឈប់អោយជីដែលមានទិត្រូហ្សែនទៀត ។

៥ អំពិលក្នុរធំ : ប្រើតែ 0-10-30 តែម្យ៉ាង រហូតអស់ភ្លៀងហើយ លែងអោយក្នុរចាស់ ។ សភាពដូចនេះគុណភាពល្អ រសជាតិផ្អែមមុត ។

៦ អំពិលរដូវប្រាំង : ប្រមូលផលហើយ លែងអោយផ្កាកដុះល្អពេលាស់ មិនដាក់ជីរហូតជិតដល់រដូវភ្លៀងទៀត ។

សរុបរូបមន្ត និងរបៀបប្រើសារៈជាតិគីមីបានដូចនេះគឺរូបមន្ត (លេខ) ក្នុមុខខ្ពស់ប្រើជំរុញការដុះចំរើនល្អពេលាស់ដ៏ដូចជា 30-20-10 រូបមន្តលេខស្មើគ្នាប្រើជាពាក់កណ្តាលទូទៅដូចជា 15-15-15 និង 20-20-20 រូបមន្តលេខកណ្តាលខ្ពស់ប្រើជំរុញផ្កាដូចជា 10-52-17, 11-45-11, 15-30-15, 17-30-17 រូបមន្តលេខចុងក្រោយខ្ពស់ប្រើជួយអោយកើតរសជាតិផ្អែមដូចជា 12-22-23 និង 6-30-30 ជាដើម ។

វិធីដាក់ជីដើមអំពិលអាយុ 1-2 ឆ្នាំ គួរប្រើវិធីរោយជុំវិញដើម ក្រោយពីដាក់ជី ស្រោចទឹក ដើមពីអាយុ 2-10 គួរប្រើវិធីបែបវង់ចិញ្ចៀន ។ ជីករងជុំវិញគល់ដើម ក្នុងជួរពាក់កណ្តាលរវាងគល់ និងជាយគុម្ពដើម ។ ដើមអំពិលអាយុ 10 ឆ្នាំ ឡើងទៅ ប្រើវិធីជីករណ្តៅនៅតាមបរិវេណក្រោមគុម្ពដើម ដាក់ជីយកដីលុប ស្រោចទឹក បើជារដូវភ្លៀងមិនបាច់ស្រោចទឹកក៏បាន ។

របៀបផ្តិតកាត់បន្លៀក មែកឈើបែកការបាកត្រូវមែក




1. កាត់ជិតភ្នែកហួសពេក. 2. កាត់ឆ្ងាយពីភ្នែកពេក.
3. បញ្ឆិតកាត់ទ្រេតខ្លាំងពេក ធ្វើឲ្យស្ងួតយ៉ាប់បំផ្លាញ 4. កាត់ត្រង់ជិតភ្នែកតាមរបៀប




ការកាត់តម្រឹមមែក ត្រូវធ្វើតាមវិធីកាល បើកាត់ត្រឹមត្រូវ បានល្អ រីឯរបួសពោកត្រូវប្រើថ្នាំបាញ់លើស្នាមនោះដើម្បីការពារមេរោគ បំផ្លិចចេញ។



ការកាត់តែងមែក :

ឈើផ្លែគ្រប់ប្រភេទ តែងតែមានការកាត់តែងមែកដែលជាលក្ខណៈចំពោះដើមទៅហើយ និងកាត់តែងតិចច្រើនប៉ុន្មាន ក៏ស្រេចតែប្រភេទនៃឈើផ្លែនោះ និងប្រភេទនៃដើមដែលអោយត្រូវផលដល់ការកាត់តែងមែកតាមលក្ខណណា ដែលកសិករអ្នកដាំត្រូវតែយល់ដល់ធម្មជាតិរបស់ពូជអំពិលនិមួយៗ ចន្លោះពេលវេលានៃការកាត់តែងមែក ។ វត្ថុបំណង គោលការណ៍នៃការកាត់តែងមែកមានដូចតទៅនេះ :

① ដើម្បីអោយដើមឈើមានគំរោងសាង គឺទ្រង់ទ្រាយរឹងប៉ឹង មាំមួន អាយុយឺនយូរ ការកាត់តែងមែកនេះ និងចាប់ផ្តើមធ្វើចាប់តាំងពីដើមឈើនៅមានទំហំនៅតូចនៅឡើយរហូតមក ។ ក្នុងរយៈពេលចាប់កាត់តែងមែកត្រូវជ្រើសរើសមែកណាដែលរឹងមាំល្អទុក កាលណាដើមធំឡើងគំរោងរបស់ដើមរមែងរឹងប៉ឹងមាំមួនល្អ ជាងពួកដែលមិនបានកាត់តែងមែក ។ ក្នុងការជ្រើសរើសមែកដើម្បីកាត់តែងនោះ ត្រូវជ្រើសរើសមែកណាដែលបានមុំទូលាយ មែកមុំណាតូចៗគួរកាត់ចេញ ។ បើធ្វើបានដូចនេះនិងធ្វើអោយដើមឈើមានគំរោងទ្រង់ទ្រាយរឹងប៉ឹង មាំមួន មានអាយុយឺនយូរ ។

② ដើម្បីអោយដើមឈើមានគំរោងទ្រង់ទ្រាយសមស្របក្នុងការអនុវត្តន៍ការងារ ដែលជាការងាយស្រួលក្នុងការនាំយកគ្រឿងប្រដាប់ប្រដារផ្សេងៗចូលទៅក្នុងចំការ ដូចនេះ បាញ់ថ្នាំកំចាត់សត្វល្អិត ការបេះផ្លែ ការទល់មែក ។ កាលណាអំពិលផ្លែជាប់ការកាត់តែងមែកដែលល្អធ្វើអោយពន្លឺថ្ងៃចូលទៅបានពេញគុម្ពដើម ធ្វើអោយសំណើមក្នុងទំរង់គុម្ពដើមចុះថយ បន្ថយការកើតមេរោគផ្សិតផ្សេងៗនៃគួរអំពិល ។

③ ដើម្បីអោយផ្លែរាយស្មើគ្នា ការកាត់តែងមែកធ្វើអោយមែកបែករាយពេញទំរង់គុម្ពដើម ធ្វើអោយផ្លែអំពិលរាយសព្វពេញដើម មិនផ្លែស្វែះស្ងួតកកកុញ តែចំពោះមែក

ណាមួយប៉ុណ្ណោះធ្វើអោយមែកស្ថិតនៅក្នុងសភាពល្អបរិបូរណ៍ មិនអោយមែកខ្លះទទួលទំងន់ខ្លាំង គួរក៏មានសភាពល្អប្រហាក់ប្រហែលគ្នា ។

៤ ដើម្បីអោយគួរមានគុណភាពល្អកាលណាគួររាយសាយសព្វពេញទាំងដើម ហើយពន្លឺថ្ងៃក៏អាចចាំងចូលធ្លុះសព្វគុម្ពដើម ការរួមផ្សំពន្លឺក៏ប្រព្រឹត្តិទៅបានយ៉ាងពេញលេញធ្វើអោយផុះមានខ្នាតស្មើគ្នា សាច់មានគុណភាពល្អដូចគ្នាទាំងអស់ ។ ការកាត់តែងមែកគួរគិតដល់បរិមាណស្លឹកលើដើមផង ពីព្រោះបើស្លឹកនៅសល់តិចពេកនិងធ្វើអោយទំហំនិងគុណភាពគួរអន់ចុះ ។

៥ ដើមអោយគួរជាប់ស្មើៗគ្នារៀងរាល់ឆ្នាំ ។ ការកាត់តែងមែកនិងជួយដោះស្រាយបញ្ហាការចេញផ្កាខានឆ្នាំ ពីព្រោះមូលហេតុបណ្តាលអោយគ្មានផ្កាគ្មានផ្លែរាល់ឆ្នាំនោះបកពីការសន្សំធាតុអាហារពួកកាបូអ៊ីដ្រាត និនីត្រូសែនក្នុងដើមឈើ ។ បើរុក្ខជាតិបានអ៊ីត្រូសែនគ្រប់គ្រាន់មានកាបូអ៊ីដ្រាតខ្ពស់ និងធ្វើអោយការដុះលូតលាស់ជំល្អមល្អ ។ រុក្ខ-ជាតិក៏ចេញផ្កា ចេញផ្លែអោយគួរជាទីពេញចិត្ត ។ ដូចនេះការកាត់តែងមែកធ្វើមិនល្អគួរជាប់ច្រើនជ្រុលទាល់តែដើមទ្រោម រាប់ទាំងការអោយជីសមស្របផង ក៏និងដោះ-ស្រាយបញ្ហារៀងផ្កាខានឆ្នាំបាន ។ ការកាត់តែងមែកដូចដែលបានពោលមកហើយនិងធ្វើអោយអាហារនៅក្នុងដើមមិនត្រូវនាំទៅប្រើដោយគួរច្រើនហួសពេកទេ ដើមនៅតែល្អបរិបូរណ៍ ហើយចាប់ផ្តើមសន្សំអាហារទុកក្នុងដើមបានច្រើន ដើម្បីត្រៀមខ្លួនចេញផ្កាទាន់នៅក្នុងរដូវភ្លៀង ។ បើដើមទ្រុឌទ្រោមការចាប់ផ្តើមសន្សំអាហារក្នុងដើមយឺតយ៉ាវ ដើមពេលនៅមិនទាន់តាំងជីហារបានល្អក៏ដល់រដូវចេញផ្កាទៀតទៅហើយប៉ុន្តែដើមនៅមិនទាន់ល្អបរិបូរណ៍នៅឡើយទើបមិនចេញផ្កា ។ កាលណាដើមល្អបរិ-បូរណ៍នៅពេលតមកក៏ផុតរដូវចេញផ្កាទៅហើយ ។ ទីបំផុតក្នុងឆ្នាំតទៅទើបត្រូវខានជាប់ផ្កា ជាប់ផ្លែ អត់មួយឆាំទៅ ។

៧ ការពាររោគសត្វល្អិតកាលជាល ពេលកាត់តែងមែកត្រូវកាត់តែងមែកដែលមានរោគ និងសត្វល្អិតបំផ្លាញ ដើម្បីកុំអោយរោគឆ្លងទៅមែកដទៃផ្សេងទៀត ជាការកំចាត់សត្វល្អិតនៅក្នុងខ្លួន ។

អំពីវត្ថុបំណងដូចបានពោលមកហើយ ទើបត្រូវពិចារណាក្នុងការនាំយកទៅកាត់តែងមែកអំពិលផ្អែម ។ វិធីកាត់តែងមែកមានគោលការណ៍ដូចតទៅនេះ :

① អំពិលដើមតូចដែលទើបតែចាប់ផ្ដើមដាំក្នុងឆ្នាំដំបូង១ គួរកាត់តែងមែកបរិវេណគល់ដើមចេញកុំអោយមានមែកខ្នែង ។ កាត់ទំរង់គុម្ពដើមពីផ្ទៃដីប្រហែល 30 សង្ទីម៉ែត្រ ជាពិសេសអំពិលផ្អែមពូជណាយយ៉ាត់ (ពណ៌មាស) និងពូជហ្សិនចុង ។ ការបែកមែកមិនសូវមានរបៀបទេ ។

② អំពិលដើមធំហើយ ប៉ុន្តែនៅមិនទាន់ជាប់ផ្លែ ក្រោយពីដាំហើយបាន 6 ខែ ទៅ 1 ឆ្នាំ កាលណាឃើញថាដើមរឹងប៉ឹងមាំមួន បែកមែកច្រើន កាលណាចូលក្នុងរដូវភ្លៀងត្រូវកាត់ចុងមែកចេញដើម្បីអោយបែកមែកថ្មី ។ ក្នុងខណៈដែលបែកមែកថ្មីស្លឹកនឹងចាប់ផ្ដើមចាស់ ត្រូវកាត់មែកខ្នែងថ្នាក់ក្រោមចេញអោយអស់ ហើយចិញ្ចឹមមែកនិងធ្វើអោយដើមអំពិលផ្អែមមានទំរង់គុម្ពដើមសមរម្យល្អ ហើយក្នុងចន្លោះពេល 1-2 ឆ្នាំ មិនគួរអោយអំពិលចេញផ្កា ជាប់ផ្លែទេ គឺកុំអោយវាផ្លែ ប៉ុន្តែត្រូវកាត់តែងទំរង់គុម្ពដើមអោយមានរូបរាងទ្រង់ទ្រាយល្អ ។ លុះដល់ឆ្នាំទីបីទើបលែងអោយបែកមែកតាមតែវាដើម្បីអោយជាប់ផ្លែ ។

③ ធ្វើការកាត់តែងមែកនៅពេលអំពិលជាប់ផ្លែហើយ ។ គប្បីកាត់តែងមែកអំពិលផ្អែមរៀងរាល់ឆ្នាំ ដើម្បីអោយទ្រង់ទ្រាយល្អ ដោយកាត់តែងមែកដែលមានលក្ខណៈមិនសម

ស្របគឺមែកដែលរះរៀវរាបឫសពេក មែកដែលចាក់ចូលទៅក្នុងគុម្ពដើម មែកដែលដុះប្រជ្រៀងគ្នាមែកដែលរលោយស់បាក់ មែកដែលស្ងួតក្រៀម ងាប់ មែកដែលមានរោគ ។

កាត់ហើយប្រើថ្នាំទឹកល្អស្អិត ឬថ្នាំការពារផ្សិត លាបស្នាមកាត់ ដើម្បីការពាររោគផ្សិតដែលអាចកើតឡើងនៅពេលក្រោយ ។ មែកដែលបានកាត់ចោលគប្បីប្រញាប់យកទៅចោលក្រៅចំការដាំ ឬយកទៅដុតភ្លើងចោល ជាពិសេសមែកដែលមានរោគ ឬមានសត្វល្អិត ដើម្បីការពារការរាលដាលរោគ ឬសត្វល្អិត ។

បើដាំតាមប្រព័ន្ធដាំជិតៗគ្នា ត្រូវតែកាត់តែងមែកអោយខ្លាំងមែនទែន ។ បើបណ្តោយអោយមែកបៀតប្រជ្រៀតគ្នាណែនអំពិលនឹងមិនជាប់ផ្លែទេ ។ អំពិលតែងតែចេញផ្កាតាមមែកចាស់ ទើបមិនគួរកាត់មែកចោលដោយមិនចាំបាច់នោះ ។

<u>ការចេញផ្កា បំប៉នផ្លែអំពិល និងការចាស់នៃផ្លែអំពិល</u> :

យន្តការនៃការចេញផ្កា បំប៉នផ្លែអំពិល និងការចាស់នៃផ្លែអំពិល ។ អំពិលដែលបានផ្អាកការដុះលូតលាស់រហូតដល់រដូវប្រាំង និងចេញផ្កានៅដើមរដូវភ្លៀង ។ កាលណាផ្លែជាប់ហើយមិនបាច់ស្រោចទឹកទេ ពីព្រោះភ្លៀងធ្លាក់មកបណ្តើរៗរហូតដល់រដូវភ្លៀងនោះ ក៏ចាត់ទុកថាទឹកវាគ្រប់គ្រាន់ណាស់ទៅហើយ ។ លុះដល់អស់រដូវភ្លៀងផ្លែអំពិលក៏មានទំហំធំហើយអស់ភ្លៀងហើយនោះមិនមានន័យថាអស់ទឹកភ្លាមទេ គឺដីហួតទឹកអស់សន្សឹមៗដោយទឹកហូរចុះទៅកាន់ទីទំនាបខ្លះ រហើយចេញទៅតាមស្លឹកខ្លះ និងហើយចេញចំហាយតាមដីឡើងមកលើអាកាស ។ ក្នុងរយៈពេលនេះឯងជាពេលចាស់និងទុំនៃផ្លែអំពិលផ្អែម តាមធម្មតានៅក្នុងខែធ្នូ ខែមករា និងខែកុម្ភៈ ។

អំពិលចេញផ្កាចាប់ផ្តើមចេញនៅពេលអំពិលជំរុះស្លឹកចាស់អស់ហើយ ហើយត្រួយមកជំនួសប្រហែលនៅក្នុងខែមិនា រហូតដល់ចុងខែមេសា ។ ក្រោយពីនោះរីកផ្កាអំពិលនិងជុះលូតលាស់កើតទៅជាផ្លែ និងចង្កោមផ្កាបរិបូរណ៍នៅក្នុងខែឧសភា ហើយផ្កាអំពិលផ្លែមនិងចាប់រីកមានផ្សំពូជគ្នារវាងកេសរឈ្មោល និងកេសរញី ។ កាលណាការផ្សំជាប់ហើយក៏ចាប់ផ្តើមជាប់ផ្លែប្រហែលចន្លោះខែកក្កដា ហើយក្រោយពីនោះក៏គួរគប្បីយកចិត្តទុកដាក់មើលថែ-ទាំទឹកអោយបានទៀងទាត់ ។ កាលណាផ្លែអំពិលចាស់ហើយត្រូវឈប់អោយទឹកទៅ ។

នៅមុនពេលនេះគឺកាលណាស្ងួតនៅក្នុងរវាងពេលចេញត្រួយ បើដីមិនប៉ះពាល់ដោយដីអាចម៍គោ ដីផ្ទាប់ ដីគ្មានទិត្រូសែនជាប់នៅពីរដូវមុន ។ អំពិលមិនលេងទឹក និងចេញផ្កាជាប់ផ្លែក្ដីបងាយ ។ គេតែងតែឃើញថាចំការដែលមានដីអាចម៍ច្រើននៅក្នុងរដូវប្រាំងនិងចេញផ្កាតិច ឬទោះជាផ្កាច្រើនក៏មិនសូវមានជាប់ផ្លែដែរ មានស្លឹកច្រើន មានលេងស្លឹកអាចជួយបានខ្លះដោយការអោយដីហ្វូសហ្វរុសបាញ់ស្លឹកដូចជា 11-45-11 ឬ 10-51-11 ដាក់ពីរស្លាបព្រា លាយទឹក 20 លីត្រ អាចលាយសារៈជាតិធ្វើអោយសើមស្លឹក ដូចជាព្រៃ-ពាន់ស៊ីអេស 7 ទៀត 1 ស្លាបព្រាកាហ្វេ ធាតុប៉ី បន្ទាប់បន្សំពួកអ៊ុយនិលេពមួយភាគបីនៃស្លាបព្រាកាហ្វេ បាញ់ថ្នាំ 7 ថ្ងៃម្តង និងជួយអោយចេញផ្កាជាប់ផ្លែឡើង ជួយបន្ថយការលេងស្លឹក ។

ក្នុងដែលស្លឹកអំពិលច្រើនហួសពេក ពីព្រោះដាំនៅលើដីល្អហួសពេក អំពិលផ្លែមដែលទទួលបានទឹកច្រើនហួសពេក ធ្វើអោយផ្កាកការជុះលូតលាស់ក្នុងរដូវប្រាំង លុះដល់រដូវភ្លៀងពេញទាំងដើមមានតែស្លឹកខៀវស្រងាត់ ផ្កាតិច យើងអាចកំចាត់បន្ថយ ផ្នែកស្លឹកខ្លះ ដើម្បីអោយបែកស្លឹកព្រមជាមួយចេញផ្កា ប្រើដីដែលគ្មានទីត្រូសែនដូចជា 0-10-30 ចំនួនមួយគីឡូក្រាម លាយទឹក 20 លីត្រ ក្នុងអោយរលាយចូលគ្នាយកកករចេញយកតែថំណែកថ្លាបាញ់ជារូបកាកបាទ ឬបាញ់ជាចំណុចៗលើដើមស្មានអោយត្រូវស្លឹកប្រហែលពាក់កណ្តាលទាំងអស់ ។ អំណើះតមកស្លឹកផ្នែកនេះនិងជ្រុះ ស្លឹកដែលមិនត្រូវមិនជ្រុះទេ ។ ចុងមែកខ្ចី

ទងខ្សែរអាចងាប់ទៅខ្លះក៏មិនជាអ្វីទេ ទង មែកពណ៌ត្នោតមិនងាប់ ទើបបែកត្រួយសារថ្មី ហើយកើតផ្កាថែមឡើង ។ ចាប់ធ្វើតាំងពីរដូវភ្លៀង ដើម្បីកើតផ្កា ជាប់ ក្ួរផ្លែទាន់រដូវកាល ។

ទោះជាយ៉ាងណាក៏ដោយ មុននិងអំពីការជាប់ផ្កាតទៅ គួរដើម្បីជ្រាបអំពីនិស្ស័យរបស់ អំពិល គឺតាមធម្មជាតិរបស់អំពិលតែងតែមានការជំរុះស្លឹកចោលសិន មុននិងចេញផ្កាគឺអំពិល



ជំរុះស្លឹកបានត្រូវស្ថិតនៅក្នុងសភាពហួតហែងអោយបានយូរប្រហែល 1-2 ខែ នៅចន្លោះពេលដែលអំពិលផ្អែមផ្អាកការដុះលូតលាស់ក្នុងរដូវហួតហែង ប៉ុន្តែក្នុងទីកន្លែងខ្លះការជំរុះស្លឹកនៃអំពិល អាចប្រព្រឹត្តិទៅមិនបានល្អ ពីព្រោះដីខ្លះអាចនិងមានថ្នាក់ទឹកក្រោមដីច្រើន ទោះបីនៅក្នុងសភាពហួតហែងហើយ ប៉ុន្តែមានទឹកនៅក្រោមដីនៅឡើយ អំពិលក៏មិនអាចជំរុះស្លឹកចោលព្រមគ្នាបានឡើយ ដូចនេះកសិករអ្នកដាំត្រូវរកវិធីជួយអោយអំពិលជំរុះស្លឹកចោលព្រមគ្នាដោយប្រើវិធីដូចតទៅនេះ :

① បណ្តោយអោយអំពិលផ្អែមជំរុះស្លឹកខ្លួនឯងសិន កាលណាហួតហែង ។

② ប្រើវិធីជុតបំពក់ផ្សែងភ្លើង ធ្វើអោយស្លឹកអំពិលជ្រុះ ប៉ុន្តែវិធីនេះគេមិននិយម ព្រោះនឹងធ្វើអោយដើមអំពិលអន់ថ្រុឌទ្រោមបាន ។

③ ការប្រើអរម៉ូនបាញ់ អរម៉ូនដែលគេនិយមប្រើជាទូទៅគឺអិនអេអេ (NAA) ដែលមានឈ្មោះខាងពាណិជ្ជកម្ម (TradeMark) ថាផ្លែនណូហ្វិកដោយប្រើកំហាប់ 20-40 CC.លាយទឹកមួយប៉ោត ។ មុនប្រើអរម៉ូនត្រូវរង់ចាំមើលការជំរុះស្លឹកតាមធម្មជាតិទៅសិន រហូតទាល់តែអោយដឹងជាក់ក្នុងចិត្តថា បើបណ្តោយអោយជំរុះស្លឹកខ្លួនឯងតាមធម្មជាតិនោះ ប្រាកដជាមិនស្មើគ្នាទេទើបសឹមប្រើអរម៉ូនជួយជំរុះស្លឹក ។

ចំពោះកន្លែងទំនាបអាចធ្វើអោយទឹកជួយការចេញផ្កាបាន ។ អំពិលធំនិងចេញផ្កាបានល្អកាលណាប៉ះរយៈពេលហួតហែងខ្លាំង ហើយបានទឹកច្រើន ។ ដូចនោះកាលណាប្រមូលផលហើយត្រូវកាត់តែងមែកខ្លះតាមការចាំបាច់ ។ តពីនោះបូមទឹកចេញពីប្រឡាយអោយរីងស្ងួតអស់រហូតដល់មានខ្វះទឹក ដែលតាមធម្មតាក៏ល្មមក្នុងរដូវក្តៅ ហើយអាចរង់ចាំទឹកភ្លៀងធ្លាក់កណ្តាលខែមេសា ឬបូមទឹកបញ្ចូលក្នុងប្រឡាយអោយពេញរួចហើយស្រោចទឹកអោយសើមជោគ (ធ្វើដូចច្រូចខ្វិច) អំពិលនិងចេញផ្កាបាន

យ៉ាងពេញទី ។ រយះពេលនេះគួរអោយហូសហ្វាត ឬ 0-3-0 តាមដី ហើយបាញ់ 11-45-11 ឬ 10-50-10 ឬ 10-52-11 ព្រមទាំងអ៊ុយលិលេតអោយតាមស្លឹកផង ។

<u>ការជាប់ក្ដួរអំពិល</u> : អំពិលកាលណាចេញផ្កា និងផ្សំពូជកេសរពេញល និងកេសរញីរួច ហើយ ក៏ធ្វើអោយកើតក្ដួរអំពិលឡើង ។ ប៉ុន្តែជួនកាលទោះជាមានផ្កាច្រើនក្ដីក៏ពុំសូវជាប់ក្ដួរក៏មាន ។ កាលដែលជាប់ក្ដួរបាននោះ ត្រូវមានសត្វល្អិតដូចជាពពួកសត្វឃ្មុំជួយផ្សំកេសរផង និងជួយអោយជាប់ក្ដួរបានច្រើនឡើង ។ បើប្រើអរ័ម៉ូនពន្យាផ្កា ដើម្បីបន្ថែមពេលវេលានៅក្នុងការផ្សំពូជកេសរ ក៏អាចប្រើអរ័ម៉ូន NAA ដូចជាថែនថីរ ផ្លែនណូហ្វិក ឬហាន់នី ។ល។ ប្រើអត្រា 1 CC (ប្រហែល 10-15 ដំណក់) លាយទឹក 20 លីត្រ លាយព្រៃពាន់ស៊ុអេស 7 មួយស្លាបព្រាកាហ្វេ បាញ់ថ្នាំ 7 ថ្ងៃ ម្ដង ទាល់តែឃើញថាជាប់ក្ដួរច្រើនល្មម ។ អាចប្រើអ៊ុយនិលេត អត្រាមួយស្លាបព្រាកាហ្វេ ឬ មួយកញ្ចប់ទឹក 20 លីត្រ បាញ់រយះពេល 7 ថ្ងៃម្ដង ។

ចំពោះការប្រើជីក្នុងចន្លោះពេលដែលអំពិលជាប់ក្ដួររួច ហើយទើបជាពេលវេលាដ៏ល្អបំផុតក្នុងការដាក់ជីឥន្ទ្រីយវត្ថុផ្សេងៗ ដូចជាលាមកសត្វផ្សេងៗ ជីអាចម៍ គោ ស្លឹកពេរីពុករលួយ ជីវត្ថុសំណល់ពុករលួយជាដើម ។ ប៉ុន្តែត្រូវមើលសភាពដីផង ។ បើដីរឹងខ្លាំងពេកដីដែលខ្វះឥន្ទ្រីយវត្ថុពិតៗទើបគួរអោយ ។ បើអោយជីច្រើនរហូតដល់ចុងរង្វង់ភ្លៀងក៏នឹងត្រូវមានសល់ជីឥន្ទ្រីយវត្ថុ បណ្ដាលអោយរសជាតិអំពិលចេញជូរ ហើយឆ្នាំ ក្រោយនិងលេងស្លឹក ។ កណ្ដាលរដូវភ្លៀង ចុងរដូវភ្លៀង មិនគួរដាក់ជីផ្ទាប់ ជីអាចម៍គោជាច់ខាតដើមដែលលែងស្លឹក ដើមដែលក្ដួរចាស់ ក្លាយជាជូរត្រូវឈប់ដាក់ជីផ្ទាប់ ជីអាចម៍គោយ៉ាង តិចណាស់ 3-5 ឆ្នាំ ។

បំណែកជីគ្រាប់តាមដី មើលតាមលក្ខណៈដើម ។ ដើមស្លឹកខៀវស្រងាត់ លេងស្លឹក ក្លូរតិច អោយប្រើ 0-10-30 បើក្លូរច្រើនព្រៃងអាហារមិនគ្រប់គ្រាន់ល្មមប្រើ ក៏អោយប្រើ 0-10-30 ហើយពាចជីអ៊ុយរ៉េ (UREA) ឬ 46-0-0 ជំរុញបំប៉នក្លូរបន្ថិចម្តងៗ ។ អាចប្រើជីពួលេខមុខទាប ពួក្រោយខ្ពស់ក៏បានដូចជា 15-5-20+2, 8-24-24 ឬ 9-25-25 ពាបពន្លាប្រើពេម្តងនៅពេលក្លូរក្តិប ។

ជីពាមស្លឹកដែលនិងប្រើអាចជំរុញអោយក្លូរតូច ឆាប់ធំដោយប្រើ 30-20-10 កាលណានៅតូចប្រើ 20-20-20 ឬ 21-21-21 កាលណាក្លូរធំមធ្យម និង 12-22-22 កាលណាក្លូរធំអាចពាញ់ 2-3 សប្តាហ៍ ម្តង ឬកាលណាប្រើថ្នាំសម្លាប់សត្វល្អិត ឬពេលនៅតូចៗ ដែលឃើញថាក្លូរក្រធំពេក ។

ចំពោះធាតុវ៉ែបន្ទាប់បន្សំប្រើអ៊ុយនិលេពពាញ់រាល់ 3 សប្តាហ៍ម្តង ឬមួយខែក៏បានរហូតទៅជាប់ជិតចាស់ទើបពរប់ពាញ់ ។

<u>ការប្រើអ័រម៉ូនរុក្ខជាតិជួយអោយជាប់ផ្កា និងក្លូរ</u> :

អំពិលផ្អែមបុនចេញផ្កាត្រូវជំរុះស្លឹកចោលសិន មុននិងដល់ពេលចេញផ្កាបាន ប៉ុន្តែបើចេញផ្កាហើយ ផ្កាទៅជាជ្រុះធ្លាក់កាលណាប៉ះបង្អិចនិងការប្រែប្រួល ដូចជាធាតុអាកាសក្តៅត្រជាក់ ឬរុក្ខជាតិខ្វះអាហារ កាលណាកើតមានការប្រែប្រួលទាន់ហាន់នោះ ក៏និងធ្វើអោយផ្កានិងត្រួយអំពិលផ្អែមធ្លាក់ជ្រុះចុះពាន ។ ដូចនេះនាពេលបច្ចុប្បន្ននេះគេយកសារជាតិគីមីពួកអ័រម៉ូនផ្សេងៗ មកប្រើដើម្បីជួយអោយផ្កានិងក្លូរអំពិលផ្អែមជាប់ ។





អរ័ម៉ូនគឺសារៈជាតិដែលបញ្ជាការដុះលូតលាស់ធំធាត់នៃរុក្ខជាតិ ។ ទោះបីជាមានបន្តិចបន្តួចក៏អាចប្រែប្រួលសភាពម្យ៉ាងៗតាមភូតគាមសាស្ត្រនៃរុក្ខជាតិបាន ។ សារៈជាតិដែលបញ្ជាការចំរើនលូតលាស់ធំនៃរុក្ខជាតិបែងជាពីរពួកគឺ :

① សារៈជាតិប្រភេទបញ្ជាការចំរើនលូតលាស់ធំនៃរុក្ខជាតិ ដែលកើតឡើងតាមខ្លួនឯងតាមធម្មជាតិ ជាសារៈជាតិដែលសាងឡើងដោយខ្លួនឯង ដើម្បីបញ្ជាការចំរើនដុះលូតលាស់នៃសាច់ពោរ Tissue នៅក្នុងដើមរុក្ខជាតិ ។

② សារៈជាតិដែលបានមនុស្សបង្កើតឡើងដោយការផ្សំធាតុគីមីដូចជាអរ័ម៉ូន NAA ឈ្មោះពាណិជ្ជហៅថ្លៃនណូហ្វិកស៊ី ផ្លែនទិម៉ូន ក្រូផ្លាស់ ផែនថីរ ជីបបរ័លើន ។

ក្នុងនោះនឹងនិយាយអំពីអរ័ម៉ូនដែលមនុស្សបានបង្កើតឡើង ជាពិសេសអរ័ម៉ូន NAA ជីប្រើ-ល្បឿនដែលមានប្រយោជន៍ចំពោះអំពិលនោះ និងជួយអោយទងអំពិលស្វិតឡើងជួយជំរុញអោយក្លូរអំពិលចំរើនលូតលាស់ ជួយពន្យារយៈពេលវេលានៃការផ្សំកេសរ ។ សេចក្តីលំអិតក្នុងការប្រើអរ័ម៉ូនមានដូចតទៅនេះ :

① <u>ការប្រើអរ័ម៉ូន NAA</u> : អរ័ម៉ូន NAA មានឈ្មោះខាងពាណិជ្ជកម្មហៅជាទូទៅថា ផ្លែនណូហ្វិក ផ្លែនទិម៉ូន ក្រូផ្លាស់ ផែនថីរ ហាន់នី ហ្វិកស៊ីជាដើម ។ ការប្រើអរ័ម៉ូននេះត្រូវប្រយ័ត្នប្រយែងអត្រាភាគប្រើ ព្រោះប្រភេទនីមួយៗនោះមានកំហាប់ខុសពីគ្នា ។ មុនប្រើត្រូវសិក្សាពាក្យណែនាំចំណាំងជើងវិធីប្រើអោយបានហ្មត់ចត់សព្វគ្រប់ ។ ជាទូទៅអត្រាភាគដែលណែនាំអោយប្រើគឺ 1-2 CC លាយជាមួយទឹកមួយធុង ឬ 20 លីត្រ ។ ការប្រើកំហាប់ខ្ពស់អាចធ្វើអោយខូចខាតដល់ផ្កា និងក្លូរអំពិលបាន ។ សេចក្តីលំអិតក្នុងការប្រើគឺ :

ក. បាញ់មុនពេលអំពិលផ្អែមចេញផ្កា ឬចេញផ្កាខ្លះហើយ ប៉ុន្តែនៅពុំទាន់រីក ដើម្បីជំរុញការចំរើនលូតលាស់ធំ ។

ខ. បាញ់កាលណាផ្ការីកបានមួយភាគបួននៃផ្កាទាំងអស់នៅលើដើម ដើម្បីជួយអោយផលផលិតល្អឡើង និងជួយអោយទងស្វិត ។

គ. បាញ់កាលណាក្ញរអំពិលផ្អែមជាប់ទាំងអស់ហើយ ដើម្បីជំរុញការរីកចំរើនលូត-លាស់ធំនៃក្ញរអំពិលខ្ចី ។

② <u>ការប្រើជីវបៀរលៀនក្នុងចំការអំពិល</u> : តាមធម្មតាអំពិលផ្អែមក៏ដូចនឹងពូជដំទៃៗទៀត គឺមានការសាងសារៈជាតិជីវបៀរលៀននៅឯឫសដែលតមក និងបញ្ជូនពីឫសទៅបរិវេណចុងមែក និងជំរុញអោយចុងបែកត្រួយ ។ ជីវបៀរលៀនមួយភាគទៀត ត្រូវសាងឡើងពីគ្រាប់ដែលកំពុងដុះលូតលាស់ ជីវបៀរលៀនភាគនេះត្រូវបញ្ជូនទៅកាន់ទងមានផលជំរុញអោយរុក្ខជាតិនាំអាហារចូលទៅចិញ្ចឹមទង និងក្ញរដែលធ្វើអោយក្ញររីកចំរើនលូតលាស់តទៅ ។ តាមធម្មជាតិក្នុងការកសាងជីវបៀរលៀន ពេលដែលក្ញរចាប់ផ្តើមជាប់ពានថ្មីៗ គ្រាប់នៅមិនទាន់ពេញពានបរិបូរណ៍នៅឡើយ ។

ការសាងជីវបៀរលៀនអាចមានតិច បណ្តាលអោយក្ញរអំពិលចាប់ផ្តើមជ្រុះនិងក្រលូតលាស់ធំ ។ រយៈពេលនេះជាពេលដែលសមគួរនិងបានទទួលការជួយពីខាងក្រៅ ប៉ុន្តែកាលណាក្ញរធំឡើង គ្រាប់ក៏ធំឡើង ។ ហើយនិងមានការសាងសារៈជាតិជីវបៀរលៀនឡើងល្មមគ្រប់គ្រាន់ បើពុំចាំបាច់អ្វីត្រូវប្រើជីវបៀរលៀនពីខាងក្រៅចូលទៅជួយទៀតទេ គ្រាប់មានមុខនាទីសាងជីវបៀរលៀនដូចនេះទៅរហូតដល់ជិតចាស់ ការសាងសារៈជាតិជីវបៀរលៀនក៏ថយចុះ ក្ញរអំពិលក៏ថយអត្រាលូតលាស់ធំចុះ ទីបំផុតក៏មិនចាំបាច់សាងទៀត ក្ញរក៏ចាស់ដែលជាលក្ខណៈកើតឡើងតាមធម្មជាតិ ។

ក. ការប្រើជីប្បេរល្លិនដើម្បីជំរុញត្រួយ : ក្នុងពេលខ្លះយើងប្រទះឃើញថា កាលណាបានពេលប្រើរាហារដែលនៅក្នុងដើម រហូតសឹងតែអស់ពីដើមរលីង ឬក៏នៅសល់តិចបំផុតនោះអំពិលនឹងមានអាការៈទ្រោម ដូចដែលការអោយផលិតផលខ្ពស់ហើយ មិនបានអោយជីទូទាត់ពេញទី និងធ្វើអោយអំពិលនោះមិនអាចបែកត្រួយ ចេញផ្កា និងជាប់ផ្លែបានតាមប្រក្រតីឡើយ ឬមួយមានអាការៈងាប់មែក ពាក្យថា " មែកងាប់ " បានន័យថាកាលណាមែកសាងចុង សាងស្លឹកចេញមកថ្មីហើយ និងលូតលាស់ចំរើនបានមួយរយះ រួចក៏ងាប់ចុះមកពីចុង ។ អាការៈបែបនេះជាគ្រឿងចង្អុលអោយឃើញថា ដើមអំពិលនោះទ្រោមដល់កំណត់ហើយ បើគ្មានការថែរក្សាថែទាំបំប៉នអោយបានត្រឹមត្រូវទេ អាចបណ្តាលអោយដើមអំពិលនោះងាប់បាន ឬខូចខាតពេលវេលាលូតលាស់ 1-2 ឆ្នាំ ទំរាំតែបានដុះលូតលាស់ធំល្អបរិបូរណ៍ឡើងវិញ ហើយចេញផ្កាជាប់ផ្លែបានតាមប្រក្រតីធម្មតានោះ ក្នុងករណីដូចនេះ យើងគួរតែងតែមានការជំរុញអោយបែកត្រួយ ដោយៈប្រើជីប្បេរល្លិនផ្សំជាមួយជីផ្សេងៗ ធ្វើព្រមគ្នានិងការធ្វើអោយដីល្អពេញទី ។ រូបមន្តដែលប្រើបាញ់ស្លឹកពិសោធន៍ទៅឃើញថាបានផលល្អ គឺប្រើជីប្បេរល្លិនអំពូលបំណុះ 50 មិល្លិក្រាម ចំនួនមួយអំពូល ។ ជី 20-20-20 ចំនួន 50 ក្រាម ជីអ៊ុយរ៉េ (UREA) 46-0-0 ចំនួន 50 ក្រាម អ៊ុយនិលេតចំនួន 25 មិល្លិក្រាម និងព្រៃពាន់ស៊ីអេស 7 ចំនួន 25 CC លាយទឹក 100 លីត្រ ឬ 5 ប៉ោត ប្រើបាញ់ពាសពេញដើមទាំងដើម 1-2 ដង រយាលពីគ្នា 7 ថ្ងៃ រីឯតាមដីវិញអោយប្រើជីដែលមានធាតុរ៉ែជីគ្រប់ អាចជាជីរូបមន្ត 3 តួលេខ ដូចជា 12-24-12 ឬជីរូបមន្តតួលេខ 4 តួ 5-5-20 + 10 ឬជីរូបមន្តតួលេខ 5 តួរ ដូចជា 12-9-20 + 2 + 1 បាចពាសពេញក្រោមទំរង់គុម្ពដើមទាំងមូល រួចបាចហ្វូសហ្វាតដូឡូមិត ឬកំបោរដូឡូមិន ឬជីឥន្ទ្រីយវត្ថុអាចជាជីផ្ទាប់ ឬជីអាចម៍គោក៏បានដាក់ពីលើ រួចហើយស្រោចទឹកអោយសើមជោគ ។ កាលណាអោយជីតាមដី និងបាញ់ស្លឹកដូចនេះ ក៏នឹងធ្វើអោយអំពិលត្រឡប់ទៅជាបែកត្រួយ និងជាប់ផ្លែឡើង

វិញបានក្នុងរយៈពេលតមក ។ ការប្រើជីតាមជីផ្លូនទៀតនោះ ត្រូវមើលអាការៈដែលដើមអំពិលសំដែងចេញមកឃើញ (ថាមានលក្ខណៈបែបណាសិន) ។

ខ. <u>ការប្រេះជីបបិរលើន ជួយអំពិលអោយជាប់ក្តរច្រើនសារ</u> : បើអំពិលផ្តើមនោះមានសន្សំអាហារបានច្រើនបំផុត គឺធាតុអាកាសសមស្របល្អល្មម អំពិលក៏អាចជាប់ក្តរបានច្រើនស្ទើរស្ទួរតាមធម្មជាតិ ប៉ុន្តែដោយសារពេលបច្ចុប្បន្ននេះយើងតែងតែធ្វើអោយដើមរុក្ខជាតិធ្វើការផលិតយ៉ាងពេញបន្ទុក ទើបបណ្តាលអោយរុក្ខជាតិអស់កម្លាំង ឬប្រើការហួសកម្លាំងការចេញផ្កា ជាប់ផ្លែទើបមិនល្អដូចដែលបណ្តាយអោយប្រព្រឹត្តតាមធម្មជាតិ ធ្វើអោយមានការចាំបាច់ត្រូវជួយអោយអំពិលជាប់ក្តរ ដែលធ្វើបានដោយងាយដោយប្រើជីរបមន្តបាញ់ស្លឹក ដូចដែលប្រើក្នុងខទីពីរ ដើម្បីជំរុញអោយចេញត្រួយដូចពោលមកហើយ គឺប្រើជីបបិរលើនចំណុះ 50 មិល្លីក្រាម ចំនួនមួយអំពូល ។ ប្រើជី 20-20-20 ចំនួន 50 ក្រាម ជីអ៊ុយរ៉េ (UREA) ឬជី 46-0-0 ចំនួន 50 ក្រាម ប្រើអ៊ុយនិលេត 25 ក្រាម និងព្រៃតាន់ស៊ុអេស 7 ចំនួន 25 CC លាយទឹក 5 ប៉ោត ឬ 100 លីត្រ កូរអោយចូលគ្នាបានល្អ ដើម្បីបាញ់នៅពេលផ្កាអំពិលរីកពេញទំហឹងហើយ បើកាលណាក្នុងអំឡុងពេល 7-10 ថ្ងៃតមក មានចំនួនក្តរអំពិលដែលជាប់នៅមិនទាន់គ្រប់គ្រាន់ ត្រូវបាញ់ថែមម្តងទៀត ។ តាមធម្មតាបើធ្វើបែបនេះក៏នឹងធ្វើអោយជាប់ក្តរល្អបំផុត ។ ប្រសិនណាដើមអំពិលល្អបរិបូរណ៍រួចស្រេចទៅហើយនោះ គួរមើលសិនថានៅពេលផ្ការីកពេញផឹងហើយ បើជាប់ក្តរច្រើនល្មមហើយក៏មិនបាច់បាញ់ទៀតទេ ។ បើនៅមិនទាន់ច្រើនល្មមកាលណាបាញ់ហើយគួរស្ទង់ពិនិត្យមើលមុនក្នុងអំឡុង 7-10 ថ្ងៃ អោយដឹងថាការជាប់ក្តរនៅមិនទាន់ច្រើនល្មមនោះទេ សឹមបាញ់បន្ថែមជាលើកទីពីរ ។ ការដែលធ្វើយ៉ាងនេះក៏ដើម្បីការពារមិនអោយអំពិលជាប់ក្តរច្រើនហួសពេកទេ ដែលអាចលើសកម្លាំងដើម និងធ្វើអោយក្តរអំពិលតូច ។

គ. <u>គោលការណ៍ប្រើជីបប៊ីរលីនជាមួយនិងរុបមន្តផ្សេងៗ</u> : ជីបប៊ីរលីននោះតាមធម្មតាគ្រាន់តែជាសារៈជាតិជំរុញសកម្មភាពក្នុងរុក្ខជាតិ ពុំមែនជាអាហាររបស់រុក្ខជាតិដោយប្រការណាមួយទេ ។ រុក្ខជាតិទទួលជីបប៊ីរលីនបានល្អ លុះត្រាតែរុក្ខជាតិនោះមានអាហារសន្សំបានច្រើន មានភាពល្អបរិបូរណ៍ រឹងប៉ឹង មាំមួនពេញទី បើរុក្ខជាតិមានកម្លាំងទន់ខ្សោយ ឬទ្រោមខ្លាំង បើប្រើតែជីបប៊ីរលីនជាកត្តាជំរុញអោយរុក្ខជាតិធ្វើសកម្មភាព ប៉ុន្តែខ្វះអាហារផ្សំ ខ្វះជីនោះក៏ត្រឡប់ទៅជាធ្វើអោយដើមរុក្ខជាតិត្រូវប្រមូលអាហារដែលនៅសល់យកមកសាងត្រួយ និងចុងមែកថ្មី ដែលអាចត្រឡប់ទៅជាធ្វើអោយដើមរុក្ខជាតិអស់កម្លាំងយ៉ាងពិតប្រាកដ ទន់ខ្សោយរហូតដល់ងាប់ងាយ ។ គោលការណ៍ប្រើជីបប៊ីរលីនដ៏ត្រឹមត្រូវនោះគួរប្រើជាមួយរុក្ខជាតិដែលរឹងប៉ឹងមាំមួន ហើយបើប្រើជាមួយរុក្ខជាតិមិនរឹងប៉ឹងមាំមួនល្មមគ្រប់គ្រាន់ទេនោះ ក៏ត្រូវតែអោយអាហារ ឬធាតុរ៉ែជីតាំងតាមស្លឹក ទាំងតាមដីអោយបានបរិបូរណ៍ ព្រមទាំងស្រោចទឹកអោយសើមជោគ ទាល់តែអាចស្រូបយកជីចូលទៅប្រើបានយ៉ាងពេញបន្ទុក ។

សរុបសេចក្តីទៅការប្រើជីបប៊ីរលីនទៅលើអំពិលផ្អែម យើងអាចប្រើដើម្បីជួយជំរុញអោយបែកត្រួយ និងចុងត្រួយក្នុងអំពិលដែលធ្លាប់អោយផលផលិតច្រើនស្វេះស្វូវ និងកម្លាំងទ្រោមម្តងទៀត បើកាលណាអំពិលកំពុងចេញផ្កាពេញទំហឹង និងដើម្បីអោយផ្កាដែលកំពុងរីកបានជាប់ក្លូវអោយបានច្រើនគ្រប់គ្រាន់ទៅតាមតម្រូវការ ហើយរាល់ពេលប្រើជីបប៊ីរលីនគួរហិតខ្ជិនទាំងជី ទាំងទឹកផងយ៉ាងគ្រប់គ្រាន់ទើបបានផលល្អគួរជាទីពេញចិត្ត ។

<u>ការដោះស្រាយអំពិលផ្អែមជាប់ក្លូវច្រើនសារ</u> :

អ្នកកសិករដាំណាំអំពិលផ្អែមច្រើនគ្នា តែងជួបប្រទះបញ្ហាមានក្លូវអំពិលច្រើនសារលើដើមតែមួយ ឬនៅក្នុងចំការតែមួយ ។ ជួនកាលដើមវាជូវចេញផ្កាហើយ ផ្កាជ្រុះច្រើន

ពមកចេញផ្កាទៀតក្ទួរជាប់ខ្លះទៀត ជ្រុះខ្លះ ។ បែបនេះទៅរហូតដល់រដូវភ្លៀង ។ ករណីខ្លះអស់ហ្វូតហែងហើយអំពិលលើដើមនៅមានអំពិលទុំ នៅមានអំពិលទុំមិនទាន់អស់ក៏មានទើបចេញទាំងផ្កា និងមានក្ទួរនៅដើមតែមួយជាមួយគ្នានោះឯងតែម្តង ។

មូលហេតុមកពីកើតក្ទួរផ្លែច្រើនសារនោះឯង កើតពីព្រោះកាលណាអំពិលចេញផ្កាសាដំបូងក្នុងរយៈពេលដើមរដូវភ្លៀងនោះ ក្ទួរជាប់មិនច្រើនល្មមអាចមកពីលេងស្លឹក អាចខ្វះសារជាតិអ័រម៉ូន ឬខ្វះធាតុរ៉ែជីម្យ៉ាងណាមួយ ឬចំនួនទឹកភ្លៀងដែលមិនគ្រប់គ្រាន់មានភ្លៀងតិចហើយក៏បាត់ភ្លៀងទៅ ។ កាលណាជាប់ក្ទួរដំបូងតិចអំពិលក៏មានអាហារសន្សំគង់នៅធ្វើអោយមកចេញផ្កាទៀតក្នុងចន្លោះពេលរដូវភ្លៀងមក ឬកាលណាចេញផ្កាគ្រាដំបូងក្ទួរជាប់ខ្លះ ហើយក៏ដាក់ជីធ្វើអោយអំពិលទៅជាល្អបរិបូរណ៍ឡើង ហើយក៏មានភារៈតិច ឬក្ទួរជាប់មិនទាន់ច្រើនក៏ចេញផ្កាទៀតបណ្តោយតែម្តងទៅ ។ សភាពបែបនេះអាចកើតរហូតដល់រដូវភ្លៀង ទើបធ្វើអោយជាប់ក្ទួរផ្លែច្រើនសាទៅលើដើមជាមួយគ្នា ។



គុណវិបត្តិដែលកើតឡើងធ្វើអោយការរក្សាថែទាំការពារប្រព្រឹត្តទៅមិនស្រួល ទាំងរឿងប្រើជី ការអោយទឹក ឬអត់ទឹក ការកើតមេរោគផ្សិតស៊ីក្តួរអំពិលទុំច្រើនឡើង សត្វល្អិតស៊ីគ្រាប់អំពិលសារថ្មីច្រើនឡើងជាដើម ។ ក្នុងការអោយជីនោះក៏បានជ្រាបរាល់គ្នាហើយថា ការបំប៉នក្តួរក្តិបរអំពិលអោយធំល្អ ក៏ត្រូវអោយជីផ្កាប់ ជីអាចម៍គោខ្លះ និងជីគីមីប្រើនិត្រូហ្សែននាំដូចជា 16-11-14 + 2 ប៉ុន្តែបើនៅប្រើជីបែបនេះកាលណាក្តួរចាស់ជិតទុំ និងធ្វើអោយអំពិលទុំយូរជាងធម្មតា ហើយរសជាតិជូរច្រើនជាង ។ ធម្មតាដែលត្រឹមត្រូវនោះគឺកាលណាក្តួរជិតចាស់ យើងត្រូវឈប់អោយជីផ្កាប់ ជីអាចម៍គោ និងជីគីមីដែលមាននិត្រូហ្សែន ប៉ុន្តែអោយប្រែជី 0-10-30 ជំនួសវិញ ប៉ុន្តែបើនៅលើដើមមានក្តួរអំពិលនៅតូចពេក ការប្រើជីគ្មាននិត្រូហ្សែនក៏ធ្វើអោយក្តួរមិនធំ ។ បើយកទាំងពីរយ៉ាងត្រូវប្រើម្យ៉ាងកន្លះគឺ 15-5-20 + 2 កន្លះនិង 1-10-30 កន្លះធ្វើអោយក្តួរតូចធំទៅបាន ប៉ុន្តែក្តួរធំរសជាតិក៏ត្រូវអន់ចុះគឺជូរឡើង ។ ដូចនោះការមានក្តួរច្រើនសានៅលើដើមអំពិលតែមួយដើមនោះ ទើបធ្វើអោយខូចប្រព័ន្ធដាក់ជីដោយជៀសវាងពុំរួច ។

គុណវិបត្តិនៃប្រព័ន្ធអោយទឹកទំនាក់ទំនងដូចគ្នាដែរ ។ តាមធម្មតាកាលណាអស់ភ្លៀងក៏ចាប់ផ្តើមអត់ទឹកដល់អំពិលផ្អែមដោយស្វ័យប្រវត្តិ ដើម្បីថែមភាពផ្អែមអោយក្តួរអំពិលចាស់ ។ ប៉ុន្តែបើអត់ទឹកព្រាកដយ៉ាងនេះមែននោះក្តួរតូចក៏និងពុំសូវធំ ។ បើស្រោចទឹកអោយក្តួរតូចធំតទៅ ក្តួរធំក៏ទៅជាមានរសជាតិមិនល្អ គឺក្រទុំហើយជូរទៀតផង ។

គុណវិបត្តិដែលកើតអំពីការជាប់ក្តួរច្រើនសារដែលជួបប្រទះម្យ៉ាងទៀត គឺការកើតមេ-រោគផ្សិតស៊ីក្តួរទុំច្រើនឡើង រឿងនេះជួបប្រទះច្រើនក្នុងចំការ ក្តួរអំពិលមិនទាន់ចាស់ក៏ទុកបណ្តោយអោយនៅនិងដើមរហូតចូលរដូវភ្លៀងថ្មីមកដល់ ហើយក៏ចេញផ្កាជាប់ក្តួរសាថ្មីទៀតហើយ ក្តួរសាមុនក៏នៅខ្ចីនៅឡើយ មិនព្រមទុំ ក៏ទុកចោលលើដើម ។ ក្តួរអំពិលទាំងនេះច្រើនតែមកទុំនៅពាក់កណ្តាលរដូវភ្លៀង ក្នុងពេលភ្លៀងខ្លាំងជោគជាំ

មិនបានការ ឬបេះគួរផ្លែចុះមកទេ ។ កាលណាទុំក៏ផ្អែមមានជាតិស្ករ ក្លាយទៅជាសំបុកពួជមេរោគផ្សិត ធ្វើអោយមានផ្សិតនៅច្រើនលើដើមនោះជានិច្ច លុះគួរអំពិលសារថ្មីចេញមកក៏មានឱកាសបានទទួលមេរោគផ្សិតច្រើនសន្ធឹកសន្ធាប់ចាប់តាំងពីដើមទីមក ។

ការដោះស្រាយបញ្ហាចំពោះមុខ គួរកាត់ចោលនូវការចិញ្ចឹមទុកគួរមុន ដើម្បីនូវស្លឹកចេញអោយអស់ កុំអោយអំពិលចេញផ្កាតិច ដោយមកអំពីភារៈកិច្ចចិញ្ចឹមគួរធំនៅដល់ពេលជិតអំពិលចេញផ្កា ត្រូវបេះគួរអំពិលដែលនៅសល់ចេញអោយអស់ ទោះបីលក់ជាអំពិលខ្ចីបានប្រាក់តិចក៏ដោយ ហើយក៏បង្ហំបំប៉នអំពិលអោយប្រុងចេញផ្កាបានពេញលេញ តាមដីដាក់ផូហ្វូសហ្វាត ឬ 0-30-0 ចំណែកតាមស្លឹកបាញ់ជី 10-52-17 ឬ 11-45-11 ឬបើលេងស្លឹកប្រើ 0-52-34 ថែមអ៊ុយនិលេតផង ។ វិធីនេះនិងធ្វើអោយអំពិលប្រុងជាស្រេចដើម្បីសាងផ្កាបានយ៉ាងល្អបរិបូរណ៍ ។ លុះចេញផ្កាក៏ធ្វើអោយជាប់បានល្អទាំងអស់ ចាប់តាំងតែពីសាជីបួងមកតែម្តង ដូចជាការប្រើជីបបិរលីន (Gebberlline) ជាដើម ។

ការដោះស្រាយបញ្ហារយៈពេលវែងប្រហែលខែកុម្ភៈ ដល់ខែមិនា គួរកាត់តែងមែកតាមការចាំបាច់ ។ បើដីអន់ពេកហើយដើមខ្ទះនីត្រូហ្សែនត្រូវដាក់ហ្វូសហ្វាតជាមួយជីផ្កាប់ជីអាចម៍គោ និងជីគីមី ។ កាលណាភ្លៀងតិចពេកទៅផ្កាក៏ចេញពុំបានពេញលេញ បើធ្វើបានត្រូវស្រោចទឹកបន្ថែមអោយច្រើន ដើម្បីអោយចេញផ្កាអោយបានច្រើន ។ កាលណាផ្ការីកខ្លះហើយត្រូវមើលអោយដឹងថារីកស្មើគ្នាល្អទេ ។ បើពុំជាក់ក្នុងចិត្តត្រូវជួយជំរុញអោយការប្រុងរបស់ផ្កា និងបាញ់ជីអោយ កាលណាចាប់ផ្តើមចាក់ចង្កោមផ្កាដោយប្រើជីជីបបិរលីនខៀវវ៉ា 50 មិល្លិក្រាម មួយអំពូល ជី 6-32-32 ឬប្របាក់ប្រហែលគ្នា 25 ក្រាម អ៊ុយនិលេត 25 ក្រាម ត្រៃតាន់ស៊ីអេស 7 ចំនួន 15 CC ទឹក 100 លិត្រ ។ រយៈពេលនេះត្រូវជួយស្រោចទឹកអោយដីបានជោគច្រើនទើបល្អនៅពេលដែលផ្កាកំពុងរីកពេញទំហឹង និងគួរបាញ់ថែមម្តងទៀត ប៉ុន្តែអោយរយោពេពើ

គ្រាដំបូងប្រហែល 10 ថ្ងៃ យ៉ាងតិច ។ កាលណាជាប់ក្លូវក្តិបល្អិតៗហើយសូមអោយប្រើម្តងទៀត ប៉ុន្តែត្រូវផ្លាស់ជីពី 0-32-32 ទៅ 45-0-0 ជំនួសវិញ រីឯជីផ្សេងៗនៅដដែល ។

កាលណាក្លូវជាប់ល្អហើយអោយដាក់ជីតាមដី 15-5-20 + 2 ហ្វូសហ្វាត ជីផ្កាប់ ជីអាចម៍គោ ។ ដាក់រាល់ខែអោយទាល់តែក្លូវធំ ។ តាមស្លឹកប្រើជី 20-20-20 ចំនួន 100 ក្រាម អ៊ុយរ៉េ (UREA) 100 ក្រាម ផ្លែនណូហ្វិក 5 CC អ៊ុយនិលេត 25 ក្រាម ព្រៃពាន់ស៊ីអេស 7; 15 CC ទឹក 100 លិត្រ ។ បើឃើញក្លូវនៅតូចនៅឡើយ ប្រើជីបបរ៉លើនបន្ថែមទៀតចំនួន 50មិល្លិក្រាម មួយអំពូលជួយអោយធំស្មើគ្នាឡើង ។

កាលណាជាប់ក្លូវល្អតាំងតែពីដើមរដូវភ្លៀងហើយ អំពិលផ្អែមក៏ចេញផ្កាក្នុងសារក្រោយតិចណាស់ ។ ការបំរុងបំប៉នរក្សាថែទាំក៏សង្កត់ធ្ងន់ទៅលើក្លូវសាដំបូង (ឬសាដែលមានច្រើនបំផុត) យកជាការសំខាន់ ។ បើមាននៅសល់ក្នុងរដូវក្តៅក៏បេះលក់ជាក្លូវខ្ចីអោយអស់ ដើម្បីអោយអំពិលប្រុងប្រៀបខ្លួនជាស្រេចក្នុងសាបន្ទាប់ទៅបានពេញលេញ ។

<u>ការទុំនៃអំពិលផ្អែម</u> : បើសិនជាគ្មានបញ្ហាអ្វីៗកើតឡើងទេ ក្រោយពេលអំពិលផ្អែមជាប់ក្លូវហើយ ក្លូវអំពិលក៏ចំរើនធំឡើងៗជាដរាបទាល់តែដល់ចន្លោះខែវិច្ឆិកាក្លូវក៏ចាស់ បន្ទោះពេលនេះអស់រដូវភ្លៀងធ្វើអោយបរិមាណទឹកថយចុះ ដែលជារយៈពេលរដូវហួតហែងធ្វើអោយអំពិលផ្កាផុះល្អណាស់ធំ ធ្វើអោយក្លូវអំពិលផ្អែមទុំ ហើយចាប់ផ្តើមផ្អែមថែមឡើង ។

<u>ការទុំនៃក្លូវ</u> : អំពិលផ្អែមពូជទឹកឃ្មុំដែលទុំមុនពូជដទៃៗទៀតប្រហែល 4-5 ថ្ងៃ ។ អំពិលផ្អែមពូជស្រីធុមភ្វ ទុំតាមក្រោយប្រហែល 7 ថ្ងៃ ។ ទុំក្រោយរងចុះមកគឺពូជធន្ទលាំ ពូជខន្តី និងពូជហ្សិនចុង ។ ទុំចុងក្រោយបំផុតគឺពូជពណ៌មាស (ណាយយ៉ាត់)

ទោះជាយ៉ាងណាក៏ដោយការទុំនៃក្លូរអំពិលពុំមែនត្រូវតាមនេះរហូតទៅទេ ។ ជួនកាលក៏ស្រេចទៅលើសភាពដី ។ បើជាទីទួលតាមចង្កេះភ្នំ និងបានទទួលបរិមាណទឹកភ្លៀងមុនបរិវេណទីដីទំនាប ។ ការចេញផ្កាក៏លឿនជាងក្លូរមុន ។ លុះដល់ពេលទុំនៅទីទួលឆាប់ទុំជាង ។

តារាងការចេញផ្កា ជាប់ក្លូររបស់អំពិលផ្អែម

| ពូជ | ចេញផ្កា | ក្លូរទុំ |
|---|---|---|
| ពូជហ៊្សិនចុង | ខែឧសភា | ខែមករា |
| ពូជឥន្ទុណាំ | ខែឧសភា | ខែមករា |
| ពូជខន្តិ | ខែមេសា | ខែធ្នូ |
| ពូជទឹកឃ្មុំ | ខែមេសា | ខែធ្នូ |
| ពូជស្រីធុមភូ | ខែមេសា | ខែធ្នូ |
| ពូជប៉ាកឃុក | ខែឧសភា | ខែមករា |
| ពូជឈៀសេដ្ឋកិច្ច | ខែមេសា | ខែធ្នូ |
| ពូជពេជ្រក្បេត្រ | ខែឧសភា | ខែមករា |

ចន្លោះពេលដែលអំពិលផ្អែមទុំ ក្លូរអំពិលនិងបានទទួលបរិមាណអាហារមកចិញ្ចឹមក្លូរតូចៗពីព្រោះដើមផ្កាកការដុះលូតលាស់ធំ ទើបធ្វើអោយបរិមាណក្រូតស៊ីលហ្វូរិកក្នុងក្លូរអំពិលផ្អែមមានបរិមាណតិចទៅផងដែរ ហើយក្នុងចន្លោះពេលនេះក្លូរអំពិលផ្អែមក៏មានការសាងអេនស៊ែមឡើងក្នុងក្លូរ ធ្វើអោយរលាយបាត់ក្រូតស៊ីលហ្វូរិក អោយប្រែសភាពទៅជាស្ករទាំងអស់ ដោយហេតុនេះឯងទើបធ្វើអោយអំពិលផ្អែមមានរស់ជាតិទៅជាផ្អែម ។ ហេតុនេះ

ក្នុងរវាងរយៈពេលនេះត្រូវពរបស់អោយទឹកដាច់ខាត ព្រោះថាការប្រែប្រួលផ្លាស់ប្តូរនៃក្រូចស៊ុលហ្វ៊ួរិកអស់បាត់ទៅហើយក៏ពិតមែន ក៏ប៉ុន្តែដើមអំពិលបានទទួលទឹកក៏និងធ្វើអោយមានការបង្កើតក្រមស៊ុលហ្វួរិកឡើងមកទៀត ពីបើមានក្រូចនេះឡើងមកទៀត ក៏ធ្វើអោយអំពិលមានការផ្លាស់ប្តូរប្រែរសជាតិពីផ្អែមទៅជាជាតិជូរ ឬជូរអែម ដែលធ្វើអោយក្លូរអំពិលមានគុណភាពទាប តម្លៃធ្លាក់ ប៉ុន្តែអំពិលពូជខ្លះអាចមានរសជាតិជូរ លក្ខណៈបែបនេះក៏សំដែងអោយឃើញថាក្រូចស៊ុលហ្វួរិកក្នុងអំពិលផ្អែមនោះ ត្រូវរលាយបាត់ទៅអោយអស់ដោយអែនសៃម៍ ទើបធ្វើអោយមានរស់ជាតិជូរអែមជាប់មក ។

ការផ្លាស់ប្តូរប្រែអំពិលផ្អែម លក្ខណៈម្យ៉ាងទៀតគឺភាពជូរនៃអំពិលកាលណាក្លូរជិតចាស់ឬលហេតុមកពីនីត្រូហ្សែននៅសល់ក្នុងដីរលាយចេញមកពេលចាស់ កើតពីការប្រើជីផ្ទាប់ពីអាចម៍គោច្រើនហួសពេក ហើយបានទទួលទឹកទៀតនៅពេលជិតចាស់ ទើបក្លូរដាក់ជីអោយល្មមសមគួរ ។ កាលណាក្លូរក្តិបជាប់ល្អហើយ ហើយកាលណាក្លូរធំរហូតដល់ចាស់ ក៏អោយនីត្រូហ្សែនតាមដីត្រូវប្រើអស់ល្មមល្អ នៅសល់តែហ្វូសហ្វូរស និងប៉ូតាស្យូមជួយបង្កើតរសជាតិផ្អែមអោយពេញតទៅ ។ ការអនុវត្តន៍អាចឃុំនីត្រូហ្សែនក្នុងដីពិបាក ប៉ុន្តែបើប្រើពាមស្លឹកវិញនិងឃុំបានល្អល្មម គឺបាញ់ស្លឹកប៉ុន្មានរុក្ខជាតិក៏ត្រូវប្រើទៅប៉ុណ្ណឹង ។

វិធីកែដីដែលល្អហួសពេក ឬស្មៅដែលមាននីត្រូហ្សែនច្រើនហួសពេកក្នុងចំការអំពិលផ្អែម គឺរកគ្រាប់ស្មៅមកព្រោះ ហើយសឹមកាត់ស្មៅយកទៅអោយសត្វស៊ីក្រៅចំការ ឬប្រើជាប្រយោជន៍ដីទៃទៀត ស្មៅជួយស្រូបយកជីលើសបានល្អប្រហែល 2-3 ឆ្នាំ ដីល្អបរិបូរណ៍កាត់ស្មៅចោលទៅក្នុងចំការអំពិលផ្អែម ជាការរក្សាគុណភាពទុកបានតទៅ ។

ចំពោះដីទំនាបបញ្ហាប្រឈមមុខគឺ កាលណាក្លូរចាប់ផ្តើមផ្អែមហើយក៏និងកើតផ្សិត ។ ការដោះស្រាយបញ្ហាមេរោគផ្សិតត្រូវធ្វើ កាលណាក្លូរចាប់ផ្តើមផ្អែម និងមានមេរោគផ្សិតចូលអោយបូមទឹកចេញពីប្រឡាយដើម្បីធ្វើអោយដី និងធាតុអាកាសស្ងួតឡើង ។ បើចាំបាច់

បាញ់សារៈជាតិកំចាត់ផ្សិតដូចជាថ្នាំ សាជ្រន់ ជ្រន់ត្ង និងថីរ៉ាខ្ការ៉ី និងស៊ីប៊ុនអេកស៍អោយខ្លះ កាលណាបេះក្ករមកហើយអោយអប់ដោយកំដៅ រួចហាលថ្ងៃអោយស្ងួតល្អមសមគួរ និង ការពារផ្សិតបានល្អ ។

វិធីម្យ៉ាងទៀតគឺកុំអោយមានក្ករឆ្លងរដូវ ក្ករដែលចាស់មិនទាន់ ហើយនៅខ្ចីនៅឡើយរហូត ដល់ជិតនឹងចាប់ផ្ដើអំពិលសាថ្មីនោះ អោយបេះលក់ជាអំពិលស្រស់អោយអស់ បើមិនដូច នោះទេធ្វើអោយផ្កាចេញមិនល្អ ។ បើក្ករអំពិលនៅសល់លើដើមទៅចាស់នៅរដូវភ្លៀង និងកើតជាអុជខ្មៅៗ ។ បើនៅសល់ដល់ក្ករអំពិលសារថ្មីចាប់ផ្ដើមចាស់ និងក្លាយទៅជា ប្រភពមេរោគផ្សិតដល់អំពិលសាថ្មីយ៉ាងសំខាន់ ។ ដូចនោះនៅទីដីទំនាបដាំលើរងត្រូវបេះ អំពិលក្នុងមួយសារៗអោយអស់ កុំអោយមានសល់ជាប់នៅលើដើម ។

<u>ការប្រមូលផល</u> :

អំពិលផ្ដើមភាគច្រើននិងចាស់ ហើយបេះប្រមូលផលបានក្នុងរវាងខែធ្នូដល់ខែមិនានៃឆ្នាំ បន្ទាប់ ។ ទាំងនេះស្រេចតែទឹកន្លែងដីដាំសភាពដីនិងអាកាសធាតុ ។ ក្ករអំពិលចាស់បេះ បាន ឬក្ករទុំនិងមានក្ករពណ៌ត្នោតចាស់ ឬពណ៌ទ្នួន ឬពណ៌មាស ។ ស្រេចទៅលើលក្ខណៈ ប្រចាំពូជនៃពូជនីមួយៗ ។ ក្ករចាស់ដែលស្ងួតល្អហើយ ចាប់មើលទៅមានទំងន់ស្រាល ប៉ុន្តែបើក្ករនៅមិនទាន់ចាស់មែនទែននិងមានទំងន់ធ្ងន់ ។ បើគោះមើលឮសម្លេងខ្ទិកខ្ទុក ប៉ុន្តែកុំអោយគោះខ្លាំងពេកសំបកអាចបែកបាន ហើយមិនត្រូវយកក្រចកដៃកោសទេ និង ធ្វើអោយសំបកក្ករអំពិលមិនស្អាតល្អ ។

វិធីបេះប្រើជណ្ដើរពាក់ផ្អែកទៅនឹងមែកឡើងទៅ ឬស្ទូរឡើងដើមបេះ ។ អ្នកបេះម្នាក់ៗ អាចមានថង់យាមស្ពាយជាប់នឹងខ្លួនដើម្បីប្រើសំរាប់ដាក់អំពិល ។ ការបេះត្រូវធ្វើយ៉ាង

ប្រណិតប្រយ័ត្នប្រយែងកុំអោយក្ញួរបែក ព្រោះមើលមិនស្អាតល្អ តម្លៃធ្លាក់ ហើយកើតមេរោគផ្សិត ។

ក្ញួរអំពិលក្នុងរយៈពេលនីមួយៗនិងមិនទុំស្រុះគ្នាទេ ទើបត្រូវបេះបណ្តើរៗច្រើនសារ ។ អ្នកមានការស្ទាត់ជំនាញប៉ុណ្ណោះ ទើបដឹងថាក្ញួរណាអាចបេះបាន ឬមិនបាន ។ ក្រៅពីនោះការត្រូវប្រើកន្ត្រៃកាត់ចេញពីដើមក្នុងមួយក្ញួរៗ ដើមមួយៗអាចមានប្រហែល 1,000 ទៅ 2,000 ក្ញួរ ទើបត្រូវប្រើពេលវេលានិងអ្នកបេះចំនួនច្រើន ។ នៅទីកន្លែងចំការដែលមានដាំច្រើនៗ តែងតែមានបញ្ហាកម្លាំងការងារកើតឡើងជានិច្ច ព្រោះត្រូវប្រញាប់បេះប្រមូលផលនៅពេលព្រមគ្នាទាំងអស់គ្រប់ចំការ ។ ជួនកាលទើបត្រូវជួលកម្លាំងការងារមកពីខាងក្រៅ ដែលគ្មានការស្ទាត់ជំនាញក្នុងការបេះ អាចធ្វើអោយគុណភាពក្ញួរអំពិលដែលបានបេះនោះទាប ព្រោះបេះពុំបានត្រឹមត្រូវល្អ ។

កាលណាបេះមកហើយកុំអោយត្រូវទឹក យកមកជ្រើសរើសកាត់តែងចាត់ថ្នាក់អំពិល កាត់តែងក្ញួរខ្លះដែលមានទងចង្កោមក្ញួរវែងៗចោលចេញ ។ ជ្រើសរើសក្ញួរដែលខូច ឬមានស្នាមចេញ យកទៅសំដិលហាលវែកអោយក្ញួរត្រូវខ្យល់ កុំអោយគរជាន់លើគ្នាច្រើនហួសពេក សំដិលហាលទុក 3-5 ថ្ងៃ ទើបយកទៅប្រកក្នុងថង់ប្លាស្ទិក ឬកែសក្រដាស ។ បិទមាត់កែសហើយយកទៅលក់បាន ។ វិធីនេះអាចទុកអោយអំពិលបានយូរតទៅប្រហែល 20 ថ្ងៃមិនខូច ។

<u>ការទុកដាក់ថែរក្សាក្ញួរអំពិល</u> :

អំពិលផ្អែមអាចទុកដាក់រង់ចាំលក់បានយូររាប់ឆ្នាំ បើប្រសិនទុកដាក់ថែរក្សាបានយ៉ាងត្រឹមត្រូវ វិធីទុកដាក់ថែរក្សាក៏ធ្វើបានយ៉ាងងាយស្រួល បើត្រូវការថែរក្សាទុកសំរាប់លក់ក្នុងរយៈពេលខ្លីៗ 20-30 ថ្ងៃ ។ យកទៅសំដិលហាលខ្យល់ វែកញែរអោយស្តើងៗដើម្បីអោយខ្យល់

អាកាសចេញចូលជិតជល់សព្វទាំងអស់ ការសំដិលហាលខ្យល់ធ្វើយ៉ាង តិចណាស់ 3-5 ថ្ងៃ រួចហើយយកទៅដាក់កេសដែលចន្លោះរន្ធអោយខ្យល់អាកាសចេញចូលបាន ។ ភាគច្រើន និយមដាក់ថង់ក្នុងមួយថង់ទំងន់មួយគីឡូក្រាម ។

បើចាំបាច់ត្រូវទុកដាក់អោយបានយូរជាដើម ត្រូវបន្ថែមពេលវេលាសំដិលហាលទុកចំនួន 15 ថ្ងៃឡើងទៅ អោយទាល់តែដឹងថាក្ចរអំពិលលែងចេញទឹកហើយ ពីព្រោះបើក្ចរនៅមាន ចេញទឹកនៅឡើយ និងធ្វើអោយកើតចំហាយក្តៅឡើង ។ ដូចនោះពេលសំដិលហាល ខ្យល់ត្រូវព្យាយាមវែកញែក្ចរកុំអោយត្រួតលើគ្នា ។ វិធីដ៏ល្អគឺប្រើកញ្ច្រែងរងក្ចរនៅពេល សំដិលហាលខ្យល់ ។ តពីនោះទើបច្រកដាក់ភាជនៈសំរាប់យកទៅលក់ ។



អំពិលផ្អែមដែលជាប់ក្ចរច្រើនសាលើដើមតែមួយ

វិធីនេះទុកដាក់រក្សាថែទាំក្តួរអំពិលអោយបានយូរ 40-60 ថ្ងៃ ប៉ុន្តែបើលក់នៅមិនទាន់អស់ ត្រូវពន្យារពេលវេលាទុកដាក់អោយបានយូរតទៅទៀត ដោយហេតុតែអំពិលនេះមានជាតិផ្អែម ដដែល ត្រូវធ្វើអោយសាច់ និងគ្រាប់អំពិលទុំដោយវិធីចំហុយ ឬអប់ ។

ការចំហុយក៏ដូចជាចំហុយម្ហូបអាហារទូទៅដែរ ដោយប្រើចំហុយទឹកពុះ ។ មុនចំហុយ គួរជ្រើសរើសទំហំបំបែកជាថ្នាក់ៗហើយគួរបំបែកពូជដោយឡែកៗផង ដើម្បីអោយក្តួរគ្រប់ក្តួរទុំស្មើគ្នា ។ ប្រើពេលចំហុយដោយចំហាយទឹកពុះយូរប្រហែល 20 នាទី ឬពេលវេលាស្រេចតែទំហំក្តួរអំពិល ក្តួរធំប្រើពេលវេលាយូរជាងក្តួរតូច ។ សំបកក្តួរក្រាស់ប្រើពេលវេលាយូរជាងសំបកស្តើង ។ ចំហុយអោយក្តួរឆ្អិនស្មើគ្នា រួចហើយយកដាក់សំដិលហាលខ្យល់អោយត្រជាក់ ឬសំដិលហាលថ្ងៃក៏បាន អោយទាល់តែដឹងជាក់ថាក្តួរអំពិលស្ងួត និងត្រជាក់បានការហើយ ទើបយកទៅដាក់ប្រកភាជនៈពួកពាង ឬក្រឡធំៗបិទអោយជិតណែន ទុកក្នុងបន្ទប់ដែលមានខ្យល់ចេញចូល ទុកដាក់បានយូរឆ្នាំ ។

ចំពោះការអប់នោះអាចប្រើទូអប់ស្ងួត ដូចទូអប់ប្រើថាមពលដោយពន្លឺថ្ងៃ ឬទូអប់បែបទូអប់ស្លឹកថ្នាំជក់ដូចរោងអប់ស្លឹកថ្នាំជក់ក៏បាន ។ អប់រួចហើយមិនបាច់យកទៅសំដិលហាលថ្ងៃទេគ្រាន់តែទុកពេលអោយត្រជាក់ក៏យកទៅដាក់ក្នុងពាង ក្រឡបិទអោយជិតបានតែម្តង ។

អំពិលផ្អែមពូជនិមួយៗអោយផលផលិតមិនស្មើគ្នាទេ និងមិនទៀងទាត់ក្នុងពូជតែមួយនោះផង ។ បើជាំខុសគ្នាទំហំក្តួរតូច ឬធំនោះធ្វើអោយតម្លៃមិនស្មើគ្នា ។ តម្លៃអំពិលផ្អែមអាចពាំងតែមួយគីឡូក្រាម 50-200 បាទ ។ ដូចនោះការដាំអំពិលផ្អែមអោយបានតម្លៃល្អ គួរដាំពូជល្អ ដោយប្រើបំពៅមែក ឬភ្ជាប់ភ្នែក និងធ្វើមិនអោយក្លាយពូជហើយចាំបាច់ត្រូវថែរក្សាការពារអោយបានល្អផង ដើម្បីអោយបានទំហំក្តួរម៉ានបទដ្ឋាន មានភាពស្មើគ្នា និងមានគុណភាពល្អ ។

## ប្រតិទិននៃការអនុវត្តន៍ថែរក្សាការពារអំពិលផ្អែមក្នុងរយៈពេលមួយឆ្នាំ

| | |
|---|---|
| រដូវវស្សា | បេះប្រមូលផលអស់ កាត់តែងមែក |
| រដូវប្រាំង | បេះប្រមូលផលអស់ កាត់តែងមែក លែងអោយផ្កាកការដុះលូតលាស់ មិនដាក់ជីអ្វីៗទាំងអស់ ផ្នែកខ្លះធ្វើអោយប្រឡោះផ្លូវការពារភ្លើងឆេះ |
| ភ្លៀងធ្លាក់ | បែកត្រួយ កុំអាលដាក់ជី បណ្តាលអោយចេញផ្កា ដាប់ក្អួរធម្មជាតិ |
| លេងស្លឹក | បាញ់ស្លឹក ប្រើជីលេខកណ្តាលខ្ពស់ដូចជា 10-52-17 |
| ផ្កាមិនជាប់ក្អួរ | បាញ់ផែនថីរ 1 CC លាយទឹក 20លិត្រ 7 ថ្ងៃបាញ់ម្តងទាល់តែជាប់ក្អួរ |
| ជាប់ក្អួរភ្លើប | បាញ់ជីបបិរលើនមួយអំពូល ទឹក 100 លិត្រ ( 5 កៅត) បិះបេិតពី 2 ដង រយាលពីគ្នា 7-10 ថ្ងៃ |
| ជីតាមដី | ប្រើ 0-10-30 រួមជាមួយជីផ្កាប់ ជីអាចម៍គោមិនបាច់ច្រើនទេ ឬ ប្រើ 15-5-20 + 2 |
| ជីតាមស្លឹក | ក្អួរតូចប្រើ 30-20-10<br>ក្អួរធំមធ្យមប្រើ 20-20-20 ឬ 21-21-21<br>ក្អួរធំប្រើ 12-22-32 |
| ធាតុរ៉ែបន្ទាប់បន្សំ | ប្រើអ៊ុយនិលេពតាមអត្រាក្នុងស្លាក កន្លះខែម្តងៗរហូតដល់រយៈពេល មុនពេលបេះប្រមូលផលមួយខែ |
| បុងភ្លៀង | នៅតែលើម ប៉ុន្តែក្អួរចាប់ផ្តើម ការពារផ្សិតដោយប្រើថ្នាំសាប្រូល ឬ បេិនលេត ប្រហែល 10 ថ្ងៃម្តង ទាល់តែអស់ភ្លៀង |
| រដូវវស្សា | បេះប្រមូលផលអស់ កាត់តែងមែក |

## រោគ និងសត្វល្អិតបំផ្លាញអំពិលផ្អែម :

ចំការអំពិលផ្អែមក៏ជាឧទ្យានព្រឹក្សជាតិនៃរោគ និងសត្វល្អិត ដូចគ្នានិងរុក្ខជាតិដីទៃផ្សេងៗទៀតអីចឹងដែរ មានទាំងសត្វល្អិតដែលមានប្រយោជន៍ និងឥតប្រយោជន៍បំផ្លាញដំណាំក្នុងពេលវេលាខុសគ្នា ។ ដូចនោះវិធានការអនុវត្តន៍ចាំបាច់ត្រូវបន្ថយសត្វល្អិតជាសត្រូវបំផ្លាញដំណាំអោយនៅតិចចុះ អោយមានភាគប៉ះពាល់តិចជាមួយសត្វល្អិតដែលមានប្រយោជន៍តិចជាទីបំផុត ហើយអោយចាត់ទុកថាការប្រើសារៈជាតិពិសពុលសម្លាប់សត្វល្អិតនោះជាវិធានការចុងក្រោយបង្អស់នៅពេលដែលជៀសវាងមិនផុតប៉ុណ្ណោះ ។

១ រោគផ្សិតម្សៅ : រោគនេះកើតមកពីផ្សិតអោយឈ្មោះ (Oidium sp) ជារោគអំពិលដែលគេប្រទះឃើញច្រើនបំផុត វាចូលទៅបំផ្លាញផ្នែកស្លឹកមុន ។ ដាទូទៅគេមើលឃើញដោយភ្នែកទទេ ជាកញ្ចុំពណ៌សនៃសរសៃ ។ កាលណាមេចំរើនធំពេញទីក៏មើលឃើញស្នាមស្រដៀងម្សៅពណ៌ស ចន្លោះៗពីគ្នាជាខ្ពង់ចេញមកតាមស្លឹក និងត្រួយចុងជាធូលិស្រដៀងពណ៌ស ដែលជាធូលិរបស់ពួកស្ព័រ ។ កាលណាកើតនៅនិងត្រួយក៏ធ្វើអោយស្លឹកជ្រុះទៅ ប៉ុន្តែបើកើតនិងស្លឹកចាស់ក៏កើតជាស្នាមដំកៅជាពណ៌លឿងចាស់បំពោះបរិវេណដែលមេចូលទៅបំផ្លាញ ។ តទៅក៏ក្លាយទៅជាស្នាមឆេះពណ៌ត្នោតបើកើតច្រើននិងធ្វើអោយផ្នែកដែលកើតស្ងួតងាប់បាន ។ ចន្លោះពេលដែលផ្សិតម្សៅកើតរាលដាលច្រើនបំផុតគឺចន្លោះពេលរវាងរដូវភ្លៀង និងរដូវរងារ ។

រោគនេះគួរបាញ់ថ្នាំប្រភេទម្សៅស្ពាន់ធ័រដែលលាយទឹកបាន ចាប់តាំងពីរយៈពេលដំបូងចាប់ចេញផ្កា ដើម្បីការពារកុំអោយកើតមានគ្រោះថ្នាក់ដល់អ្នកបរិភោគ ប៉ុន្តែបើមានរាលដាលខ្លាំងត្រូវប្រើថ្នាំពួកខូប្រូសាន អាហ្វីដាន ឬបេនលេត ។

(២) <u>ដង្កូវបោះក្ទួរអំពិល</u> : ដង្កូវមេអំបៅយប់មាឌតូច មានស្លាបគូរមុខពណ៌ត្នោត ស្លាបគូរក្រោយគួរណ៌សត្នោត ។ ពងដាក់មួយៗលើក្ទួរអំពិលតាំងតែនៅជាក្ទួរខ្ចី រហូតទៅដល់ក្ទួរទុំ ដោយពងដាក់តាមស្នាមបាក់ ឬបែកច្រើនជាងពងដាក់ទុកលើក្ទួរអំពិលធម្មតា ។ ការទាំងនេះដើម្បីជួយដង្កូវដែលញាស់ចេញពីពង ហើយចូលទៅក្នុងក្ទួរបានងាយស្រួលថែមឡើង ។ ដង្កូវខាំស៊ីខាងក្នុងក្ទួរប្រហែលបីសប្តាហ៍ ហើយទើបចូលទៅជាឌុកដឿ ទៀតប្រហែលមួយសប្តាហ៍ទើបផុសចេញជាតួពេញវ័យ ។ ក្ទួរអំពិលខ្ចីដែលមានដង្កូវប្រភេទនេះចូលទៅអាស្រ័យនៅទៅជាក្ទួរស្ងួតក្រៀមស្ងើង រីឯក្ទួរអំពិលចាស់សាច់ខាងក្នុងក្ទួរត្រូវខាំស៊ីទៅ ហើយដង្កូវក៏ផុះអាចម៍ដាក់ក្នុងក្ទួរបណ្តាលអោយក្ទួរស្អុយខូច ។ ដង្កូវប្រភេទនេះក្រៅពីកើតរាលដាលច្រើននៅពេលបេះប្រមូលផលហើយ នៅមកបំផ្លាញក្ទួរអំពិលក្រោយពេលប្រមូលផលទៀតផង ។

ការការពារកំចាត់ប្រើអំពិលពូជដែលមិនសូវបែកក្ទួរ ដើម្បីជៀសវាងការអាស្រ័យនៅរបស់ដង្កូវ សត្វល្អិតបោះក្ទួរអំពិល ហើយត្រូវបំផ្លាញចោលក្ទួរបែកចេញ អាចប្រើសារធាតុគីមីពុក ខារិបារិល ដូចជាសេហ្វិន 85 និងម៉ូណូក្រូតូហ្វូស 0.1 ភាគរយប្រើ 30 ក្រាម លាយទឹកមួយលីត្រ ។ បាញ់ក្នុងរយៈពេលក្ទួរខ្ចី ឬចន្លោះពេលដែលត្រូវបំផ្លាញបាញ់ 10-15 ថ្ងៃ ម្តងៗ ។ បាញ់មុនដង្កូវចូលទៅក្នុងក្ទួរ បើដង្កូវបោះចូលហើយបាញ់ថ្នាំក៏ពុំបានប្រសិទ្ធិភាពដែរ ។

(៣) <u>ដង្កូវឌួងបោះក្ទួរអំពិល</u> : ជាដង្កូវប្រភេទដង្កូវបោះក្ទួរ ។ មាឌពេញវ័យ មានពណ៌ត្នោតស្មើគ្នារហូតពេញដងខ្លួន ។ មេពងដាក់តាមសើសំបកក្ទួរអំពិល ។ កាលណាដង្កូវញាស់ចេញមកអំពីពងវាក៏បោះចូលទៅក្នុងក្ទួរ ។ លក្ខណៈដង្កូវមានរូបរាងមូល ពណ៌សគ្មានជើង ។ កាលណាវាធំពេញទីហើយក៏ចាត់សំបុកពណ៌សរាងមូលចូលជាដឹងខៀ ។ ដង្កូវប្រភេទនេះខាំស៊ីគ្រាប់ និងផុះអាចម៍ជាអាចម៍រណា ស្មោគគ្រោកនៅខាងក្នុងក្ទួរអំពិលទើបធ្វើអោយក្ទួរខូច ។ ចំណែកសាច់អំពិលក៏ស្ងួតក្រៀមប្រើជាប្រយោជន៍ពុំកើត

ការរាលដាលខ្លាំងកាលណាគ្រាប់ខាងក្នុងក្តរចាប់ផ្តើមចាស់ និងទៅជាប់ជាមួយក្តរក្រោយពេលបេះប្រមូលផល ។

ការការពារកំចាត់សត្វល្អិតប្រភេទនេះ បើឃើញក្តរខូចមានអាចម៍ស្មោគគ្រោក ឬជាសំបុកពណ៌សៗ និងក្តររឹងព្រោះសាច់ស្ងួតរើងខុសប្រក្រតី ។ ក្តរស្រោល ឬរលុងខ្លួគត្តរយកទៅបំផ្លាញកប់ដីចោល ។ ចំពោះអំពិលផ្អែមដែលបេះប្រមូលផលហើយ ហើយមានបញ្ហាដង្កូវបោះក្តរ អាចកំចាត់សត្វល្អិតដែលមាននៅសល់ក្នុងក្តរដោយអប់ចំហាយទឹក ។

① <u>ដង្កូវស្រោប</u> : ជាដង្កូវមេអំបៅយប់ ។ ពេញវ័យមាឌធំពេញវ័យ តូច ខ្លួនពណ៌ខ្មៅបានពុកមាមស្រដៀងប្រាស់ ។ មេញីឆ្លាបនិងជើងទេអាស្រ័យនៅក្នុងស្រោមដើម្បីរង់ចាំទទួលការផ្សំពូជគ្នា ។ ពងរួចហើយក៏ងាប់នៅក្នុងស្រោមនោះទៅ ។ មេនីមួយៗអាចពងបានច្រើនយ៉ាងសន្ធឹកសន្ធាប់ ។ កាលណាពងញាស់ចេញជាដង្កូវក៏ចេញពីស្រោមរបស់មេវាទៅខាំស៊ីស្លឹកអំពិល និងសាងស្រោមថ្មីក្នុងរយះពេលដំបូងវាស៊ីចំពោះសំបកប៉ុណ្ណោះទេធ្វើអោយស្លឹកស្ងួតងាប់ ។ កាលណាដង្កូវធំឡើងក៏ធ្វើអោយស្រោមហ៊ុំខ្លួនវាស៊ីស្លឹកទាំងអស់ ។ កាលណាដង្កូវធំពេញទីក៏ឈប់ស៊ីអាហារ ហើយចាក់សំបុកបិទមាត់ស្រោម និងចាក់សរសៃស្រដៀងសរសៃសំបុកពីងពាង អោយស្រោមបណ្តោងជាប់នឹងមែក ហើយចូលជាដឹកដឿបាន ។ កាលណាធំពេញវ័យក៏បោះចុងស្រោមចេញមក ។

ការការពារកំចាត់ គប្បីកាត់តែងមែកចាងដែលមានដង្កូវទៅដុតភ្លើងចោល ហើយប្រើថ្នាំរអនទ្រិនបាញ់ក្នុងរយះពេលដង្កូវស្រោមនៅតូច និងមានប្រសិទ្ធិភាពជាងដង្កូវធំហើយ ។

៥ <u>ដង្កូវអាល</u> : ជាដង្កូវមេអំបៅមាឌធំពេញវ័យ មានស្លាបមួយគូរមានក្រឡាសរសៃលើ មាត់ពណ៌ប្រផេះ ជាយពណ៌ត្នោតចាស់ ឬពណ៌ត្នោតលាយខ្មៅ មានអុចៗតូចឆ្មារ ពណ៌ខ្មៅនិងត្នោតចាស់រាយពាសពេញតាមស្លាប ទ្រូង និងក្បាល ។ ស្លាបមួយគូរ ក្រោយមានពណ៌លឿង ។ មេអំបៅពងជាកញ្ចុំៗជាប់នឹងទងស្លឹកអំពិលរៀងគ្នាជាផែន មួយជាន់ខ្លួនដង្កូវដែលញាស់ចេញពីពងថ្មីមានរោមវែងពណ៌លឿង ។ កាលណាធំឡើង មានពណ៌លឿងលាយពណ៌ក្រូចទុំ ។ លក្ខណៈដង្កូវមានរោមកាលណាប៉ះត្រូវធ្វើអោយ ក្រហាសរមាស់ឡើងកន្ទួលបាន ។ ខ្លួនដង្កូវប្រវែងប្រហែល 5-6 សង្ទីម៉ែត្រ ។ កាលណាធំពេញទីក៏ចូលទៅជាដឹកដៀក្នុងសំបុកដឹកដៀដែលហ៊ុំព័ទ្ធទៅដោយសូត្រ ពណ៌-ក្រម៉ៅទុំជាប់នឹងស្លឹកហើយតែងតែនាំគ្នាស៊ីកុំជាមួយគ្នា ។ ដង្កូវប្រភេទនេះស៊ីស្លឹកអំពិល ធ្វើអោយមានស្នាមក្រវាមពាសពេញ ធ្វើអោយស្លឹករទុះអស់ទាំងស្លឹក ។

ការការពារកំចាត់ កាលណាប្រទះឃើញកញ្ចុំពងត្រូវយកទៅបំផ្លាញចោល ឬបាញ់ថ្នាំ គីមីពពួកឌិលត្រិន 0-05-0-1 ភាគរយ ។

៦ <u>ដង្កូវនាគ</u> : ជាដង្កូវមេអំបៅយប់ល្បោលពណ៌ត្នោតក្រម៉ៅ ញីពណ៌ត្នោតខ្ចីមានក្រឡា តាមជាយស្លាប មេពងដាក់ជាកញ្ចុំៗតាមស្លឹកអំពិល ។ ខ្លួនដង្កូវមានពណ៌ត្នោតក្រម៉ៅជិតខ្មៅ ក្បាលធំជាប្ញកទុលចេញមកក្រោយផត ជើងពិតមានបីគូរ វែងជាងជើងដង្កូវមេអំបៅដទៃទៀត ជើងក្រលៃមាន 4 គូរ ដែលនៅតាមបរិវេណដងខ្លួនលើជើងក្រលៃនេះលក្ខណៈសំប៉ែត ។ ដង្កូវដែលធំពេញទីចាក់សរសៃធ្វើសំបុកពណ៌លឿង ដោយប្រើស្លឹកអំពិលហ៊ុំព័ទ្ធ ។ ដង្កូវប្រភេទនេះចូលចិត្តស៊ីស្លឹកអំពិលណាស់ ។

ការការពារកំចាត់ដង្កូវប្រភេទនេះ បើសិនប្រទះឃើញចំនួនតិចក៏អោយប្រើវិធីបេះ កញ្ចុំដង្កូវ ឬសំបុកដឹកដៀទៅបំផ្លាញចោល ឬបើមានច្រើនគួរបាញ់ថ្នាំសេហ្វិន ឬ ម៉ាឡាថែអន ។

៧ <u>ដង្កូវបោះមែក និងដើម</u> : ជាដង្កូវមេអំពៅពងដាក់តាមជំពាមមែក និងតាមសំបកដើមឈើ ។ ពងមានពណ៌ត្នោតលាយពណ៌ក្រហម ។ កាលណាដង្កូវញាស់ចេញពីពងមានទំហំ 1.5-3 សង្ទីម៉ែត្រ លក្ខណៈខ្លួនរបស់ដង្កូវដងខ្លួនជាថ្នាំង ដងខ្លួនពណ៌សបរិវេណក្បាលពណ៌ខ្មៅ មាត់មានថង្គម ។ កាលណាខ្លួនធំពេញវ័យទំហំប្រហែល 3-5 សង្ទីម៉ែត្រ មានស្លាបខ្មៅលឿងចាស់ ពាក់កាត់កណ្តាលស្លាបទាំងពីរខាង ក្បាលខ្មៅ ពុកមាត់វែង ពុកមាត់បរិវេណដែលជាប់និងក្បាលមានពណ៌ខ្មៅ គន្លះក្បាលមានពណ៌លឿងចាស់ រាលដាលខ្លាំងនូវចន្លោះរដូវហួតហែងប្រហែលកំឡុងខែវិច្ឆិកា ដល់ខែមិនា ។

ការការពារដង្កូវប្រភេទនេះ ត្រូវតែព្យាយាមពិនិត្យមើលបរិវេណដើម បើប្រទះឃើញមេដង្កូវនៅត្រូវមើលតាមមែក បើមានដង្កូវចូលទៅបំផ្លាញនិងសង្កេតឃើញរបមូល ប្រើកាំបិតជីរះសំបកបំផ្លាញដង្កូវ ឬប្រើថ្នាំសំលាប់សត្វល្អិតបាញ់ ។

៨ <u>ដង្កូវមូរស្លឹក</u> : ជាដង្កូវមេអំពៅញីស្លាបគូរដំបូងពណ៌ត្នោតលាយក្រហម ។ ត្រង់ជាយមានស្នាមពងពណ៌ត្នោតចាស់ ឬខ្មៅម្ខាងស្នាមមួយ ចំណែកឈ្មោលមានស្នាមអុជជាងពាសពេញ ស្លាបក្រោយពណ៌លឿងលាយពណ៌ត្រួចជូចគ្នាទាំងឈ្មោល ទាំងញី ។ មេអំពៅពងជាកញ្ចុំៗក្នុងមួយកញ្ចុំមានប្រហែល 70-200 ពង ។ ក្រោយពីពងបាន 3-5 ថ្ងៃ និងកើតជាដង្កូវតូច ខ្លួនពណ៌ក្រហមកាលណាធំពេញទីខ្លួនត្នោតពណ៌ខ្មី មានពករោមតាមខ្លួន ហើយក្នុងពកមួយៗមានរោម 1-2 សរសៃ ។ ដង្កូវប្រភេទនេះស៊ីស្លឹក និងចូលចិត្តមូរស្លឹកធ្វើជាសំបុកអាស្រ័យនៅ កាលណាចូលដកឿចូលទៅក្នុងស្លឹកដែលមូរនោះបណ្តាលអោយអំពិលមានផ្លែតិច ។

ការការពារកំចាត់ដង្កូវប្រភេទនេះ គួរបាញ់ដេដេតេ (DDT) មៀលាយទឹក 0.1-0.5 ភាគរយ ។

១ <u>សត្វល្អិតស៊ីរុង</u> : ជាដង្កូវស្លាបរឹង ខ្លួនតូចប៉ុនចុងកូនម្រាមដៃ ។ សត្វល្អិតនេះបង្កើតពូជនៅក្នុងដីដែលមានជីឥន្ទ្រិយច្រើន ។ ខ្លួនធំពេញវ័យចូលចិត្តរកស៊ីពេលយប់ រាប់តាំងពីក្បាលព្រលប់ ចូលចិត្តលេងភ្លើង ។ សត្វល្អិតនេះស៊ីស្លឹក ធ្លាប់ស៊ីស្លឹកអំពិលទាល់តែរទុះអស់ពេញស្លឹកងាប់ក៏មាន ។

នៅពេលមានសត្វល្អិតប្រភេទផ្សេងៗទៀតដែលសត្វបំផ្លាញអំពិល ដូចជាមេអណ្តើក ឬដង្កូវប្រមោយខៀវ ក៏ស៊ីត្រួយវិនាសហិនហោចដូចគ្នា ។ ករណីចំពោះចៃជញ្ជក់រុក្ខរស មិនសូវមានបញ្ហាធំទេ ។ អាចមានចៃខ្យង ចៃម្សៅ ខ្លះនៅតាមមែកនិងស្លឹកលើសពីនោះទៅទៀត បើមានស្រមោចនៅផងហើយកន្លែងនោះមិនសូវបានបាញ់ថ្នាំសម្លាប់សត្វល្អិតផង បើប្រសិនមានសត្វល្អិតពួកចៃជញ្ជក់រុក្ខរសអាស្រ័យនៅនឹងស្លឹក ហើយផ្នែកក្រោមៗក៏កើតទៅជាពណ៌ខ្មៅៗនៃមេផ្សិត ដែលមកស៊ីទឹកនោមផ្អែមក្នុងវត្ថុបញ្ចេញដោយចៃជញ្ជក់រុក្ខរស ។

សត្វល្អិតផ្សេងៗក្នុងចំការអំពិលផ្អែម កសិករចំការអាចដោះស្រាយបញ្ហាបានដោយប្រើថ្នាំគីមីកំចាត់សត្វល្អិត តាមអត្រាដែលបានកំណត់ក្នុងស្លាក បាញ់ស្លឹក មែក ធាង ដើម ក្ទរខ្ចី គ្រាប់ និងបាវច្រកគ្រាប់ ប៉ុន្តែហាមបាញ់សារៈជាតិពិសពុលទៅក្នុងរយៈពេលដែលផ្កាកំពុងរីក ដើម្បីការពារកុំអោយខូចខាតគ្រោះថ្នាក់ដល់ឃ្មុំ និងសត្វល្អិមានប្រយោជន៍ ក្រៅពីប្រើសារៈជាតិគីមីហើយអាចប្រើអំពូលប្លែកឡែស៍ បើគ្មានអំពូលធម្មតាទេអោយប្រើអគ្គិសនី ឬអាគុយក៏បាន ឬចាំបាច់ប្រើចង្កៀងម៉ាំសុងក៏បាន អាចបញ្ឆោតទាក់សត្វល្អិតនៅពេលយប់ពីម៉ោង 7-12 យប់ ចាប់សត្វល្អិតទុក ដោយប្រើផើងដាក់ទឹក ស្រះទឹក ឬពាងស្ងួត ដាក់បន្ទះស័ង្កសីចំកណ្តាលអោយងើបផុតពីពាងចេញមក 30 សង្ទីម៉ែត្រ រួចហើយដាក់អំពូលភ្លើងលើស័ង្កសី ។ វិធីនេះនិងកំចាត់បន្ថយសត្វល្អិតស៊ីស្លឹកបានច្រើន រាប់បញ្ចូលទាំងសត្វល្អិតដែលបំផ្លាញអំពិលរយៈពេលផ្សេងៗ

ទៀតផង ។ ចំណែកក្ដួរអំពិលក៏អាចការពារបានដោយអប់ចំហាយទឹកក្ដៅ មានប្រសិទ្ធិ-ភាពល្អ ហើយគ្មានខូចខាតផង ។





# រយៈពេលដុះចំរើនលូតលាស់ធំ និងគំរោងការអនុវត្តន៍ថែរក្សាការពារអំពិលផ្អែម



# ឧបសម្ព័ន្ធទីមួយ

## ការបេះប្រមូលផលអំពិល និងចាត់ការអនុវត្តន៍ក្រោយពេលប្រមូលផលហើយ

---


ដោយលោក សៀន ហមណាន

ចំការអំពិលផ្អែមឆ្នូនណយ ភូមិអេរ៉ាវ៉ាន់ ស្រុកវ៉ាំងសាក់កុង ខេត្តលើយ


អំពិលតាមឯកសារយោងរបស់ហ្លួងបុរេតបំរុងការដែលលោកសាស្ត្រាចារ្យ ស្វ័ត វិរៈ ដេត សរសេរទុកក្នុងកសិកម្មស្រុកក្តៅម្រែ 6 បន្ទាត់តែប៉ុណ្ណោះ ។ គ្រាន់តែដឹងថាអំពិលមានដើមកំណើតនៅទ្វីបអាហ្វ្រិក ពង្រីកពូជចូលទៅក្នុងប្រទេសឥណ្ឌាដោយព្រះសង្ឃកាតូលិក ។ រយះពេលវេលាយូរមកប៉ុន្មាននោះ ក៏ពុំបានកត់ទុកទេ ប៉ុន្តែជនជាតិឥណ្ឌាបរិភោគអំពិលក្នុងលក្ខណះផ្សេងៗគ្នា ទំពារស៊ីធ្វើជាថ្នាំជំនួសថ្នាំរបាយប្បៀមអោយចេញទឹករំលាយរបាយកំដៅនៅពេលកំពុងដើរឆ្លងកាត់សមុទ្រខ្សាច់ តាមកន្លែងដាច់ស្រយាលមានធាតុអាកាសក្តៅហប់ ជនជាតិឥណ្ឌា និងប្រជាករក្នុងក្រុមប្រទេសអារ៉ាប់នៅនិយមបរិភោគអំពិលជូរ ដែលប្រើជាប្រយោជន៍បានច្រើនជាងអំពិលផ្អែម ដោយរូបបែបលក្ខណៈផ្សេងៗខុសពីគ្នារហូតមកទល់សព្វថ្ងៃនេះ ។

ចំពោះអំពិលផ្អែមសទ្ធិដ្ឋានប្រវត្តិកើតមកទំនងច្បាស់ថា ដើមកំណើតនៅក្នុងប្រទេសលាវមានតំណតមកអំពីទេសកាលព្រះធាតុភ្នំថ្ងៃពេញបោរណ៍ ខែបី រៀងរាល់ឆ្នាំ អំពិលផ្អែមពីប្រទេសលាវក៏ចូលឆ្លងត្រើយទន្លេមកលក់នៅត្រើយថៃ ។ ជនជាតិថៃអ្នកនិយមបរិភោគបានទិញហើយនាំយកមកផ្ញើ ។ ជនជាតិថៃក្នុងមូលដ្ឋានចូលចិត្តរសជាតិអំពិលផ្អែម ទើបនាំគ្នាយកគ្រាប់មកដាំពាសពេញតំបន់ទន្លេមេគង្គចាប់ពីខេត្ត ស៊ីសាក់កេត ឧបុករាជធានី មុក-ដាហាន នគរភ្នំ ណងខាយ សកលនគរ ឧត្តរាជធានី លើយ និងពេជ្របូរណ៍ ។ ការពង្រីកពូជអំពិលផ្អែមតាមជាយទន្លេមេគង្គគឺលោកអនុសេនីយ៍លក់គ្របី ដែលមានភស្តុតាងសំអាង

នៅឯស្រុកជានសាយ ខេត្តលើយ ។ ម្ចាស់ដើមអំពិលតាំងឈ្មោះថា “ ពូជហាយម៉ី ” អាយុរាប់រយឆ្នាំហើយដែលគេឃើញនៅសព្វថ្ងៃនេះ ។

អំពិលជូរអំពីប្រទេសអាហ្វ្រិកមកកាន់ប្រទេសឥណ្ឌៀ គួរតែមានអំពិលផ្អែមលាយឡំគ្នានៅផង ប៉ុន្តែគ្មានអ្នកណានិយាយដល់ ដោយមកពីអំពិលផ្អែមប្រើជាប្រយោជន៍បានតិចជាងអំពិលជូរ ។ អំពិលជូរ និងអំពិលផ្អែមជាពូជពង្សត្រកូលតែមួយ ជាពូជសេដ្ឋកិច្ចសំខាន់ពូជមួយនៃប្រទេសលាវ ។ អំពិលផ្អែមតាមជាយទន្លេមេគង្គមានទាំងផ្អែមខ្លាំង ជូរអែម លក់មិនបានថ្លៃ ម្ចាស់គិតកាប់ធ្វើឱសថុតធ្យូង មិនចេះប្លន្តចុង ដូចនៅក្នុងពេលបច្ចុប្បន្ននេះទេ លោក អន រ៉ាំងខះខាត ភូមិណូនភៀម និគមខាំសយ ខេត្តបុកជាំហានដាំអំពិលផ្អែមដោយគ្រាប់ ។ សព្វថ្ងៃអាយុ 42 ឆ្នាំ (ឆ្នាំ ព.ស 2538) មាននៅ 16 ដើម អាស្រ័យប្រើម្លប់សាខាក្នុងបរិវេណផ្ទះ ។ មានជាតិផ្អែមដូចដើមមេមួយដើម ជូរអែមមួយដើម ក្រៅពីនោះជូរទាំងអស់ ។ មានដើមមួយដែលផ្លែជាប់ក្រួរស្វែះ ជាចង្កោម ជាកម្រង ក្លរជំនុបបន្តិចសាច់ច្រើន សាច់មានតម្លៃខ្ពស់យកទៅប្រកួតនៅក្នុងបុណ្យប្រចាំឆ្នាំ “ រួមត្រកូលថៃមុកជាហាន អំពិលផ្អែមជាយទន្លេមេគង្គ ” បានឈ្នះការប្រកួតលើកទីមួយ និងការប្រកួតលើកទីពីរជាប់ៗគ្នា ដល់ឆ្នាំទីបី គឺឆ្នាំ 2531-2532-2533 តាមភស្តុតាងសំអាងដែលបានសរុបសេចក្តីតាមបច្ចេកទេសបានថា អំពិលផ្អែមដែលដាំគ្រាប់ និងក្លាយពូជពីជូរមកជាអំពិលផ្អែមវិញ ហើយពីផ្អែមក្លាយទៅជាជូរវិញ ។

អំពិលផ្អែមមានពាស់ពេញទូទៅក្នុងខេត្ត ទាំង 17 ខេត្ត ភាគឦសាន្ត ក្នុងមួយភូមិមួយដើមពីរដើមផ្លែផ្អែមខ្លាំង ផ្អែមតិច ។ បើនិយាយថយក្រោយវិញកាលពី 50 ឆ្នាំ មុននៅមិនទាន់មានទីកន្លែង ឬគ្រួសារណាដាំអំពិលផ្អែមជាដុំកំភួនទេ មានលើកដំបូងដែលដាំអំពិលផ្អែមជាជួរៗ ការត្រៀមដីល្អ រយៈពេលដាំ និងការថែរក្សាថែទាំការពារល្អ គឺលោកអនុសេនីយ៍ទោម៉ាល័យ មិទិត្យ នៅទីមូលដ្ឋានស្រុកឡុមសៅ ខេត្តពេជ្របូរណ៍ កាលពី 37 ឆ្នាំ កន្លងមកហើយ ។

**លក្ខណៈអំពិលផ្អែម :**

1. ផ្លែជាវ : លក្ខណៈផ្លែវែងរបន្តិចដូចកាំបិតជាវ ដូចជាពូជបាននៃយ៉ៃ ពូជខន្តី
2. ផ្លែគង ឬផ្លែខុប : ខុបក្បាល កន្ទុយ ចូលមករកគ្នាច្រើនឬតិច ដូចជាពូជទឹកឃ្មុំ ពណ៌មាស ហ៊្មិនចុង
3. ផ្លែសំយុង ផ្លែត្រង់ : ដូចជាពូជបានរោចន៍ ពណ៌ជិព្វ ពូជត្រូអ៊ិន
4. ផ្លែឆ្អឹង: សំបកជាថ្នាំង១ ផត ចង្អុរដឹងថាមានគ្រាប់នៅក្នុងផ្លែបានយ៉ាងច្បាស់ ចំណែកផ្លែធំ ច្រើនតែជាផ្លែរបស់ពូជអ្នកស្រុក ។

តាមការពិនិត្យមើលយ៉ាងដិតដល់ ក៏អាចជៀប្រាកដថា អំពិលផ្អែមមានផ្លែត្រង់ និងផ្លែ-ជាវ មានសរសៃស្រោបសាច់ និងគ្រាប់តូចជាងពូជគង ឬខុបដែលមានសរសៃស្រោបធំ ។

**លក្ខណៈអំពិលផ្អែមដែលគួរតែប្រើបណ្តុះបណ្តាល :**

1. ត្រូវមានសាច់ក្រាស់ តម្លៃសាច់ និងភាគរយនៃសាច់ខ្ពស់
2. សំបកក្រាស់ សរសៃស្រោបតូច
3. ផ្លែសំយ៉ុងត្រង់ ដើម្បីងាយស្រួលក្នុងការដាក់ច្រក និងខ្ចប់
4. ពណ៌សំបុរសាច់ក្រម៉ៅ សាច់រងើមជាស្រមោលថ្លា ជាក្រាមស្អុរខាងក្នុង សាច់ស្វិតមិនល្បៀច
5. ពូជស្រាលបេះប្រមូលផលបានមុន
6. ថ្នាំងញឹកមានឱកាសចេញចង្កោម និងចង្កោមស្លឹកបានច្រើន
7. ផែនស្លឹកក្រាស់ អោយស្លឹកច្រើន មានការផ្សំពន្លឺប្រកបដោយអាហារបានច្រើនជាងសន្លឹកល្អិត ផ្លែតូច ស្លឹកល្អិត ។

អាយុនៃការបេះប្រមូលផល :

1. ពូជស្រាលបេះបានរវាងថ្ងៃទី 19 ខែវិច្ឆិកា ដូចជាពូជបានព្រះរោចន៍ ពូជស្រិធុមភ្ន ។ បំប៉នផ្លែ 7 ខែ មានរយៈពេលផ្កាកការដុះលូតលាស់ 5 ខែ និងអោយផលផ្លែច្រើនស្ទើរមួយឆ្នាំ ខានមួយឆ្នាំ ។
2. ពូជកណ្តាលបេះប្រមូលផលបានរវាងថ្ងៃទី 14 ខែធ្នូ ដូចជាពូជផៃយ៉ៃ ត្រូអ៊ិន ចន្លោះរយៈពេលបំប៉នក្លូរ 7-8 ខែ ផ្កាកការដុះលូតលាស់ 4-5 ខែ ជាប់ក្លូរច្រើនស្ទើរមួយឆ្នាំ និងខានមួយឆ្នាំ ។
3. ពូជធ្ងន់បេះប្រមូលផលបានរវាងថ្ងៃទី 22 ខែមករា ដូចជាពូជពណ៌មាស ពូជខន្តី ពូជទឹកឃ្មុំ បំប៉នក្លូរយូររយៈពេល 9 ខែ មានរយៈពេលផ្កាកការដុះលូតលាស់ត្រឹមតែបីខែ និងមានក្លូរច្រើនស្ទើរមួយឆ្នាំ និងខានមួយឆ្នាំ ។

ការបេះប្រមូលផល :

អំពិលទុំអាចបេះប្រមូលផលបាន សាច់និងសំបកជាច់ឃ្លាតពីគ្នា ដឹងបានដោយវិធីសង្កេតសំបកក្លូរគោះ ឬអង្រួនតិចៗនិងមានសម្លេងស្រឡះ មិនស្អៀន និងទុំពេញក្លូរ ។ គោះដំបូងជិតទងក្លូរ បើសំលេងស្រឡះដឹងថា ក្លូរនោះទុំទាំងក្លូរហើយ សាច់ប្រែពីស្រស់មកជាស្ងួតវិញ ស្អិតមានក្រួតជាតិជាតិកខ្ពស់ បើជាអំពិលផ្អែមត្រូវមានតម្លៃប្រៀបធៀបស្ករខ្ពស់មិនទាបជាង 14.3 ប្រិកស៍ ។

វិធីបេះប្រមូផល :

បេះប្រមូលបានច្រើនវិធី :

1. ដើមដែលមានទំរង់គុម្ពដើមទាបអាយុ 5-8 ឆ្នាំ ប្រើដណ្តើរ កៅអី ឬកាជនៈជំរៃ ដែលឈោងដល់ មិនព្រួយិតប្រយោង ឬប្រទាញមែក ។

2. ដើមខ្ពស់មានអាយុតាំងតែ 10 ឆ្នាំឡើងទៅ ប្រើជណ្ដើរឈើ បង្គោល ឬអង្កុយរាន ។
3. បើជាអំពិលជូរដែលមានទំរង់គុម្ពដើមខ្ពស់ ម្ចាស់អាចប្រើវិធីកាប់មែកទំលាក់ចុះមក ដោយមិនខ្លាចក្ទួរបែក មិនដូចអំពិលផ្អែមក្ទួរបែក បាក់ លក់ពុំបានថ្លៃ ។

<u>អំពិលដែលមានគុណភាពល្អ និងតម្រូវការរបស់ទីផ្សារ</u> :

1. អំពិលទុំហើយបេះប្រមូលផលបានរវាងខែវិច្ឆិកា ខែធ្នូ ខែមករា និងខែកុម្ភៈ ប៉ុណ្ណោះដែលមាន ។
2. អំពិលជូរត្រូវការក្រួត ថារីថារិកខ្ពស់
3. អំពិលផ្អែមត្រូវមានជាតិស្ករនៅក្នុងគីរត 13.3° ប្រិកស៍ឡើងទៅ ទឹកអំពៅជាមធ្យមទូទៅទាំងប្រទេសវាស់បាន 18.20 ប្រិកស៍ ។
4. ភាគរយសាច់រវាង 56-58° តម្លៃពិតប្រាកដនៃសាច់ (RV) ប្រហែល 15-16 (RV) = Real Value of Pulp គឺ :

$$1.\quad \frac{\text{ចំនួនសាច់} \times 100}{\text{ចំនួនក្ទួរ}} = \%\ \text{សាច់}$$

$$2.\quad \frac{\text{ចំនួនសាច់} \times \%\ \text{សាច់}}{100} = \text{តម្លៃសាច់ពិតប្រាកដ}$$

តម្លៃ RV ចេញមកប៉ុន្មានត្រូវចែកនិងចំនួនក្ទួរ ក៏បានជាតម្លៃពិតប្រាកដ ឧទាហរណ៍ដាក់អំពិលត្រឹម 10 ក្ទួរ យកចំនួនក្ទួរចែក ។

## កត្តាត្រូវប្រយ័ត្នក្នុងការបេះប្រមូលផល :

1. កុំប្រយិតប្រតោងស្វាមែក កាត់មែក ។ មែកអំពិលក្រោយពីពេលបេះប្រមូលផល ហើយនិងផ្លាស់ប្តូរទិស បណ្តាលអោយមែកដែលធ្លាប់ផ្លែមក្នុងឆ្នាំតទៅទៀត និងទៅជាផ្ចូរបាន ។
2. កុំប្រើកង្វារការ អង្រួនដើម្បីអោយក្ជូរជ្រុះ ។ ការប្រើកម្លាំងធ្វើអោយមែកផ្លាស់ប្តូរទិសទី ។
3. ការប្រើល្ងួសចង់រឹម ឬចងកន្ទោងបន្ទះក្តារសំរាប់ស្វារឡើង នៅពេលដែលអំពិលដាំថ្មីដើមនៅតូច លុះធំឡើងម្ចាស់ភ្លេចយកបន្ទះស្វារចេញ មែកនោះត្រូវល្ងួសរឹតមែកសូម្បីសាច់ឈើក៏ផុះរីកបិទជិត មើលឃើញពីខាងក្រៅក៏ដោយ ប៉ុន្តែសាច់ឈើនៅខាងក្នុងផតចូលត្រូវល្ងួសរិត ការបញ្ជូនអាហារមិនស្រួលចំពោះមែកនោះនិងមានរសជាតិជូរជាងមែកដទៃក្នុងដើមតែមួយ ។

## ការអនុវត្តន៍ក្រោយពេលប្រមូលផលដើម្បីលក់ :

1. យកហាលថ្ងៃ 1-2 ថ្ងៃ ឬរោងអប់ដោយពន្លឺថ្ងៃចេញបែបដោយការឧបត្ថម្ភកសិកម្មធ្វើអោយមានជាតិសើមល្អកក្នុងសាច់ថយចុះ ហើយសត្វល្អិតដែលមាននៅសល់នៅខាងក្នុងរត់គេច ឬងាប់ទៅ ដើម្បីទុកថែរក្សាទៅអោយបានយូរ និងការពារផុះផ្សិត ។
2. បញ្ជូនគ្រឿងអប់ ឬដាក់ថ្នាំដោយគ្រឿងសម័យទំនើប ដើម្បីការពារមេផ្សិត និងបញ្ឈាសំណើមក្នុងសាច់តាមបំណង ។
3. ចំហុយដោយចំហាយទឹកដើម្បីសម្លាប់មេផ្សិត និងដង្កូវចោះក្ជូរអំពិល ។ គុណវុបត្តិដែលទទួលបានគឺអំពិលនឹងបឺតស្រូបយកសំណើមអំពីចំហាយទឹក បណ្តាលអោយពណ៌សំបកនិងសាច់ប្រែ ។

4. ការចាត់លំដាប់ថាក់ល្អ អន់នៃក្លូវអំពិលមុនពេលដែលដាក់កែសលក់ ដែលជាកាតព្វកិច្ច ចាំបាច់សំរាប់ប្រយោជន៍ប្រាក់ចំណូលចុងក្រោយបង្អស់របស់កសិករចំការជាម្ចាស់ ។

<u>កិច្ចចាត់ការក្រោយពេលបេះប្រមូលផល</u> :

1. អំពិលដែលមានអាយុ 5-8 ឆ្នាំ ជារយៈពេលដែលអោយផល ត្រូវកាត់តែងមែកអោយស្រឡះក្នុងខែកុម្ភៈ ឬមុនចេញចង្កោមស្លឹក និងចង្កោមផ្កា 1-2 ខែ ។
2. អំពិលដែលអាយុ 10 ឆ្នាំ ឡើងទៅ ក្រោយពីពេលបេះប្រមូលផលហើយមែកផ្សេង មែកឯង រមួល ក្រពិតក្រញេវ ដោយមកពីប្រើជណ្តើរផ្អែកសង្កត់ ប្រពោង ជាន់ មែកងាប់ ក្លូវស្ពុយខូច មែកដែលមិនស្រឡះ គ្មានរបៀបត្រូវកាត់ចេញយកទៅដុតភ្លើងចោល ។
3. កាត់មែកចាស់ដែលមានសំបករាបចោល ទុកអោយនៅចំពោះតែមែកគគ្រីម មានពកភ្នែកដុសចេញម្ខាង១ទាំងពីរខាង ។
4. អំពិលដែលនៅលើដីមានសំណើមខ្ពស់ គឺវតទឹកជ្រៅ 1-2 ម៉ែត្រ ឫសកែវដុះដល់ទឹក អំពិលដើមនោះនឹងមានស្លឹកក្រាស់ ទំរង់គុម្ពដើមស្អុក លេងស្លឹករហូតដល់ពេលចេញផ្កា និងក្លូវរហូតទាំងឆ្នាំ ក្លូវទុំគ្មានគុណភាព សាច់ល្បៀច លក់មិនបានថ្លៃ បើដាំអំពិលនៅលើទីដីខ្ពស់បញ្ចេញទឹកបានល្អ គឺវតដីខ្ពស់ពីទឹក 7-8 ម៉ែត្រ និងផ្លាស់ប្តូរស្លឹកចេញផ្លែបេះប្រមូលផលទៅតាមរដូវកាល គុណភាពល្អ ប្រព្រឹត្តទៅតាមលក្ខណៈពូជ ។

<u>រោគ សត្រូវ និងការរក្សាថែទាំការពារក្រោយពីប្រមូលផល</u> :

អំពិលមានសត្រូវមកបំផ្លាញច្រើនជាង 30 ប្រភេទ ប៉ុន្តែអំពិលបានទទួលការខូចខាតត្រឹម 3-4 ប្រភេទតែប៉ុណ្ណោះ ។ តាមការពិសោធន៍គួរគប្បីបែងចែករយៈពេលមើលរក្សាថែទាំទាំងអស់ ចាំបាច់ត្រូវអនុវត្តន៍បែងចែកជា 4 រយៈគឺ :

រយៈទីមួយ :

1. ក្នុងខែមីនា ដល់ខែមេសា កាលណាជំរុញការផ្លាស់ស្លឹកចាស់ចោល ប្រើសារជាតិហ៊ុំវមិកអ៊ែរស៊ិក 3% សារជាតិជំរុញអោយរុក្ខជាតិស៊ីអាហារ ផ្សំជីគ្រាប់ 15-30-15 ជួយជំរុញជីតាមស្លឹក ជំរុញអោយជាប់ផ្កា និងផ្លែ (ចំការឈួនណយ ប្រើរីករីហ្វូល 20 CC ផ្សំជីគ្រាប់សែល 15-30-15 អត្រា 30 ក្រាម ក្នុងទឹក 20 លិត្រ) បាញ់រយៈរយោលគ្នា 7 ថ្ងៃ ចំនួន 2-3 ដង មុនពេលស្លឹកជ្រុះ ។

2. ក្រោយពីស្លឹកជ្រុះបាន 85-90% ប្រើថ្នាំការពារផ្សិតម្សៅដែលអាចមាននៅសេសសល់តាមមែកនិងដើម លាងអោយអស់រលីងទៅ ប្រើថ្នាំតៃហ្សប្រ៊ីលជាឈ្មោះសាមញ្ញ ចំការទួនណយប្រើថ្នាំសាផ្រល់នៃគីមីសែលអត្រា 15-20 CC ក្នុងទឹក 20 លិត្រ បាញ់ 1-2 ដង រយោលគ្នា 5-7 ថ្ងៃ ។

3. ក្រោយពីអំពិលផ្លាស់ស្លឹកចោលប្រហែល 15-20 ថ្ងៃ និងចាក់ចង្កោមស្លឹកចេញតាមចង្វែកមែក ពីត្រួយពណ៌ក្រហមលឿង ជាពណ៌ខៀវខ្ចី និងខៀវចាស់ អាចធ្វើបន្លែម្ជូរបាន និងមានមែក និងចង្កោមផ្កាចេញមកតាមចង្វែកមែកទូទៅ ។ ក្នុងចន្លោះពេលនេះ សត្វល្អិតស៊ីរុង សត្វល្អិតស្លាបរឹងមកពីក្រោមដីឡើងមកស៊ីចង្កោមស្លឹក និងចង្កោមផ្កា ប្រើថ្នាំ Carbaryl ជាឈ្មោះសាមញ្ញ ចំណែកពាណិជ្ជកម្មហៅថាសេវិន (Scvin) 85 ជាថ្នាំម្សៅ ផ្សាំថ្នាំចាប់ស្លឹកនិងជួយអោយថ្នាំចាប់ជាប់នៅបានយូរ ។ សត្វល្អិតប្រភេទនេះនឹងចុះមកបំផ្លាញនៅពេលយប់ បាញ់រយោលគ្នា 5-7 ថ្ងៃ ត្រឹម 2-3 ដង។

រយៈទីពីរ :

ក្រោយផ្ការីកជាប់ក្នុរហើយធំប៉ុនក្បាលឈើគូស ឬធំជាងនេះ ក្នុងពេលដែលគំរោងសាងនៃសំបកនៅខ្ចី ហើយមានដង្កូវចោះចូលក្នុរបំផ្លាញ មានរន្ធតូចហើយផុះចេញជាអាចម៍

រលោកអោយឃើញការខូចខាតតិចធ្វើអោយគួរវៀចក្រញិងក្រញង់ប្រើថ្នាំ Monocrotophos ជាឈ្មោះសាមញ្ញ ឈ្មោះពាណិជ្ជកម្មគឺអេសូឌ្រីន 60 បាញ់មិនបាច់ប្រើថ្នាំជុបស្អិត អត្រា 20-30 CC ក្នុងទឹក 20 លីត្រ ។

រយៈទីបី :

ជារយៈពេលអំពិលជិតទុំ អស់រដូវភ្លៀងចូលដល់រដូវរងារ មានទាំងរោគ ទាំងសត្វល្អិតចូលបំផ្លាញគឺដង្កូវបោះកួរ ផ្សិតខ្មៅ ចៃខ្យង ផ្សិតចូលកួរ ។ បើមានដង្កូវបោះចៃខ្យងប្រើអេសូឌ្រីន 60 អត្រា 20-30 CC ក្នុងទឹក 20 លីត្រ ។ បើឃើញមេផ្សិតច្បាស់ប្រាកដគួរប្រើថ្នាំសាព្រល់អត្រា 10-20 CC ក្នុងទឹក 20 លីត្រ ។

រយៈទីបួន :

ដង្កូវបោះកួរចូលបំផ្លាញក្នុងកួរខ្ចីរហូតដល់កួរចាស់ ចាប់តាំងពីអំពិលនៅលើដើមនៅឡើយ ប្រើសារៈជាតិ Pyrethriod ដូចជាស៊ីប៊ុខតអត្រា 10-20 CC ក្នុងទឹក 20 លីត្រ បាញ់កំចាត់ដង្កូវ ហើយក្រោយពីប្រមូលផលយកមកដាក់គរចាំលក់ក៏នៅអាចចូលទៅបំផ្លាញបានដែរ ។ វិធីការពារដោយយកទៅហាលថ្ងៃប្រលាក់ថ្នាំ បញ្ចូលត្រៀងអប់ដោយកំដៅបិទអែស ខ្ចប់អោយជិតល្អអាចទុកបានយូរ ។

# ឧបសម្ព័ន្ធទីពីរ

## ចំណុចដែលត្រូវសង្កេតដោយប្រការខ្លះៗដែលមិនជាប់ក្នុងអំពិល


**ដោយលោក ទ្រីកៀត ឃិមស្វ័ត និងលោក សិរិទ្ធិ ហៀងច័ន្ទ**

ក្រុមកសិកម្មសាស្ត្រ មហាវិទ្យាល័យខនកែន


ជនជាតិថៃបានស្គាល់អំពិលផ្អែមមកហើយមិនតិចជាងពី 100 ឆ្នាំ ទេ ដូចដែលបានឃើញពីដើមអំពិលផ្អែម ដើមខ្លះដែលមានអាយុជាង 100 ឆ្នាំ នៅឃុំណាស្វេក ស្រុកមឿង ខេត្តបុកជាហាន (ប្រសើដ្ឋ = 2530) ប៉ុន្តែការធ្វើចំការអំពិលផ្អែមមុនគេនោះគឺលោក អនុសេនីយ៍ទោ ម៉ាល័យ មិទិព្វ នៅឯស្រុកប៉ុបសាក់ ខេត្តពេជ្របូរណ៍ (សិរិទ្ធិ = 2530) ។

អំពិលផ្អែមជារុក្ខជាតិដែលគួរអោយចាប់អារម្មណ៍យ៉ាងក្រៃលែង ពីព្រោះសាច់មានរសជាតិផ្អែម និងផ្ទួរអែមជាទីពេញចិត្តនៃជនជាតិថៃ និងជនជាតិបរទេស ហើយប្រការសំខាន់គឺតម្លៃក្នុងអំពិលផ្អែមថ្លៃជាងផ្លែឈើផ្សេងៗ ដ៏ទៃទៀតណាស់ តម្លៃជាទូទៅចាប់ពីមួយគីឡូក្រាមថ្លៃ 60-200 បាត ទាំងនេះស្រេចតែប្រភេទពូជ ទំហំក្នុង និងរសជាតិទើបអំពិលផ្អែមជារុក្ខជាតិទាក់ទាញកសិករ និងអ្នកមានមុខរបរកសិកម្មអោយចង់ និងសុខចិត្តដាក់ទុនដាំអំពិលផ្អែមចំនួនដ៏រាប់ពាន់រ៉ៃ ធ្វើអោយបន្ថែមចំនួនដីដាំដំណាំអំពិលផ្អែម ច្រើនកើនឡើងយ៉ាងរហ័សនៅក្នុងខេត្តជាច្រើន ដូចជាខេត្តពេជ្របូរណ៍ ឧបលរាជធានី មុកដាហាននគររាជសីមា សុរិន ហើយជាពិសេសក្នុងខេត្តលើយ ។ ទោះជាយ៉ាងណាក៏ដោយតម្លៃអំពិលផ្អែមក្នុងទីផ្សារក៏នៅថ្លៃនៅឡើយជាធម្មតាដូចដើម ប៉ុន្តែគួរអោយសង្កេតថាកសិករដែលផលិតដើមបំពៅមែកលក់ច្រើនតែជាអ្នកមានប្រាក់កាសច្រើនជាងកសិករ ដែលផលិតផ្លែលក់ ។

ចំណុចនេះសរអោយឃើញថាការនិយមនៅមាននៅឡើយ មិនសាបសូន្យដើមពូជអំពិលផ្អែម ទើបនៅមានលក់គ្រប់ពេលវេលា ហើយការដាំអំពិលផ្អែមអោយបានដើមនោះមិនគួរកើតមានជាបញ្ហាទេ បញ្ហានៅត្រង់ជាប់ផ្លែ ពីព្រោះសង្កេតឃើញថាតម្លៃផ្លែអំពិលផ្អែមមិនដែលមានតម្លៃទាបឡើយ ទើបអាចអះអាងធានាបានមួយយ៉ាងថា ផលិតផលត្រូវបានតិចទោះបីចំនួនផ្ទៃដីដាំអំពិលផ្អែមបន្ថែមច្រើនឡើងក៏ដោយ ។

<u>បញ្ហាជាប់ផ្លែអំពិល</u> :

ការពិតការដាំអំពិលផ្អែមមានបញ្ហាសំខាន់ច្រើនយ៉ាង ប៉ុន្តែបញ្ហាដែលសំខាន់បំផុតគឺអំពិលមិនជាប់ផ្លែ ។ តាមការស្ទង់ត្រួតពិនិត្យមើលការដាំអំពិលផ្អែមរបស់អ្នកសរសេរក្នុងឆ្នាំ 2529 ក្នុងខេត្តជាច្រើននៅក្នុងភូមិភាគឦសាន្តប្រទេះឃើញថា កសិករបានបោះបង់ចោលចំការអំពិលផ្អែម ទុកអោយស្ពុកនៅទំនេរទរទេដោយពុំធ្វើអ្វីតទៅទៀត មានចំនួនជាច្រើនក្នុងចំការតែម្តង ដោយអោយមូលហេតុថា ការដែលបោះបង់ចោលចំការទុកអោយស្ពុករាំងពីព្រោះអំពិលផ្អែមមិនជាប់ផ្លែ មិនឃុំនិងការដាក់ទុនតទៅទៀត ហើយចំការខ្លះដែលជាប់ផ្លែក៏អោយផលមិនពេញលេញគឺអោយផលត្រឹមតែ 50%-60% នៃចំនួនដើមដែលដាំតែប៉ុណ្ណោះ ។ កសិករដែលមានបទពិសោធន៍ក្នុងការដាំអំពិលផ្អែម ច្បាស់ជាមិនបដិសេធអភូតហេតុដូចបានពោលមកហើយយ៉ាងពិតប្រាកដ ។

តាមបញ្ហានៃការមិនជាប់ផ្លែអំពិលផ្អែមដូចពោលមកនោះ ធ្វើអោយអ្នកបច្ចេកទេសគិតដល់ដើមហេតុនៃសន្និដ្ឋាននៃបញ្ហាច្រើនប្រការ ជាអាទិ៍ភាពមិនល្អបរិបូរនៃលំអងកេសពេញាល និងសំបុកពងដែលមិនអាចធ្វើសកម្មភាពផ្សំពូជគ្នា ភ្លៀងមិនធ្លាក់តាមរដូវកាល ពូជអំពិលដែលដាំមិនសមស្របនិងដី និងការខ្វះធាតុរ៉ែអាហារ ឬភាពមិនល្អបរិបូរណ៍នៃដើមរុក្ខជាតិខ្លួននោះឯង ។

មុនយើងគិតដោះស្រាយបញ្ហាដូចបានពោលមកហើយថា តើអ្វីជាបញ្ហាពិតៗធ្វើអោយអំពិលមិនសូវជាប់ផ្លែ ។ ជាបឋមយើងគួរសិក្សាអំពីធម្មជាតិនៃអំពិលមុនថាតើវាយ៉ាងមិច អំពិលចាប់ផ្តើមបេះប្រមូលផលរាប់ចាប់តាំងតែកណ្តាលខែធ្នូ ចំពោះពូជស្រាលទៅរហូតដល់ពាក់កណ្តាលខែកុម្ភះចំពោះពូជធ្ងន់ តពីនោះក៏ចាប់ចូលរដូវប្រាំង ស្លឹកអំពិលក៏ជ្រុះជាបន្តបន្ទាប់រហូតដល់ខែមេសា ស្លឹកចាស់ជ្រុះជិតអស់ពីដើម ។ ទាំងនេះស្រេចតែចន្លោះពេលធ្លាក់ភ្លៀងក្នុងឆ្នាំខ្លះ ឧទាហរណ៍ : បើភ្លៀងធ្លាក់មុនរដូវកាលមកធ្លាក់ក្នុងខែធ្នូ ស្លឹកអំពិលក៏ជ្រុះយឺតទៅ ។ លក្ខណៈការជ្រុះស្លឹកអំពិលអាចជ្រុះអស់ពីដើម ឬអាចជ្រុះព្រមជាមួយគ្នា និងការបែកត្រួយដែលស្រេចតែសំណើមក្នុងដី និងអាកាសធាតុ ។

កាលណាត្រួយបែកចេញមកពេញដើមហើយ ហើយកាលណាប្រែជាស្លឹកចាស់ប្រហែលខែមេសា ផ្កានិងចាប់ចេញ និងចេញបណ្តើរៗពេញទីទៅដល់ខែមីនា ។ ចំណែកខែកក្កដា និងខែសីហា ផ្កាអំពិលនិងចេញរាយៗ ។ ទាំងនេះការចេញផ្កាក៏ស្រេចតែបរិមាណនិងចំនួនទឹកភ្លៀង ។ រាប់ចាប់ពីអំពិលចាប់ផ្តើមចេញផ្ការហូតដល់ពេលផ្កាផ្តើមបើក ប្រើពេលវេលាគិតជាមធ្យម 20 ថ្ងៃ ហើយផ្កាចាប់ផ្តើមបើក រាប់ចាប់ពីពេលព្រឹកម៉ោង 05:30 រហូតដល់ម៉ោង 08:30 បន្ទាប់ពីពេលនេះផ្កានឹងមិនបើកតទៅទៀតទេរហូតដល់ថ្ងៃតទៅទៀត ទើបផ្កាចាប់ផ្តើមបើកថ្មីឡើងវិញ ។ ចន្លោះពេលវេលាផ្កាបើកដែលសមស្របបំផុតគឺវេលាម៉ោង 06:30 ដែលផ្កាអំពិលនិងបើកដល់ 54 ភាគរយ ។ តាមការសិក្សារបស់អ្នកវិទ្យាសាស្ត្រក្រុមជាមួយគ្នា បានរាយការណ៍អោយដឹងអំពីភាពបរិបូរណ៍នៃលំអងកេសរចំនួន 665 គ្រាប់ ឃើញថាចំនួន 95.54 ភាគរយ ជាលំអងកេសរបរិបូរណ៍ រីឯចំណែក 3.45 ភាគរយទៀតប៉ុណ្ណោះ ជាលំអងកេសរអោរ (ខ្ចើយ) ចំណុចដែលពោលទុកថា ការមិនជាប់ផ្លែអំពិលបណ្តាលមកពីភាពមិនបរិបូរណ៍នៃលំអងកេសរនោះ ។ តាមរបាយការណ៍នេះប្រហែលជាមិនពិត ពីព្រោះភាពបរិបូរណ៍នៃលំអងកេសរមានច្រើនទៅដល់ 96.54 ភាគរយ ។

កាលណាជ្រាបអំពីភាពបរិបូរណ៍នៃលំអងកេសរអំពិលហើយ ការជាប់ក្ងរមិនគួរមានជាបញ្ហាឡើយ ។ អ្នកវិទ្យាសាស្ត្រក្រុមជាមួយគ្នានេះបានសិក្សាទាំងវិស័យអំពិលជាប់ក្ងរតទៅទៀត ប្រទះឃើញការចាប់ផ្តើមផ្សំកេសរផ្កាអំពិល ចាប់ផ្តើមតាំងតែមុនផ្កាផ្តើមបើកបានមួយថ្ងៃ ថ្ងៃពេលដែលផ្កាបើកបានមួយថ្ងៃ ក្រោយផ្កាបើករហូតដល់ 2 ថ្ងៃ ក្រោយផ្កាបើក ហើយប្រទះឃើញថាចំនួនដែលជាប់ក្ងរគិតជាភាគរយ តាមលំដាប់ដូចនេះ 32, 56, 32 និង 6 ភាគរយ ។ និងសង្កេតឃើញថាការជាប់ក្ងរអំពិលមិនគួរមានបញ្ហាដូចតួលេខរបាយការណ៍ដូចពោលមកហើយ ប៉ុន្តែហេតុអ្វីផ្កាអំពិលទើបជ្រុះយ៉ាងច្រើនសំបើម ហើយជួនកាលក៏ជ្រុះរស់រលីងទាំងដើម ប្រាប់អោយដឹងថាផ្កាអំពិលដែលជ្រុះទៅមួយភាគបានទទួលការផ្សំហើយ ចំនួនមិនតិចឡើយ ។ បញ្ហាដែលពោលថាអំពិលផ្អែមមិនជាប់ក្ងរនោះកើតមកពីផ្កាមិនបានផ្សំលំអងកេសរក៏គួរតែបញ្ចប់បាន ដូចនេះបញ្ហាអំពិលផ្អែមមិនជាប់ក្ងរ គួរតែគិតមានឡើងពីការខ្វះធាតុរ៉ែអាហារ ឬភាពមិនបរិបូរណ៍នៃដើមអំពិលនោះឯង ។ ចំណែកទឹកភ្លៀងដែលធ្លាក់តាមរដូវកាលនោះជាបច្ច័យបង្គោលទ្រទ្រង់សមុដ្ឋាន នៃការជាប់ក្ងរបានយ៉ាងពិតប្រាកដ ពីព្រោះទឹកជាបច្ច័យជួយក្នុងការនាំធាតុរ៉ែអាហារឡើងទៅប្រើក្នុងចន្លោះពេលជាប់ក្ងរ ។ ទាំងនេះក៏បានជាការពិតថាចន្លោះពេលបេះប្រមូលផលជាមួយនិងចន្លោះពេលសន្សំអាហារដើម្បីចេញផ្កានោះ ជាចន្លោះពេលខ្លីនិងជារដូវប្រាំង ការសន្សំអាហារច្បាស់ជាមិនគ្រប់ ទើបគួរអោយសង្កេតថាការដែលស្លឹកអំពិលជ្រុះនោះប្រហែលជាមួយភាគនៃការត្រៀមដើម្បីចេញផ្កា ដូចនោះក្នុងចន្លោះពេលដូចពោលមកហើយ គួរអោយមានធាតុរ៉ែអាហារដែលមានរូបមន្តសមស្រប ។ បញ្ហាជាប់ក្ងរអាចដោះស្រាយបានជាភាគមួយនៃការត្រៀមដើម្បីចេញផ្កា ។ ដូចនេះនៅក្នុងចន្លោះពេលពោលមកហើយនោះគួរមានការអោយធាតុរ៉ែអាហារដែលសមស្រប ។ បញ្ហាជាប់ក្ងរក៏អាចដោះស្រាយបាន ។

ការសន្និដ្ឋានក្នុងការដោះស្រាយបញ្ហាជាប់ក្មួរអំពិល :

តាមការសង្កេតអំពិលផ្អែមដែលជាប់ក្មួរស្មើគ្នារាល់ឆ្នាំនោះ ច្រើនតែអំពិលដែលដាំនៅក្នុងបរិវេណផ្ទះដែលបានទទួលទឹក និងធាតុរ៉ែអាហារបានទៀងទាត់ ធ្វើអោយការចេញផ្កាជាប់ក្មួរបានជាប់តគ្នាមកជារៀងរាល់ឆ្នាំ ។

ដោយហេតុនេះការដោះស្រាយបញ្ហាមិនជាប់ក្មួរ ទើបក្មួរតែដោះស្រាយដើមហេតុ ពីព្រោះអាហារជាវត្ថុដើមដែលសំខាន់ក្នុងការសាងអ័រម៉ូនដើម្បីអោយជាប់ក្មួរ ជាពិសេសអ័រម៉ូនអកស៊ិន ដែលនិងយកទៅប្រើក្នុងចន្លោះរយៈពេលផ្សាំជាប់ ឬរយៈពេលដែលសំបុកពងពង្រីកខ្លួន ក្រោយពីបានទទួលការផ្សំកេសរហើយ ។ រយៈពេលដុះលូតលាស់ចំរើនធំជាបញ្ហាទាក់ទងនឹងការជាប់ក្មួរ គឺការជ្រុះរយៈពេលដំបូង ឬ Early Drop ប្រើអ័រម៉ូនខាងក្នុងរុក្ខជាតិគឺអកស៊ិនមិនគ្រប់គ្រាន់ ផ្កាដែលផ្សំជាប់និងជ្រុះភ្លាម ដូចតាមរបាយការណ៍របស់លោក Luckwill; 1953 ដែលបានរាយការណ៍ថា ផ្កាដែលបានទទួលការផ្សំកេសររយៈពេលដំបូង បើមានអកស៊ិននៅតិចផ្កាដែលបានផ្សំជាប់ហើយនោះនិងជ្រុះភ្លាម ។

ដូចនោះការដោះស្រាយបញ្ហាការជាប់ក្មួរ ទើបត្រូវបានចាប់ផ្តើមពីភាពបរិបូរណ៍នៃរុក្ខជាតិជាប្រការសំខាន់ គោលគឺត្រូវធ្វើអោយដុះលូតលាស់ល្អបរិបូរណ៍ដើម្បីជួយអោយផ្កាចេញ ជាប់ក្មួរបានរាល់ឆ្នាំ ។ វិធានការអនុវត្តន៍គឺត្រូវអោយជីគ្រប់គ្រាន់ ទាំងជីឥន្ទ្រីយវត្ថុ ទាំងជីគីមី ។ការដាក់ជីគួរដាក់អោយបានច្រើន ហើយសល់ល្មមពីការសាងក្មួរ ដើម្បីនាំទៅប្រើការក្នុងការចេញផ្កាជាប់ក្មួរបាននៅក្នុងរដូវតទៅមុខទៀត ។ ទាំងនេះព្រោះធម្មជាតិអំពិលនោះនឹងចេញផ្កាជាប់ក្មួរទៅរហូតដល់រដូវភ្លៀង ។

ដូចនោះការអោយធាតុរ៉ែអាហារ ត្រូវពិចារណាអំពីការសន្សំអាហារនៅក្នុងដើមអោយសល់ទុកក្នុងរដូវប្រាំងដែលត្រៀមចេញផ្កាផង ។ ប្រការដែលគួរអោយចាប់អារម្មណ៍ទាក់ទងនិង

បញ្ហាជាប់គួរ ។ ប្រការមួយទៀតគឺការអោយទឹកអោយបានទៀងទាត់ ព្រមជាមួយនិងការអោយជី ពីព្រោះបើអំពិលមានការសន្សំអាហាររហូតដល់ពេលវេលា ការសាងអរ៉ម៉ូនដើម្បីចេញផ្កា និងជាប់គួរ ទើបមិនគួរមានបញ្ហាទេដូចឃើញស្រាប់ហើយថាអំពិលផ្អែមដែលដាំតាមផ្ទះដែលបានទទួលទឹកដែលបានប្រើនៅក្នុងផ្ទះ និងជីគ្រប់គ្រាន់ ទើបចេញផ្កា ជាប់គួរបានរៀងរាល់ឆ្នាំ ។ ការសង្កេតនេះទើបគម្បីជាចំណុចសំខាន់ក្នុងការអភិវឌ្ឍន៍ចំការអំពិលដែលត្រូវអាស្រ័យទឹកនៅក្នុងចន្លោះពេលវស្សាប្រាំងផង ទោះបីជាចំការអំពិលដែលដាំដោយអាស្រ័យទឹកភ្លៀងក៏ដោយ ។ ទាំងនេះកាលណាតម្លៃអំពិលនៅខ្ពស់នៅឡើយ ទាក់ទាញអន្ទងអោយផ្សងព្រេងយ៉ាងណាក៏ដោយ ។ ការដោះស្រាយបញ្ហានៅក្នុងរឿងពូជជាប្រការដ៏សំខាន់ដូចគ្នា បើសិនជ្រើសរើសពូជដែលសមស្រប ការប្រថុយផ្សងព្រេងក៏ថយចុះដែរ អំពិលពូជស្រាលដែលជាប់គួរ ហើយបេះប្រមូលផលបានមុនដូចជាពូជពណ៌ជីពូ ក៏គួរតែបានទទួលការពិចារណាប្រើជាពូជដែលដាំនៅកន្លែងដីអាស្រ័យទឹកភ្លៀង ពីព្រោះជាពូជដែលប្រែសភាពបានល្អ ទោះជាសភាពទឹកដីអាកាសធាតុមិនអំណោយក៏ដោយ ប៉ុន្តែទាំងនេះអនុវត្តន៍មើលថែរក្សាការពារអោយអំពិលបានល្អបរិបូរណ៍ នៅរហូតពេលវេលាក៏ជាកត្តាដែលត្រូវប្រកាន់យកដើម្បីអនុវត្តន៍ ។

បញ្ហាអំពិលផ្អែមជាប់គួរជាបញ្ហាធំ ដែលធ្វើអោយកសិកររុញរាដកថយក្នុងការអភិវឌ្ឍន៍ចំការតទៅ ។ ដូចនោះបច្ច័យដែលជួយដោះស្រាយបញ្ហាសំខាន់ដូចបានពោលមកហើយនោះបានគឺ ការកែប្រែដីអោយបានល្អគ្រប់ពេលវេលា ដោយការដាក់ជីផ្ទាប់ ជីអាចម៍គោ និងជីគីមីអោយបានគ្រប់គ្រាន់ រហូតដល់ការអោយទឹកបំប៉នក្នុងចន្លោះពេលចេញផ្កា ដោយមិនរង់ចាំទឹកភ្លៀង ទើបជឿជាក់ថាការមិនជាប់គួរនឹងពុំមានបញ្ហាទៀត ។

# ឧបសម្ព័ន្ធទីបី

## ការអនុវត្តន៍ថែរក្សាការពារអំពិលផ្អែម

ក្រុមបច្ចេកទេស ក្រុមហ៊ុន អេហ្វ អ៊ី ស៊ីល្វិក

យើងតែងបានឮអំពីពាក្យចចាមអារាមជានិច្ចអំពីពួកអ្នកកសិករចំការជាច្រើនកន្លែងដូចគ្នាក្នុងរឿងទាក់ទងដែលថាអំពិលផ្អែមក្លាយទៅជាអំពិលជូរទៅវិញ ហើយបាននិយាយអំពីពូជដែលបានដាំមកថាកើតទៅជាក្លាយពូជ ឬថាមិនដូចតាមពូជនោះបើដូចជាធ្លាប់បានបេះប្រមូលផលដែលមានរសជាតិផ្អែមអំពីដើមទាំងនោះមកអស់ហើយមួយរយៈក៏ដោយ រសជាតិបានក្លាយផ្លាស់ប្តូរទៅ ។ លក្ខណៈដែលបានជួបប្រទះដូចពោលមកនេះច្រើនតែជួបប្រទះជាចំការអំពិលដែលដាំនៅលើដីខ្សាច់ ឬដីគ្រួសក្រហម ហើយដាំ ហើយក៏លះបង់ចោលទៅគ្មានការមើលថែរក្សាការពារថែទាំអ្វីទេ ដោយមានជំនឿថាអំពិលជារុក្ខជាតិដែលអាចធន់និងភាពហួតហែងបាន ធន់នឹងសភាពបរិស្ថានទូទៅបាន មិនងាប់ងាយ ។ ទាំងនេះបណ្តាអ្នកដាំទាំងនោះតែងតែប្រៀបធៀបអំពិលជូរដែលបានមកអំពីការដាំគ្រាប់ជាគោល ។

តាមហេតុផលដូចបានរៀបរាប់មកខាងដើមគប្បីឃើញបានថា អ្នកដាំភាគច្រើននៅមានគោលគំនិតកប់ជិតជាប់នៅក្នុងរឿងដែលថា " អំពិលជារុក្ខជាតិធន់ ស៊ូ មិនបាច់ចាំមើលថែរក្សាច្រើនទេ " អ្នកដាំត្រូវមើលត្រឡប់មកក្រោយវិញថាអំពិលផ្អែមនោះក៏ដូចជាពេជ្រ-ផ្លែដីទៃៗទូទៅដូចគ្នា ត្រូវមានការយកចិត្តទុកដាក់មើលថែរក្សាការពារ ។ និយាយរួមប្រហាក់ប្រហែលគ្នា បើខុសគ្នាក៏ខុសបន្តិចបន្តួច ។ ក្នុងទីនេះសុំនិយាយចំពោះក្នុងរឿងដាក់ជី ឬការប្រើជីជាមួយវិធីអនុវត្តន៍ផ្សេងៗ ។ យើងអាចបែងចែករយៈពេលដាក់ជីតាមចន្លោះពេលដុះលូតលាស់ចំរើននៃដើមអំពិលផ្អែម (ចាប់ផ្តើមអោយផលហើយ) មានដូចតទៅនេះ :

1. រយៈពេលមុនបេះប្រមូលផល និងរយៈពេលចេញផ្កា ។ ដោយមកពីអំពិលផ្អែមជារុក្ខជាតិដែលមាននិស្ស័យផ្លាស់ស្លឹក និងចេញផ្កាពីផ្នែកចុងត្រួយមែកដែលចេញពីស្លឹកថ្មី ដូចនោះសុខភាពល្អបរិបូរណ៍នៃដើម មុនជម្រុះស្លឹកចោលទើបគួរតែមានវិធានការដ៏សំខាន់ចំពោះបរិមាណ និងភាពបរិបូរណ៍នៃផ្នែកផ្កាដែលប៉ុចឡើងមកថ្មីនោះផង ។ ដើមអំពិលដែលមានទំរង់គុម្ពដើមស្កុក មានមែកជាងភាគច្រើន តែងតែជួបប្រទះជម្រុះស្លឹកចោលមិនព្រមគ្នា ឬមិនស្មើគ្នាទេ ទើបបណ្តាលអោយចេញត្រួយ និងចេញផ្កាមិនព្រមគ្នាទៅផងដែរ ធ្វើអោយការចាត់ការថែរក្សាថែទាំ ជាពិសេសការដាក់ជី និងការបេះប្រមូលផលធ្វើទៅដោយពិបាក ។ ក្រៅពីនេះចេញផ្កាមកមិនបរិបូរណ៍ទោះបីជាបានផ្កា បរិមាណច្រើន ហើយផ្លែក៏ជាប់តិចទៅដែរ ។ ការកាត់តែងមែកក៏មានទំហំតូច និងមានចំនួនច្រើនរួមទាំងការកាត់មែកអោយខ្លីចាត់ជាវិធីក្តោបក្តាប់ទំហំ និងកំពស់នៃទំរង់គុម្ពដើមដែលល្អបំផុតមួយ ហើយព្រមទាំងជាកម្មវិធីក្តោបក្តាប់បរិមាណនៃផលិតផលអោយសមស្របទាំងនេះ ពីព្រោះចំនួនខ្ពស់បង្អស់ដែលនឹងកើតឡើងមកថ្មីនោះមានបរិមាណតិចចុះ ។ ការជណ្តើមចំណីអាហាររវាងមែកទើបចុះថយទៅតាមផងដែរ ។ ការជណ្តើមចំណីអាហារបន្សំដែលមានទើបអាចបញ្ជូនទៅចិញ្ចឹមមែកគ្រប់មែកដែលមាននៅបានដល់សព្វគ្រប់ ។ មែកដែលមាននៅទាំងអស់ទើបស្ថិតនៅក្នុងកិរិតល្អបរិបូរណ៍ស៊ីងតែទាំងអស់ ។ ក្រៅពីនេះការកាត់តែងមែកជួយកាត់បន្ថយឧបសគ្គក្នុងការបេះប្រមូលផលដែលផ្លែបណ្តាក់គ្នាជាបន្តបន្ទាប់ ប្រើរយៈពេលយូរទំរាំតែបេះប្រមូលផលអស់ពីដើម បើកាលណាបញ្ហាដោយការកាត់តែងមែក ហើយនិងជួយបន្ថយបញ្ហារយៈពេលវេលាដែលត្រូវប្រើក្នុងការប្រមូលផល ។

ឧបសគ្គដ៏សំខាន់មួយទៀត ដែលទាក់ទងមកពីរយៈពេលវេលាក្នុងការបេះប្រមូលផល ដោយរយៈពេលវេលាដូចបានពោលមកហើយ ក្នុងចន្លោះពេលក្បៀកគ្នានិងពេលជម្រុះស្លឹកអំពិលផ្អែម ដែលនិងផ្លែបន្តបន្ទាប់គ្នាដូចកាំច្រវាក់ ពាមគ្នាទៀតជាច្រើនឆ្នាំ បើសិនជាបេះប្រមូលផលយឺតយ៉ាវទៅទៀតក៏និងចេញផ្កា ជាប់ផ្លែហើយការអនុវត្តន៍

មើលរក្សាថែទាំការពារអោយល្អនោះ តែងតែប៉ះដល់ផ្ទិតផងដែរ ។ ឱកាសដែលផលិតក្តូរអំពិលអោយមានគុណភាពខ្ពស់មើបប្រព្រឹត្តិទៅដោយលំបាក ។

វិធានការមួយក្នុងការកែបញ្ហាដូចបានពោលមកហើយនោះ អាចធ្វើទៅបានដោយវិធីកាត់តែងមែក ព្រមទាំងដាក់ជីប៉ូតាស្យូម និងហ្វូសហ្វរសខ្ពស់មុនរយះពេលបេះប្រមូលផល ។ បើប្រសិនដាក់ជីតាមដីគួរដាក់អោយរយះពេលមុនប្រមូលផលប្រហែលមួយខែកន្លះ ប៉ុន្តែបើបាញ់តាមស្លឹកគួរអោយក្នុងរយះពេលមុនប្រមូលផលមួយខែជាដើមមក ដោយបាញ់ 2-3 ដង រយាលគ្នា 5-7 ថ្ងៃ ក្នុងពេលបាញ់ម្តងៗធាតុប៉ូតាស្យូមនិងជួយអោយសាច់អំពិលមានរសជាតិផ្អែមមុតច្រើនឡើង ដែលជាការអាចអោយយល់បានថាអំពិលផ្អែមក្លាយទៅជាពូជអំពិលផ្ការពារ ដោយសារតែបរិមាណនៃធាតុប៉ូតាស្យូមនេះ និងជួយទៅដឹកជញ្ជូនស្ករដែលបានផ្សំរួចហើយពីស្លឹក ហេតុនេះហើយបានជាស្លឹកត្រូវការប្រើសន្សំគីផ្នែកផ្លែនោះឯង សភាពដើមបើមិនមានស្លឹកច្រើនល្មមនោះនឹងរាំងការជាប់ក្តូរផ្លែ ។ ក្រៅពីនេះបើក្រោយពីពេលបេះប្រមូលផលហើយដើមនៅមានជីវះស្លឹកនៅឡើយ អាចប្រើជីតាមស្លឹកដែលមានដូចពោលមកហើយបាញ់ 1-2 ដងទៀតដើម្បីប្រើជញ្ជូនស្ករអំពីស្លឹកទៅសន្សំទុកនៅក្នុងមែក ហើយនឹងនាំត្រឡប់ចេញមកប្រើម្តងទៀតក្នុងរយះពេលចាប់ផ្តើមចេញស្លឹក បើសិនជាមានចំណីអាហារបន្សំបានច្រើនបំផុត ។ ផ្កានិងចុងមែកត្រួយដែលបានក៏រមែងមានភាពបរិបូរណ៍ល្អឡើង ។ ការជាប់ក្តូរនិងភាពបរិបូណ៌នៃក្តូរក៏ខ្ពស់ឡើងផងដែរ ។ ចំពោះធាតុហ្វូសហ្វរសនោះក៏មានចំណែកជួយអោយភ្នែកផ្កាប្លេតលាស់ឆាប់រហ័សឡើង ព្រមទាំងធ្វើអោយគ្រាប់ល្អបរិបូរណ៍ផង (បើសិនជាគ្រាប់មិនលូតលាស់ចំរើនធំធាត់ទេ ផ្នែករបស់ក្តូរត្រង់នោះច្រើនតែផត ធ្វើអោយរូបទ្រង់ទ្រាយក្តូរមិនស្អាតល្អ ហើយទំងន់ក្តូរក៏ថយចុះផង) ។

2. រយះពេលលូតលាស់ចំរើនធំនៃក្តូរអំពិល និងការលូតលាស់ចំរើនតាមមែកស្លឹក ដូចដែលបានពោលមកហើយខាងដើមថា និស្ស័យនៃការចេញផ្កាអំពិលនោះកើតមកអំពី

ភ្នែកផ្កាដែលផ្ទាកការដុះលូតលាស់ កាលណាមែកជាចុងមែកត្រួយក៏មានផ្កាជាប់តាមបកផងនៅផ្នែកខាងចុងមែក ។ អាហារបន្ទុំដែលមាននៅក្នុងដើមមុនជំរុះស្លឹកនោះជាផ្នែកដែលដើមអំពិលនាំយកមកប្រើតាមរបៀបនេះដែលត្រូវការសាងទាំងស្លឹក ទាំងផ្កាផង ។ ស្លឹកដែលសាងឡើងមកថ្មីនេះក៏ស្មើនិងការដាក់ទុននៃដើមអំពិលដោយផ្ទាល់ ហើយស្លឹកផ្នែកនោះមានបែបបទមួយដ៏សំខាន់ គឺមានតួនាទីសាងអាហារចិញ្ចឹមក្សួរផង ដូចនោះក្នុងចន្លោះរយៈពេលនេះការធ្វើអោយគ្រាប់ចំរើនបរិបូរណ៍ ទើបជាកត្តាដែលត្រូវការកើតមុន បើមិនដូចនោះទេក្សួរអំពិលក៏អាចខ្ជីកន្តុត។ ឬមួយក៏ផតស្បៀត ។ ក្នុងចន្លោះពេលក្រោយត្របកផ្កាក៏រុះរោយប្រហែល 2-3 សប្តាហ៍ អាចជួយអោយគ្រាប់លូតលាស់ល្អឡើង និងបន្ថយការជ្រុះធ្លាក់នៃផ្លែបានដោយអោយជីតាមស្លឹកដែលរូបមន្តក្នុងអត្រាភាគនិត្រូហ្សែន = ហ្វូសហ្វរុស = ប៉ូតាស្យូម ស្មើនិង 1:3:3 ចំពោះនិងលក្ខណៈដីទូទៅ ឬ 1:3:5 សំរាប់ដីរពាយខ្សាច់បាញ់ 1-2 ដង រយាលគ្នាប្រហែល 5-7 ថ្ងៃ ។ បើសិនដើមអំពិលល្អបរិបូរណ៍ណាស់ទៅហើយនោះ ការដាក់ជីក្នុងចន្លោះពេលដូចពោលមកនោះអាចមិនចាំបាច់សោះក៏បាន ។

ក្រោយពីជាប់ក្សួរហើយបានប្រហែលមួយខែ ជាចន្លោះរយៈពេលដែលក្សួរអំពិលលូតលាស់ចំរើនធំ គឺរយៈនៃការចំរើនលូតលាស់ធំនៃក្សួរនេះកើតឡើងព្រម។គ្នា ជាមួយនឹងការលូតលាស់ធំនៃមែកធាង និងស្លឹក ។ ដូចនោះការអោយជីក្នុងចន្លោះពេលនេះទើបត្រូវអោយដោយបរិមាណច្រើនគ្រប់គ្រាន់ ដោយមកពីខាងក្នុងដើមនោះត្រូវមានការបែងចែក (ឬដណ្តើមគ្នា) ។

អាហាររវាងផ្នែកដែលជាផ្លែ ឬក្សួរនិងផ្នែកដែលត្រូវប្រើសាងឫស ស្លឹក មែក ធាងថ្មី បើសិនសភាពដីមិនល្អបរិបូរណ៍នោះការដណ្តើមអាហារក៏កាន់តែខ្លាំងឡើង អំណាចឬឥទ្ធិពលស្រូបយកអាហារអំពីផ្នែកស្លឹក ឬឫស (ការលូតលាស់ចំរើនតាមស្លឹក មែក) តាមធម្មតាមានខ្ពស់ជាងផ្នែកក្សួរ ដែលអាចបណ្តាលអោយក្សួរជ្រុះធ្លាក់ ក្សួរស្វិតសំប៉ែត

ឬក្រពិត មិនល្អតលាស់ធំបរិបូរណ៍ ។ ការដាក់ជីក្នុងចន្លោះពេលនេះគួរប្រើជីដាក់តាមដី ដែលអាចមានអត្រាភាគ 1:1:1 ឬ 1-5:1:1 ដូចជា 15-15-15 ឬ 16-16-16 ឬរបមន្តខាងដើមលាយជាមួយអ៊ុយរ៉េ (UREA) អោយមានភាគសមរម្យល្មមគ្នាតាមតំរូវការ ជីអាចម៍គោ ឬជីផ្កាប់ បើសិនរកបានគួរដាក់ព្រមៗគ្នាផងក្នុងរយៈនេះ ព័ព្រោះជួយអោយមានប្រសិទ្ធិភាពក្នុងការដាក់ជីគីមីកាន់តែល្អឡើងទៀត ។ ការខូចខាតបាត់បង់ជីដោយហេតុមកពីការហូរច្រោះ (ជាពិសេសនៅក្នុងដីគ្រួសក្រហម ឬដីខ្សាច់) ក៏ប្រើការបានចំនួនតិចចុះ ។ ការដាក់ជីនៅក្នុងចន្លោះពេលនេះគប្បីបែងដាក់ 2-3 ដងអោយរយាលគ្នាបានប្រហែលមួយខែកន្លះ ដល់ពីរខែម្តង ដើមអំពិលអាចយកជីទៅប្រើបានត្រឹមតែម្តង ពីព្រោះកន្លែងដីដាំអំពិលផ្អែមច្រើនស្ថិតនៅលើដី ដែលជាដីគ្រួសក្រហម ឬដីខ្សាច់ភាគច្រើន មិនតែប៉ុណ្ណោះក្នុងរយៈពេលនេះអំពិលផ្អែមនៅក្នុងចន្លោះរដូវភ្លៀង កាន់តែធ្វើអោយអត្រាការច្រោះខ្ពស់ខ្លាំងឡើង រួមរយៈពេលដុះល្អតលាស់ដែលលាតសន្ធឹងពេលវេលាច្រើនខែ ។ ការដាក់ជីត្រឹមតែម្តងអាចធ្វើអោយដើម និងក្ខរផ្កាកការដុះល្អតលាស់ចំរើន ដោយមកពីដាច់ជីជាប់គ្នា ។ ចំពោះចន្លោះប្រុងប្រៀបត្រៀមដើមអោយស្រេចមុនពេលចេញផ្កា ដូចបានពោលមកក្នុងប្រការដំបូងហើយដែលជាចន្លោះពេលត្រូវដាក់ជីប៉ូតាស្យូម និងហ្វូសហ្វ័រសម្តងទៀត ។

គង់ឃើញថាការដាក់ជីដើមអំពិលនោះ ជាទូទៅគឺមានភាគច្រើនប្រហាក់ប្រហែលគ្នា និងឈើផ្លែផ្សេងៗដទៃៗទៀតអញ្ចឹងដែរ ។ ការដែលមានខុសគ្នានៅត្រង់អំពិលមានចន្លោះពេលអភិវឌ្ឍន៍គុណភាពខាងរសជាតិនៃសាច់ និងការត្រៀមសាងផ្នែកផ្កានៅក្នុងរយៈពេលជិតៗគ្នា និងជាន់គ្នាយ៉ាងណាក៏ដោយ ចាត់ទុកថានៅមានចំណែកល្អដោយមកពីរយៈទាំងពីរនេះ ត្រូវការជីអោយបានភាគប្រហាក់ប្រហែលគ្នា ។ ក្រៅពីនេះទីដីដែលបានដាំមកជាយូរយារណាស់មកហើយ មានការបេះប្រមូលផលជាប់ទាក់ទងគ្នារហូតមកក៏គួរគប្បីអោយអាហារ (ធាតុអាហាររង ឬធាតុអាហារបន្ទាប់បន្សំ) បន្ថែមផងដោយអាចបាញ់តាមស្លឹក ។ ធាតុអាហារទាំងនេះទោះបីដើមត្រូវការចំនួនតិចបំផុត

ក៏ដោយកាលណាប្រៀបធៀបទៅនិងការធាតុនីត្រូហ្សែន = ហ្វូសហ្វរុស = ប៉ូតាស្យូម ហើយបន្ថែមខ្លះខាតទៅពុំបាន ។ សភាពដីកាលណាប្រើអស់រយៈពេលយូរនោះធាតុទាំងអស់នេះបានត្រូវនាំចេញទៅពីដីតាមមែក ឬផ្លែ (គ្រាប់) ដោយពុំបានទូទាត់អោយមកវិញដោយប្រការណាឡើយនោះក៏មានឱកាសខ្វះខាតបានដូចគ្នា ។ ចំពោះរឿងទាក់ទងនិងការដាក់ជីក្នុងទីនេះ ពុំបាននិយាយអំពីបរិមាណជីដែលអោយដល់គ្នាទេ ដោយគិតថាអ្នកដាំមានការចេះដឹងល្មមសមគួរក្នុងរឿងអស់នេះហើយទើបពុំបាននិយាយ ។ ទោះជាយ៉ាងណាក៏ដោយអត្ថបទនេះក៏គង់ជាភាគមួយជួយអោយអ្នកដាំបែរត្រឡប់មកមើលដើមអំពិលផ្អែមរបស់ខ្លួនឯងខ្លះផង យ៉ាងហោចណាស់ក៏លះបង់គំនិតដែលនៅកប់ជិតនៅក្នុងចិត្តថា " អំពិលជារុក្ខជាតិធន់ធាន មិនត្រូវការថែរក្សាថែទាំការពារទេ " ចេញអោយអស់ ដើម្បីប្រុងប្រៀបត្រៀមអភិវឌ្ឍន៍គុណភាពអំពិលផ្អែមអោយបានល្អប្រសើរ និងត្រឹមត្រូវតទៅ ។



# ឧបសម្ព័ន្ធទីបួន

## សេចក្ដីណែនាំក្នុងការប្រកួតប្រជែងអំពិលផ្អែម

---

## ដោយលោក សៀន ហមណាន

បើកាលណានិយាយចេញឈ្មោះអំពិល ទោះបីជាអំពិលជូរ ឬផ្អែមក៏ដោយជនជាតិថៃទូទៅស្គាល់ច្បាស់ណាស់ ។ ប្រយោជន៍ក្នុងការយកអំពិលមកផ្ទៃប្រើមានច្រើនសន្ធឹកសន្ធាប់ណាស់ រាប់ចាប់ពីត្រួយ ក្លិប ខ្ចី ក្លរជិតចាស់ សូម្បីតែមែក ដើម ជ្រៅទៅដល់ឫសអំពិលទៅទៀត ។ រីឯគ្រាប់រុក្ខជាតិប្រភេទខ្លះស៊ីសាច់ហើយក៏ចោលទៅ ប៉ុន្តែគ្រាប់អំពិលនៅយកមកលីងលក់យកប្រាក់ យកមាស មានគុណភាពខាងសេដ្ឋកិច្ចកើតឡើងយ៉ាងចំឡែក ។ កម្លោះក្រមុំដែលមានធ្មេញនៅល្អបានភ្លក់រសជាតិគ្រាប់អំពិលលីងហើយប្រាប់ថា " ខ្ចិះឆ្ងាញ់កុំប្រាប់នរណាអោយដឹងអី " ។

នាពេលបច្ចុប្បន្ននេះផ្ទៃដីដែលដាំអំពិលផ្អែម បានពង្រីកយ៉ាងទូលំទូលាយ ហើយធ្វើជាចំការធំៗដាំជាជួរៗយ៉ាងត្រឹមត្រូវ មានការជ្រើសរើសចំរាញ់យកពូជល្អៗមកដាំ ហើយនៅពុំទាន់មានរុក្ខជាតិចំការប្រភេទណាដែលមានតម្លៃថ្លៃស្មើនិងអំពិលផ្អែម ដែលមានតម្លៃយ៉ាងខ្ពស់បំផុត មួយគីឡូក្រាមថ្លៃទៅដល់ 150-180 បាត បើសិនជាផ្អែមមែនទែនមានគុណភាពល្អ គ្មានរោគ ហើយក្លរធំៗក៏និងលក់បានថ្លៃ ជាពិសេសតាមកន្លែងណាដែលមានពួកអ្នកទេសចរណ៍បរទេសក៏អាចលក់បានថ្លៃរហូតដល់មួយគីឡូក្រាម 250-300 បាត ។ អំពិលផ្អែម ឬជូរចាត់ទុកថាជារុក្ខជាតិនាំចេញដ៏សំខាន់មួយ ។

ការប្រកួតអំពិលផ្អែមនាពេលនេះ ចាត់អោយមានជាប្រចាំជារៀងរាល់ឆ្នាំនៅក្នុងខេត្តពេជ្របូរណ៍ និងប៉ែកមួយផ្លូវទន្លេមេគង្គគឺខេត្តមុកដាហាន ឧបលរាជធានី ខេត្តនគរភ្នំ ខេត្តសកលនគរ ស៊ីសះកេត និងខេត្តណងខាយ ។ ការកាត់សេចក្ដីត្រូវប្រើវិធីមើលទំហំផ្លែ ផ្លែគ្មានរោគ រសជាតិផ្អែមជាគិរិត ។

នៅពេលថ្ងៃកសិកម្មជាតិចាប់ធ្វើឡើងនៅឯបរិវេណមហាវិទ្យាល័យកសិកម្មបាងខេន រវាងថ្ងៃទី 31 ខែមករា ដល់ថ្ងៃទី 07 ខែកុម្ភះ ឆ្នាំ 2530 ។ វិញ្ញាបនប័ត្រត្រូវក្រុមកសិកម្ម ឬក្រុមអ្នកចាត់ចែងបុណ្យកសិកម្មជាតិចេញអោយឈ្នះការប្រកួត នាំយកមកតាំងប្រកួតអំពិលផ្អែមប្រភេទផ្លែខុប ផ្លែខុបធំ ផ្លែត្រង់តូច ឬផ្លែដាវធំ ការប្រកួតអំពិលផ្អែមបុណ្យផ្កាកប្បាស់រីកនៅស្រុកលើយ ពីឆ្នាំ 2530 ដាក់កំរិតទំហំផ្លែ គឺផ្លែធំ ផ្លែធំមធ្យម ផ្លែតូចប៉ុណ្ណោះ ។ ដល់ឃើញហើយថា ការកំណត់ប្រភេទនិងបែបនៃផ្លែអំពិលក្នុងការប្រកួត មើលទៅស្មុគស្មាញ បើប្រសិនជាស្ថាប័នស្រាវជ្រាវរុក្ខជាតិចំការ ក្រុមបច្ចេកទេសកសិកម្ម និងក្រុមបណ្ដុះ-បណ្ដាលកសិកម្មឃើញសារៈសំខាន់ ដាក់គោលការណ៍ដែលអនុវត្តដូចគ្នានិងការប្រកួតស្រូវអង្ករថ្នាក់ប្រទេស ក៏គួរតែឃ្លីនិងបានអំពិលផ្អែមដែលមានលក្ខណៈល្អបរិបូរណ៍ជាងដែលមាននៅក្នុងពេលនេះ ។

ចំពោះអំពិលផ្អែមក៏គួរមានគោលការណ៍លក្ខខ័ណ្ឌប្រកួត ដោយបែងគោលការណ៍លក្ខខ័ណ្ឌទូទៅ និងលក្ខខ័ណ្ឌដែលទាក់ទងទៅនឹងអំពិលផ្អែម ។

<u>គោលការណ៍លក្ខខ័ណ្ឌទូទៅ</u> :

1. ចំការដែលបញ្ជូនអំពិលផ្អែមចូលទៅប្រកួតក្នុងរដូវដែលនឹងមកដល់នោះ ត្រូវដាក់ពាក្យសុំទៅខេត្ត ដាក់ឈ្មោះពូជយ៉ាងតិចណាមួយពូជ 5 ដើម ព្រមទាំងដាក់សញ្ញាសំគាល់ដើមទុកអោយគណៈកម្មការត្រួតពិនិត្យ ។

2. រុក្ខជាតិដែលដាំនៅក្នុងខេត្ត ក្នុងខេត្តនិមួយៗត្រូវមានយ៉ាងតិច 5 ចំការ ឬ 10 ចំការ
3. ចាត់តាំងគណៈកម្មការចំរុះថ្នាក់ក្រុម ឬថ្នាក់មហាវិទ្យាល័យ ។ គណៈកម្មការចំរុះត្រូវចាត់បញ្ជូនអ្នកបច្ចេកទេសអោយត្រួតពិនិត្យ តាំងតែពីលក្ខណៈដើម ការដាក់ផ្កា លក្ខណៈផ្កា និងភាពល្អបរិបូរណ៍ ការមើល និងការថែទាំរបស់អ្នកជាម្ចាស់ចំការគុណភាពរបស់សាច់អំពិល ។
4. អញ្ជើញប្រធានក្រុមកសិកម្មចូលរួមជាគណៈកម្មការផងដែរ ។

<u>គោលការណ៍លក្ខខ័ណ្ឌដែលទាក់ទងទៅនឹងអំពិលផ្អែម</u> :

1. <u>ចែកលក្ខណៈផ្កាអំពិល</u> :
    1. ពូជផ្កាដាវ
    2. ពូជផ្កាខុប ឬផ្កាគង
    3. ពូជផ្កាត្រង់
    4. ពូជផ្កាឆ្អឹង

2. <u>បែងចែកសមត្ថភាព និងលក្ខណៈប្រចាំពូជ</u> :
    1. ការដុះលូតលាស់ចំរើនក្នុងទីកន្លែងមូលដ្ឋានល្អ
    2. ទំរង់គុម្ពដើមស្រឡះ ជាប់ផ្កាច្រើនស្មែះជាងទំរង់គុម្ពដើមស្អុក
    3. ទំហំផ្កាធំត្រង់ និងស្រួលក្នុងការច្រកដាក់កេស ខ្ចប់សំរាប់លក់
    4. មានរសជាតិផ្អែមក្រអូប សាច់ស្អិត ពណ៌ក្រម៉ៅ សាច់ក្រាម
    5. ជាប់ផ្កាស្មើគ្នារាល់ឆាំ
    6. ផ្លែរហូតដើមខ្ពស់
    7. ធន់និងរោគសត្វល្អិត ផ្ការមិនបែក
    8. សំបកផ្កាក្រាស់ ធន់និងរោគសត្វល្អិតចង្រៃជាងពូជដែលមានសំបកផ្កាស្តើង

3. <u>គុណវិបត្តិប្រចាំពូជត្រូវតែផ្អែមខ្លាំង</u> : ចំពោះភាពផ្អែមប្រើវិធីវាស់ដោយគ្រឿងវាស់ភាពផ្អែម (Hand Refractometer) ចេញមកជាតម្លៃប្រៀបធៀបភាគរយនៃស្ករដូចគំរូនៃការប្រាប់លំអិត និងភាគរយស្ករដូចតទៅនេះ :

ក) ពូជត្រូឌិន ភូមិណាសាយ ឃុំព្រះខេមរ៉ាត ខេត្តឧបលរាជធានី មានគ្រាប់សំប៉ែត សាច់ធូរ គ្មានសរសៃគ្រាប់ជាប់នៅសល់ ក្បាលត្រង់ ទំងន់មួយគីឡូក្រាមមាន 106 ក្បាល :

- ទំងន់សាច់ = 520,00 ក្រាម
- ទំងន់គ្រាប់ = 213.3 ក្រាម
- ទំងន់សំបក = 266.7 ក្រាម
- មានភាពផ្អែម = 14.7 ភាគរយ

ខ) ពូជភូមិផៃឃៃ ស្រុកមួងសាមសិប ខេត្តឧបលរាជធានី ទំងន់ក្នុងមួយគីឡូក្រាមមាន 60 ក្បាល :

- ទំងន់សាច់ = 560 ក្រាម
- ទំងន់គ្រាប់ = 230 ក្រាម
- ទំងន់សំបក = 270 ក្រាម
- មានភាពផ្អែម = 14.3 ភាគរយ

3. <u>ពេលប្រមូលផល</u> : ចាត់ទុកថាលក្ខណៈប្រចាំពូជ មានភាពសំខាន់ទាក់ទងទៅនឹងទីផ្សារដែលទោះបីជាអំពិលផ្អែម ឬជូរក៏ដោយនិងចេញផ្កាសារដំបូងរវាងថ្ងៃទី 15 ខែមេសា រវាងចុងខែកក្កដា ដល់ខែសីហា ។ បេះប្រមូលផលប្រហែលខែវិច្ឆិកា ដល់ខែធ្នូ ។ <u>ឧទាហរណ៍</u> : ពេលវេលាបេះប្រមូលផលអំពិលផ្អែមគឺ :

ក) ពូជភូមិព្រះរាជន៍ ឃុំណាងឆាងវៃ ស្រុកម្លូងសាមសិម ខេត្តឧបលរាជធានី ដល់ថ្ងៃទី 19 ខែ វិច្ឆិការ ។

ខ) ពូជភូមិផៃវៃ ស្រុកម្លូងសាមសិម ខេត្តឧបលរាជធានី ពូជគ្រូអ៊ិន ស្រុកខេមរ៉ា-រ៉ាត ខេត្តឧបលរាជធានី បេះប្រមូលផលថ្ងៃទី 14 ខែធ្នូ ។

គ) ពូជពណ៌មាស ឬពូជណាយយ៉ាត ស្រុកឡមកៅ ខេត្តពេជ្របូរណ៍ បេះប្រមូល-ផលនៅថ្ងៃទី 25 ខែ ធ្នូ ។

គោលការណ៍លក្ខខ័ណ្ឌដូចបានពោលខាងលើនេះ ជាការយល់ឃើញចំពោះការស្នើរណែនាំអោយអ្នកដែលមានការពាក់ព័ន្ធយកទៅពិចារណាប្រើទៅតាមការសមស្រប ដោយជ្រើស-រើសប្រើចំពោះការដែលប្រកាន់យកជំនឿ និងការអនុវត្តន៍បើសិនជាបានទិន្នន័យណាមួយទៅប្រកាន់យកនិងការអនុវត្តន៍ពុំបានគ្រប់ ក៏គួរតែប្រកាន់យកកត្តាសំខាន់នៃលក្ខណះគួរ គុណ-សម្បត្តិប្រចាំពូជ អាយុនៃការបេះប្រមូលផលជាប្រការពិចារណាថ្នាក់ដំបូងៗ ។

ការប្រើពេលវេលាពិចារណាការប្រកួតគួរគប្បីអោយហើយស្រេចក្នុងរយះពេល 2-3 ម៉ោង ឬក្នុងរយះពេលមួយថ្ងៃយ៉ាងយូរ ។

<u>លទ្ធផលប្រកួតដែលមានគោលការណ៍លក្ខខ័ណ្ឌដោយសមស្របនឹងធ្វើអោយ</u> :

1. ប្រទេសថៃឡង់ដ៏និងមានអំពិលផ្អែមពូជល្អៗឡើងទៅ ។
2. ការបណ្តុះបណ្តាលកសិកម្មនិងអាចសន្និដ្ឋានបានថា អំពិលពូជផ្អែមណាជាពូជដែលគួរបណ្តុះបណ្តាល ។
3. ក្រុមបច្ចេកទេសកសិកម្ម និងក្រុមបណ្តុះបណ្តាលកសិកម្មរហូតដល់ពួកកសិករ ក៏មានចំណែកចូលរួមពិចារណាថានិងដាំអំពិលផ្អែមពូជណាល្អ ។

# ឯកសារយោង " References "

*អត្ថបទដើម (ភាសាថៃ) Original Text (Thai Language):*

Agriculture University (1st Edition) Office 1074; Bangkok Thailand, Post Code 10903

រូបភាពខាងក្រៅ Cover Picture

Sweet Tamarind by Kaknok Chhuonanont, Bangkok Thailand
Printed at Phatsayam Printing--Shop
Telephone Number : 587-0943

*រូបភាពទាំងនេះគូរដោយ*

*លោក សោម សារ៉ាត មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមភ្នំពេញ កម្ពុជា ខែតុលា ឆ្នាំ 1997*

*Artwork by:* Sarath, Som. Center for Social Development. Phnom Penh, Cambodia, October 1997.

*បកប្រែដោយគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែខេត្តតំបន់ពាយ័ព្យ ប្រទេសកម្ពុជា ថវិកាដែលផ្តល់សំរាប់ចងក្រងសៀវភៅនេះឧបត្ថម្ភដោយកម្មវិធីសិលា*

*Translation by the Cambodia Northwest Provinces Fruit Culture Development Committee. Support for the production of this book provided through the SEILA Programme.*

*Computer file:* TREEBK10.DOC

*បោះពុម្ពលើកទីមួយ (ខែតុលា ឆ្នាំ 1997) 500 ក្បាល*

*First Printing (October 1997): 500 copies*

*ហាមថតចម្លងនិងហាមលក់បើគ្មានការអនុញ្ញាត្តិពីគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែខេត្តតំបន់ពាយ័ព្យ*

***This book is not for sale nor to be re-printed without consent of the Author or the Cambodia North-West Provinces Fruit Culture Development Committee.***

# សមាសភាព

# គណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែខេត្តតំបន់ពាយ័ព្យ

| ល.រ. | នាម និងគោត្តនាម | មុខងារ | មកពីខេត្ត |
|---|---|---|---|
| 1. | លោក ជង់ ប៊ុនសួរ | ប្រធានគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ | បន្ទាយមានជ័យ |
| 2. | លោក ធៀន ចិន្ត | អនុប្រធានគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ | បាត់ដំបង |
| 3. | លោក អុង អេន | លេខាធិការគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ | បាត់ដំបង |
| 4. | លោក ស្រី អឿន | សមាជិកគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ | បាត់ដំបង |
| 5. | លោក ពង់ ចន្ថា | សមាជិកគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ | សៀមរាប |
| 6. | លោក គាន គិមៀន | សមាជិកគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ | សៀមរាប |
| 7. | លោក សោក សាវ៉ុន | សមាជិកគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ | ពោធិ៍សាត់ |
| 8. | លោក ជា ភិរុណ | សមាជិកគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ | ពោធិ៍សាត់ |
| 9. | លោក សៀង គង់ | សមាជិកគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ | ពោធិ៍សាត់ |
| 10. | លោក សាន ស៊ីម៉េង | សមាជិកគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ | បន្ទាយមានជ័យ |
| 11. | លោក ពង់ ប៊ុនធឿន | សមាជិកគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ | បន្ទាយមានជ័យ |
| 12. | កញ្ញា អៀង ងីម | សមាជិកគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ | សៀមរាប |
| 13. | លោក ម៉ក់ សឿន | នាយកដ្ឋានក្សេត្រសាស្ត្រ | ភ្នំពេញ |
| 14. | កញ្ញា ខាយលិ ចូន | អ្នកជំនាញការសេវាកម្មឈើហូបផ្លែ | បាត់ដំបង |
| 15. | លោក ស៊ាង ពៀត | ទីប្រឹក្សាគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ | បាត់ដំបង |
| 16. | លោក អ៊ិត សុផល | ទីប្រឹក្សាផ្នែកកសិកម្មអង្គការវៃយ៉េរ៉េ | បាត់ដំបង |

សរុបទាំងអស់មានចំនួន 16 នាក់

វាយកុំព្យូទ័រដោយ (Computer) លោក ញ៉ ផាលី